# របៀបដែលទេវតាមក ចំពោះខ្ញុំនិងបេសកកម្ម

បងប្អូនប្រហែលជា...ខ្ញុំឃើញខ្សែអាត់សម្លេងមួយចំនួននៅទីនេះ ហើយ ពួកគេនឹងរើសវាឡើងជាប្រាកដ។ ពេលណា បងប្អូនចង់ដឹងពីអ្វីដែលព្រះវិញ្ញាណ និយាយមកកាន់បងប្អូននោះ សូមយកខ្សែអាត់សម្លេងទាំងនេះ នោះ វាអាចបង្ហាញជាថ្មី អ្នកអាចទទួលអ្វីអ្នកចង់បានជាប្រាកដ។ សូមបងប្អូនផ្ទៀង ហើយមើលថា តើវា មិនបានកើតឡើងដូចអ្វីដែលបានថែងទេដែរឬអី អ្នកឃើញទេ។ ពេលដែលអ្នកលឺ ហើយបាននិយាយថា "**នេះជាពាក្យរបស់ព្រះជាម្ចាស់** 'ជាប្រាកដ នេះគឺរបៀបនេះ'" ហើយសូមពិនិត្យម្តងទៀតថា វាត្រឹមត្រូវឬទេ។ សូមមើល? វាគឺតែងដូចនោះ។

2 ឥឡូវ នេះជាប្រវត្តិតិចតួច...ខ្ញុំសប្បាយចិត្តនៅយប់នេះ ដែលពួកយើង មានគ្នាតិចតួចនៅទីនេះ។ ពួកយើងជាអ្នកស្រុកជាមួយគ្នា មិនអញ្ចឹង? គ្មាននរណាម្នាក់ ជាអ្នកផ្សេងឡើយ។ យើងមិន...ខ្ញុំនឹងប្រើវេយ្យាករណ៍ កេនតាគី ហើយមានអារម្មណ៍ដូចនៅ ផ្ទះអញ្ចឹង ពេលនេះ ព្រោះយើងជា—យើងជា...ហើយខ្ញុំនឹងមិនចំអក ពីកេនតាគីឡើយ ពេលនេះ បើមានអ្នកណានៅទីនេះមកពីកេនតាគី។ មានអ្នកណាមកពី កេនតាគី ទេ? សូមលើកដៃ។ និយាយ! ខ្ញុំមាន អារម្មណ៍ដូចនៅផ្ទះដែរ តើមិនអញ្ចឹងទេឬអី? នេះជាសេចក្តីសុខណាស់។

3 ម្តាយរបស់ខ្ញុំធ្លាប់បើកផ្ទះសំណាក់។ ថ្ងៃមួយខ្ញុំបានទៅទីនោះ ដើម្បីរក...មានក្រុមមនុស្សដែលស្នាក់នៅទីនោះ មាន តុ ធំ ហើយ វែង ដាក់រៀបចំស្រេច។ ហើយខ្ញុំនិយាយថា "មានមនុស្សប៉ុន្មានអ្នកមកពីកេនតាគី សូមក្រោកឈរ។" គ្រប់គ្នាក្រោកឈរ។ ហើយខ្ញុំបានទៅព្រះវិហារនៅយប់នោះជាព្រះវិហាររបស់ខ្ញុំ ហើយ ខ្ញុំនិយាយ "មានប៉ុន្មានអ្នកមកពីកេនតាគី?" គ្រប់គ្នាក្រោកឈរ។ ដូច្នេះ ខ្ញុំនិយាយ "បាទ នេះគឺល្អណាស់។" បេសកជនជាច្រើនបានធ្វើការយ៉ាងល្អ ដូច្នេះយើងសូមអរគុណសម្រាប់ការនេះ។

4 ឥឡូវក្នុងគម្ពីររ៉ូម ជំពូកទី ១១ និងខ ២៨។ សូមស្តាប់ដោយយកចិត្តទុកដាក់ចំពោះការអានខគម្ពីរនេះ។

*ដោយដំណឹងល្អ ពួកគេជាខ្មាំងសត្រូវដើម្បីប្រយោជន៍ដល់ អ្នករាល់គ្នា តែត្រង់សេចក្តីរើសតាំងនោះជាស្ងួនភ្ងាវិញ...ដោយព្រោះ ពួកឰយុកោ។*

*ដ្បិតព្រះមិនដែលស្តាយ អំណោយទានទ្រង់ ឬ ការដែលទ្រង់ ហៅមនុស្សណានោះឡើយ។*

5 សូមយើងអធិស្ឋានទាំងអស់គ្នា។ ព្រះអម្ចាស់អើយ សូមជួយយើងនៅយប់នេះ ឥឡូវ ដែលយើងបានចូលមកទ្រង់ ដោយការគោរពយ៉ាងជ្រាលជ្រៅ ដោយអស់ពីចិត្ត ក្នុងភាពស្មោះត្រង់ ដើម្បីសិរីរុងរឿងរបស់ទ្រង់ ទើបសេចក្តីទាំងនេះបានថ្លែងមក។ ហើយសូមជួយទូលបង្គំផង ឱព្រះអង្គម្ចាស់អើយ ហើយសូមទ្រង់ដាក់ នៅក្នុងគំនិតទូលបង្គំនូវអ្វីដែលត្រូវនិយាយ និងនិយាយជាប៉ុណ្ណា។ សូមបញ្ឈប់ទូលបង្គំពេលដែលដល់ពេលវេលារបស់ទ្រង់។ ទូលបង្គំ សូមអោយរាល់ចិត្តទាំងអស់ទទួលសេចក្តីទាំងនេះ សម្រាប់ជាប្រយោជន៍ដល់អ្នកជំងឺ និងអ្នកដែលត្រូវការជំនួយក្នុងចំណោមអ្នកចូលរួមនេះ។ ទូលបង្គំទូលសូមដោយនៅក្នុងព្រះនាមព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ត។ អាម៉ែន។

6 ឥឡូវ ខ្ញុំចង់បញ្ចូលប្រធានបទនេះ កាលបើយើងនៅគ្នាតិច នៅឡើយ។ ហើយ—ខ្ញុំព្យាយាមទុកពេលអោយអ្នកមិនយូរពេកទេ ខ្ញុំដាក់នាឡិការបស់ខ្ញុំនៅទីនេះ ហើយព្យាយាមធ្វើអ្វីដែលអាចធ្វើល្អបំផុតនាពេលឥឡូវនេះ ដើម្បីអោយអ្នកមានពេលវេលាដ៏ល្អ ដូច្នេះអ្នកអាចត្រលប់ទៅវិញនាយប់ថ្ងៃស្អែក។ ឥឡូវ សូមចូលក្នុងសេចក្តីអធិស្ឋាន។ ខ្ញុំមិនគិតថាក្មេងប្រុសត្រូវចែកកាតទេ។ ខ្ញុំមិនដែលសុំគាត់ថាតើគាត់...ហើយថា តើពួកគេបានទទួល ឬ មិនបានទទួល នោះមិនជាបញ្ហាអ្វីឡើយ។ យើងមានកាតជាច្រើននៅទីនេះ ប្រសិនបើមានអ្នកចង់បាន។ ដូច្នេះបើសិនជាមិន ហេតុអ្វី យើងនឹងមើលព្រះវិញ្ញាណបរិសុទ្ធ មានបន្ទូល។

7 ឥឡូវបើអ្នក ស្តាប់អោយជាក់...នេះគួរតែ...អោយខ្ញុំ...យើងមាន គ្នាតិចតួចទីនេះ វាជាការល្អ ដើម្បីនិយាយរឿងនេះ ព្រោះថា—នេះជា របៀបរបស់ខ្ញុំ។ ហើយជាហេតុផល ដែលខ្ញុំអានខគម្ពីរនេះនៅយប់នេះ ដែលអ្នកអាចឃើញ

អំណោយទាននោះ និងការត្រាស់ហៅ មិនមែនជាអ្វីដែលនរណាម្នាក់ សុទ្ធតែអាច សមនឹងទទួលនោះទេ។

8 លោកប៉ូលនិយាយនៅត្រង់នេះ គាត់បាននិយាយថា "ពួកជនជាតិយូដាដែលនៅចំពោះដំណឹងល្អ គឺងងឹតហើយ ហើយក៏នៅឆ្ងាយពីព្រះជាម្ចាស់ដែរ ដែលសម្រាប់ជាប្រយោជន៍ដល់យើងវិញ។" ប៉ុន្តែ មុនខទាំងនោះ បាននិយាយពីមុនថា "អ៊ីស្រាអែលទាំងអស់នឹងទទួលបានការសង្គ្រោះ។" អ៊ីស្រាអែលទាំងអស់នឹងបានសង្គ្រោះ។ តាមរយៈការរើសតាំង ព្រះជាម្ចាស់ជាព្រះបិតាបានស្រឡាញ់ពួកគេ ហើយបានធ្វើអោយគេងងឹត ដើម្បីអោយយើងដែលជាសាសន៍ ដទៃមានកន្លែងឥឡូវសម្រាប់ការប្រែចិត្តដែលតាមរយៈលោកអ័ប្រាហាំ ពូជរបស់ លោកអាច ប្រទានពរដល់ពិភពលោក ទាំងមូលតាមរយៈ ព្រះបន្ទូលទ្រង់។ ឃើញទេថា ព្រះមានអធិបតេយ្យភាពយ៉ាងណា? ព្រះបន្ទូលរបស់ទ្រង់បានសម្រេចឥតចន្លោះឡើយ។ ទ្រង់មិនដែលផ្លាស់ប្រែឡើយ។ ហើយឥឡូវ ដោយ...ព្រះជា ម្ចាស់បានរើសយើង ទ្រង់រើសជនជាតិយូរដា ហើយទ្រង់...

9 ទាំងអស់នេះជាការដឹងមុនរបស់ ព្រះតាំងពីដើមរៀងមក។ ពេលដែលទ្រង់មានបន្ទូលពីអ្វីដែលកើតឡើង ទ្រង់បានដឹងពីវារួចទៅហើយ។ ឥឡូវព្រះជាម្ចាស់ក្នុងនាមជាព្រះ តាំងពីដើមដំបូងឡើយ ទ្រង់បានជ្រាបដឹងពីទីបញ្ចប់ បើមិនដូច្នេះទេ ទ្រង់មិនមែនជាព្រះដែលមិនមានទីបញ្ចប់នោះឡើយ។ ព្រះជាម្ចាស់ មិនមានព្រះទ័យអោយនរណាម្នាក់រងក្តីវិនាសឡើយ។ ពិតជាមិនឡើយ! ទ្រង់មិនចង់អោយនរណាម្នាក់ត្រូវវិនាសឡើយ។ តាំងពីថ្ងៃដំបូងនៃ កំណើតពិភពលោក—ម្ល៉េះព្រះជាម្ចាស់បានជ្រាបដឹងយ៉ាងប្រាកដថា អ្នកណា ដែលត្រូវបានសង្គ្រោះ និងអ្នកណាដែលមិនត្រូវបានសង្គ្រោះ។ ព្រះជាម្ចាស់មិនសព្វព្រះទ័យអោយ មនុស្ស ត្រូវបាត់បង់ឡើយ។ "វាមិនមែនជាព្រះទ័យទ្រង់ឡើយ ដែលត្រូវអោយមនុស្សបាត់បង់ ប៉ុន្តែ ជាព្រះទ័យ របស់ទ្រង់គឺ សង្គ្រោះមនុស្សគ្រប់គ្នាវិញ" ប៉ុន្តែទ្រង់ ជ្រាបតាំងពីដើមដំបូងមកម្ល៉េះ ថានរណាដែលត្រូវ និងមិនត្រូវបានសង្គ្រោះ។ នេះជាហេតុផលដែលទ្រង់មានបន្ទូលជាមុន "*ការនេះ*នឹងកើតឡើង។ *ការនោះ*នឹងកើតឡើង" ឬ "*ការនេះ* នឹងក្លាយជាយ៉ាងនោះ។ មនុស្សនេះនឹងក្លាយជាយ៉ាងរបៀប *នោះ។*" ឃើញទេ?

10 ទ្រង់អាចដឹងជាមុន ព្រោះទ្រង់ជាព្រះដែលគ្មានទីបញ្ចប់។ បើសិនជាអ្នកដឹងថាវាមានន័យយ៉ាងណានោះជា "គ្មានអ្វីដែលទ្រង់ធ្វើមិនជ្រាបឡើយ។" ឃើញទេ ទ្រង់ជ្រាប។ គ្មានអ្វីដែលមុននេះ និងបន្ទាប់ពីនេះដែល ព្រះអង្គពុំជ្រាបឡើយ ឃើញទេ ទ្រង់ជ្រាបពីអ្វីគ្រប់យ៉ាង។ គ្រប់យ៉ាង មាននៅក្នុងគំនិតរបស់ទ្រង់។ ដូច្នេះវាក៏ដូចលោកប៉ូល បាននិយាយនៅក្នុងគម្ពីររ៉ូម ជំពូក៨ និង៩ "ហេតុអ្វី បានជាទ្រង់នៅតែរកឃើញកំហុស?" ដូច្នេះយើងឃើញចំណុចនោះទេ ប៉ុន្តែព្រះ ជាម្ចាស់...

11 ដូចការអធិប្បាយដំណឹងល្អ។ មានមនុស្សនិយាយថា "បងប្រុសប្រានហាំ តើលោកជឿរឿងនេះទេ?"

ខ្ញុំនិយាយ "មើល។"

និយាយ "អ្នកត្រូវតែធ្វើជាអ្នកកាល់វិននីស (Calvinist)។"

ខ្ញុំនិយាយ "ខ្ញុំជាអ្នកកាល់វិននីស (Calvinist) ដូចជាអ្នកកាល់វិននីស (Cal—vinist) ក្នុងព្រះគម្ពីរដែរ។"

12 ឥឡូវមានមែកនៅលើដើមឈើ នោះជាអ្នកកាល់វិននីសនិយម ប៉ុន្តែក៏មានមែកកាន់តែច្រើនដែរនៅលើដើមឈើដែរ។ ដើមឈើមួយមានមែកច្រើនជាងមួយ។ ព្រះអង្គចង់អោយយើងបន្តដំណើរទៅកន្លែងសុវត្ថិភាពអស់កល្ប ហើយមួយរយៈអ្នកនឹងចូលទៅនឹងភាពសកលនិយម ហើយអ្នកក៏នឹងជាប់នឹងកន្លែងណាមួយនោះគ្មានទីបញ្ចប់ឡើយ។ ប៉ុន្តែពេលអ្នកឆ្លងកាត់ជាមួយកាល់វិន ចូរត្រលប់មកវិញ ហើយចាប់ផ្តើមជាមួយអាមីនៀននិយម (Arminianism)។ ឃើញទេ មានមែកផ្សេងទៀតនៅលើដើមឈើ ហើយក៏មានមែកផ្សេងទៀតនៅលើ ដើមឈើដែរ សូមអោយវានៅតែបន្តដូច្នេះចុះ។ គ្រប់ផ្នែករួមបញ្ចូលគ្នា បង្កើតបានដើមឈើមួយ។ ដូច្នេះខ្ញុំជឿលើ—លើ...កាល់វិននិយមដែលមាននៅក្នុងអត្ថបទព្រះគម្ពីរ។

13 ហើយខ្ញុំជឿថា ព្រះជាម្ចាស់ទ្រង់ជ្រាបមុនការកកើតពិភពលោកនេះ ទ្រង់បានរើសព្រះវិហារទ្រង់ដាក់ក្នុងព្រះគ្រីស្ត និងការសោយទីវង្គត របស់ព្រះគ្រីស្តមុនការកកើតពិភពលោកនេះទៅទៀត។ អត្ថបទព្រះគម្ពីរបានចែងថា "ទ្រង់ជាកូន ចៀមនៃព្រះ ដែលត្រូវបានសម្លាប់ ពីការកកើតផែនដីនេះ។" ឃើញទេ? ព្រះយេស៊ូវមានបន្ទូលថា ទ្រង់ស្គាល់យើងរាល់គ្នាមុនកំណើតនៃផែនដីនេះទៅទៀត ប៉ូល និយាយថា "ទ្រង់—ទ្រង់ស្គាល់យើង ហើយតម្រូវយើងទុកជាមុន សម្រាប់អោយ ទ្រង់បាន

ទទួលជាកូនចិញ្ចឹមដោយសារព្រះគ្រីស្ទមុនពិភពលោក នេះបានបង្កើតមកម្ល៉េះ។ នោះជាព្រះជាម្ចាស់ នេះជាព្រះបិតារបស់យើង។ ឃើញទេ?

14 ដូច្នេះកុំបារម្ភ កង់កំពុងវិលទៅយ៉ាងត្រឹមត្រូវ គ្រប់ការចូលមកគឺមកតាមពេលវេលា។ សេចក្ដីតែមួយនោះ គឺវានឹងចូលតាមវេន។ ហើយនោះជា—នោះជាផ្នែកដ៏ល្អ ដូច្នេះអ្នកនឹងដឹងពីរបៀបធ្វើការពេលវាដល់វេនអ្នក។

15 ឥឡូវ កត់សម្គាល់ "អំណោយទាន និងការត្រាស់ហៅ ដែលពុំមាន ការកែប្រែចិត្តគំនិត" នោះគឺជាវិធីតែមួយដែលខ្ញុំអាច—អាចដាក់ការត្រាស់ហៅរបស់ខ្ញុំ ក្នុងព្រះអម្ចាស់ស្របតាមអត្ថបទព្រះគម្ពីរ។ ហើយក៏ទុកចិត្តថា ខ្ញុំ និងមិត្តទាំងឡាយនៅយប់នេះ គឺអ្នកនឹងយល់ការនេះជាប្រាកដ និងមិនគិតថាវាជារឿងបុគ្គលឡើយ ប៉ុន្តែដែលអ្នកអាចមានការយល់ និងដឹងតែថា អ្វី—ដែលព្រះបានមានបន្ទូលនោះទ្រង់នឹងធ្វើ ហើយរកអ្វីមួយដែលធ្វើចលនា និងដើរតាមការនោះ។

16 ឥឡូវតាំងពីដំបូងឡើយរឿងទីមួយដែលខ្ញុំអាចចងចាំបានគឺនិមិត្ត។ ការដំបូងដែលខ្ញុំអាចរំលឹកក្នុងគំនិតរបស់ខ្ញុំបាន គឺជានិមិត្ត ដែលព្រះជាម្ចាស់បានប្រទានមកខ្ញុំ។ ហើយការនោះ គឺជាច្រើនច្រើនឆ្នាំកន្លងទៅហើយ ខ្ញុំគឺនៅជាក្មេងប្រុសតូចមួយនៅឡើយ។ ហើយខ្ញុំមានថ្មនៅនឹងដៃ។

17 ឥឡូវ សូមស្ដាប់ខ្ញុំម្ដងទៀត ខ្ញុំចាំកាលពីខ្ញុំនៅកំពុងស្លៀកអាវផាយ។ ខ្ញុំមិនដឹងថា តើអ្នក (ខ្លះក្នុងចំណោមអ្នកទាំងអស់គ្នា) មានវ័យចំណាស់អាចចងចាំកាលពីក្មេងធ្លាប់ស្លៀកអាវផាយឬទេ។ តើមានប៉ុន្មានអ្នកនៅទីនេះ ដែលចងចាំកាលពីនៅក្មេងប្រុសបានស្លៀកពាក់អាវផាយ? បាទ ខ្ញុំអាចចងចាំ ក្នុងខ្ទមតូចចាស់របស់ខ្ញុំ នោះជាកន្លែងយើងបានរស់នៅ ខ្ញុំបានវារនៅលើឥដ្ឋ។ ហើយមានមនុស្សម្នាក់ ខ្ញុំមិនស្គាល់ថាជានរណា ទេបានចូលមក។ ហើយយាយខ្ញុំនៅធ្វើការទីនោះ—មានបូខៀវនៅលើអាវផាយខ្ញុំ។ ខ្ញុំនៅមិនទាន់អាច ដើរនៅឡើយ។ ប៉ុន្តែកាលនោះខ្ញុំកំពុងលូន ខ្ញុំជាប់ម្រាមក្នុងព្រិលទឹកកក លើជើងរបស់ពួកគេ ខ្ញុំក៏ញ៉ាំព្រិលទឹកកកពីជើងរបស់គាត់ ដែលកំពុងឈរនៅកន្លងចង្ក្រាន ដើម្បីកំដៅខ្លួន។ ខ្ញុំចាំថាម្ដាយរបស់ខ្ញុំក៏ទាញខ្ញុំឡើង។

18 ហើយបន្ទាប់មក រឿងដែលខ្ញុំចាំបន្ទាប់ គឺប្រហែលពីរឆ្នាំក្រោយមក ខ្ញុំមានថ្មតូចមួយ។ ហើយនោះប្រហែលជាខ្ញុំអាយុ៣ឆ្នាំហើយ ហើយបងប្អូនប្រុសខ្ញុំមិនទាន់អាយុ២ឆ្នាំពេញនៅឡើយ។ ហើយយើងក៏ចេញទៅ ធ្លារក្រោយផ្ទះដែល

គ្រាន់ តែជាកន្លែងកាប់អុសជាកន្លែងដែលគេប្រើសម្រាប់ទុកអុស និងកាប់អុស។ ប៉ុន្មានអ្នកដែលនៅចាំពីថ្ងៃនោះ កាលពីពេលដែលអ្នកធ្លាប់ដឹកអុស មកដាក់ធ្លារខាងក្រោយ ហើយកាប់អុស? ហេតុអ្វីនៅយប់នេះ ខ្ញុំនៅតែពាក់ក្រវ៉ាត់កដដែល? ខ្ញុំ—ខ្ញុំនៅផ្ទះហើយ។

19 ហើយពេលគេ...ចេញពីកន្លែងកាប់អុសចាស់ មានដៃស្នឹងតូចមួយមានប្រភពពីរន្ធទឹក។ មានបោយចាស់សម្រាប់ដួសទឹកមួយនៅទីនោះ ដែលពួកយើងដួសទឹកហើយចាក់វាក្នុងធុង ធុងធ្វើពីដើមស៊ីដាចាស់ ដួសហើយដួសទៀត។

20 ខ្ញុំចាំពេលចុងក្រោយដែលខ្ញុំឃើញ ជីដូនចាស់របស់ខ្ញុំមុនគាត់ស្លាប់ គាត់មានអាយុ១១០ឆ្នាំ។ ហើយពេលគាត់ស្លាប់ ខ្ញុំបានអោបគាត់ក្នុងរង្វង់ដៃខ្ញុំ ហើយគាត់អោបខ្ញុំវិញដូច្នេះដែរ មុនគាត់ស្លាប់។ គាត់ដាក់ដៃរបស់គាត់ជុំវិញខ្ញុំ ហើយនិយាយថា "ព្រះប្រទានពរដល់ព្រលឹងរបស់អ្នកចៅសម្លាញ់ ទាំងឥឡូវនេះ និងរៀងរហូតទៅ" ពេលដែលគាត់ស្លាប់។

21 ហើយខ្ញុំមិនគិតថា ស្ត្រីធ្លាប់មានស្បែកជើង មួយគូជា—ជារបស់ផ្ទាល់ខ្លួនឡើយ ក្នុងជីវិតរបស់គាត់។ ហើយខ្ញុំនៅចាំ ពេលខ្ញុំមើលគាត់ ខ្ញុំនៅជាយុវជននៅឡើយ ខ្ញុំទៅមើល រាល់ព្រឹកដែលគាត់ក្រោកឡើង ជើងទទេ ដើរកាត់ព្រិលទឹកកកទៅកាន់ប្រភពទឹក យកធុងទៅដងទឹក ហើយត្រលប់មកវិញ ជើងរបស់គាត់ស្ពាំនឹងការនោះហើយ។ ដូច្នោះ វាមិនធ្វើអោយអ្នកឈឺឡើយ គាត់រស់ដល់ទៅអាយុ១១០ឆ្នាំ។ ដូច្នេះ (ពិតមែនហើយបាទ) គាត់ពិតជាគួរអោយកំសត់ណាស់។

22 ដូច្នេះ ខ្ញុំចាំថា គាត់បានប្រាប់ខ្ញុំពីរឿង គ្រាប់កូនឃ្លី របស់ឪពុកខ្ញុំដែលគាត់ធ្លាប់លេង កាលពីគាត់នៅជាក្មេង។ "ហើយរឿងចាស់មួយនោះ" ខ្ញុំគិត "តើគាត់ក្រោកឡើងក្នុងបន្ទប់តូចដែលមានធ្នើរក្រោមដំបូលនោះយ៉ាងម៉េច?" ខ្ទមមួយមានពីរបន្ទប់ចាស់ ដែលបន្ទប់តូចមួយនោះ មានធ្នើរក្រោមដំបូល។ មាន កំណាត់ ឈើខ្ទីពីរកាត់ និងជណ្តើរមួយ។ មែន ខ្ញុំនិយាយ...

23 មែន ឥឡូវគាត់និយាយ "ឥឡូវ បន្ទាប់ពីអាហារពេលល្ងាច យាយនឹងប្រាប់ចៅ ប្រាប់ពី គ្រាប់ឃ្លីរបស់—របស់ឪពុកឯង។"

ហើយគាត់និយាយ "មែនហើយ។"

24 ដូច្នេះ គាត់ក៏នឹងបង្ហាញរបស់ទាំងនោះដល់ខ្ញុំ ក្នុងហិបនៅជាន់លើដែលជាកន្លែងគាត់ទុកឥវ៉ាន់ គឺដូចអ្នកស្រុកធ្វើដែរ។ ហើយខ្ញុំគិតថា "តើនៅក្នុងលោកនេះ របស់ចាស់ៗ ត្រូវទុកទីខ្ពស់ ហើយដាក់ជណ្ដើរឡើងអញ្ចឹងដូចម្ដេចកើត?" ដូច្នេះ ខ្ញុំទៅក្បែរៗនោះ ហើយនិយាយថា "លោកយាយ" ខ្ញុំនិយាយថា "ឥឡូវនេះ ចាំខ្ញុំតិច ខ្ញុំឡើងទៅ ហើយជួយយាយ។"

25 គាត់តបវិញថា "ឈរមួយកន្លែងទៅ។" ពេលឡើងជណ្ដើរនោះ គាត់ឡើងដូចជាកំប្រុកអញ្ចឹង។ គាត់និយាយ "បានហើយ មិនអីទេ!"

ហើយខ្ញុំនិយាយ "បាទ លោកយាយ អញ្ចឹងក៏បានដែរ។"

26 ខ្ញុំគិតថា "អូ បើខ្ញុំអាចដូចជាគាត់ដែរ នោះពិតជាមានកម្លាំងខ្លាំងមែន គាត់អាយុដល់១១០ឆ្នាំទៅហើយ!"

27 បន្ទាប់មក ខ្ញុំចាំថា នៅរន្ធទឹកតូចនោះ ហើយខ្ញុំមានថ្ម ហើយខ្ញុំគប់យ៉ាងនេះ គប់ចូលក្នុងភក់ ព្យាយាមបង្ហាញប្អូនប្រុសតូចខ្ញុំថាខ្ញុំខ្លាំងប៉ុណ្ណា។ ហើយនៅទីនោះមានបក្សីទុំលើដើមឈើ ហើយវាយំចេចចាច ជាចាបរ៉ូប៊ីន ឬ ជាសត្វអ្វីស្រដៀងនេះ។ សត្វចាបរ៉ូប៊ីនតូចនេះ ខ្ញុំគិតថាវានិយាយមកខ្ញុំ។ ហើយខ្ញុំបែរទៅស្ដាប់ ហើយសត្វនោះក៏ហើរចេញទៅ ហើយមានសម្លេងមួយនិយាយថា "អ្នកនឹងចំណាយពេលស្ទើរពេញមួយជីវិតរបស់អ្នកនៅជិតទីក្រុងមួយឈ្មោះថា ញូអាល់បានី (New Albany)។"

28 ប្រហែលជា៣ម៉ាលពីទីនោះ ជាកន្លែងដែលខ្ញុំធំឡើង។ កន្លងប្រហែល១ឆ្នាំក្រោយមក នៅកន្លែងនោះ ខ្ញុំមិនដែលមានគំនិតចង់ទៅ...ញូអាល់បានី (New Albany) សោះ។ មួយរយៈក្រោយមក រឿងទាំងនោះកើតយ៉ាងដូចម្ដេច...

29 ឥឡូវ សូមមើល អ្នកផ្ទះរបស់ខ្ញុំមិនមែនជាកាន់អ្នកសាសនាឡើយ។ ឪពុកនិងម្ដាយរបស់ខ្ញុំមិនទៅព្រះវិហារទេ។ មុននោះ ពួកគាត់ជាអ្នកកាតូលិក។

30 ក្មួយប្រុសតូចរបស់ខ្ញុំកំពុងអង្គុយ នៅទីណាមួយនៅយប់នេះ បើតាមខ្ញុំគិត ខ្ញុំមិនដឹងដែរ។ គាត់ជាទាហានម្នាក់។ ខ្ញុំកំពុងអធិស្ឋានអោយគាត់។ គាត់ជាអ្នកកាតូលិក ហើយនៅតែជាកាតូលិកដដែល។ ល្ងាចមុននោះ ពេលគាត់នៅទីនេះ និងបានឃើញការទាំងនោះមកពីព្រះជាម្ចាស់ គាត់កំពុងឈនៅទីនោះជិតឆាក។

ហើយគាត់និយាយថា "លោកពូ ប៊ីល (Bill)?" គាត់បានទៅបរទេសយូរមកហើយ និងនិយាយថា "ពេលខ្ញុំឃើញអញ្ចឹង..." ក៏និយាយថា "នោះ—មិនមានរឿងអញ្ចឹង នៅវិហារកាតូលិកឡើយ។" គាត់និយាយថា "នោះ...ខ្ញុំ—ខ្ញុំជឿ លោកពូប៊ីល (Bill) ខ្ញុំគាំទ្រលោកពូ" គាត់និយាយ។

31 ហើយខ្ញុំនិយាយថា "អូ នោះមិនមែន*ខ្ញុំ*ទេ មែនទេ គឺទ្រង់តើ ត្រូវទេ។ ឃើញទេ គឺ*ទ្រង់*មែនហើយ។" ហើយគាត់និយាយថាគាត់...ខ្ញុំនិយាយថា "ឥឡូវ ខ្ញុំមិនសុំអោយអ្នកធ្វើអ្វីទេ មេលវីន (Melvin) ប៉ុន្តែគ្រាន់តែបម្រើព្រះយេស៊ូវគ្រីស្ទដោយអស់ពីចិត្តរបស់អ្នកចុះ។ អ្នកអាចទៅណាតាមអ្នកចង់ក៏បាន។ ប៉ុន្តែអោយប្រាកដថា ក្នុងចិត្តអ្នក ព្រះគ្រីស្ទបានកើតជាថ្មី ឃើញនៅក្នុងចិត្តរបស់អ្នក។ បន្ទាប់មក អ្នកអាចទៅព្រះវិហារណាតាមចិត្តអ្នកបានបន្ទាប់ពីនេះ។"

32 ឥឡូវប៉ុន្តែបងប្អូនមុនៗខ្ញុំ ជាកាតូលិក។ ឪពុករបស់ខ្ញុំជាជនជាតិអៀរឡង់ ហើយម្តាយរបស់ខ្ញុំក៏ជាជនជាតិអៀរឡង់ដែរ។ អ្វីដែលបំបែកនោះ គឺនៅក្នុងឈាមយាយរបស់ខ្ញុំជាជនជាតិឆឺរ៉ូគីអិនដៀន (Cherokee Indian)។ ម្តាយរបស់ខ្ញុំ ជាពូជកាត់ពាក់-កណ្តាល។ ហើយដូច្នេះខ្ញុំ...ចំពោះខ្ញុំវាជារបស់ខ្ញុំ...ជំនាន់ ពួកយើងបន្ទាប់ពីបីជំនាន់មក វាក៏រលាយចូលគ្នា។ ប៉ុន្តែ អ្វីដែលជាសម្រេចទៅរួចនោះគឺជាការជាប់រឹងមាំជាមួយអៀរឡង់ហាវ៉េ (Harvey) និងប្រានហាំ (Branham) គឺជាឈ្មោះ។ ហើយបន្ទាប់ពីនោះគឺ លីយ៉ុង (Lyons) នៅតែជាអៀរឡង់ដដែល។ ហើយដូច្នេះពួកគេជាកាតូលិក។ ប៉ុន្តែសម្រាប់ខ្ញុំផ្ទាល់ យើងមិនមានការបង្រៀន ឬបង្ហាត់ពីសាសនាឡើយ កាលពីយើងនៅក្មេងៗឡើយ។

33 ប៉ុន្តែអំណោយទាំងនោះ និមិត្តនោះ ខ្ញុំឃើញនិមិត្តដូចអ្វីដែលខ្ញុំបានធ្វើឥឡូវនោះត្រូវណាស់ ព្រោះជាអំណោយទាន និងការត្រាស់ហៅដោយមិនស្តាយ។ ព្រះជាម្ចាស់បានជ្រាបមុននេះរួចទៅ ហើយមុននឹងព្រះជាម្ចាស់ធ្វើអ្វីមួយ។ តាមរយៈ បទពិសោធន៍ជីវិត ខ្ញុំមិនហ៊ាននិយាយអំពីការនេះទេ។

34 អ្នកបានអានរឿងរបស់ខ្ញុំក្នុងសៀវភៅតូចមួយហៅថា *ព្រះយេស៊ូវ*គ្រីស្ទ ទ្រង់មិនផ្លាស់ប្រែ ទ្រង់*ដូចថ្ងៃម្សិលមិញ ថ្ងៃនេះ* និង*ជារៀងរហូត*។ ខ្ញុំគិតថាវាមានខ្លះនៅក្នុងសៀវភៅផ្សេងៗទៀត។ ត្រូវទេជេន (Gene)? តើវាស្ថិតនៅក្នុងនេះទេ ជាទូទៅ—ជាទូទៅសៀវភៅនេះ មាននៅ—នៅក្នុងសៀវភៅដែល យើងមានឥឡូវនេះមែនទេ? តើវាជា *រឿងជីវិត ឬ*? ខ្ញុំគិតថា អញ្ចឹងមែន។ អញ្ចឹងពេល

យើងមាន...នេះគឺវាមិនគួរអោយខ្លាចមែនទេ? សៀវភៅផ្ទាល់ខ្លួនរបស់ខ្ញុំ ហើយខ្ញុំមិនដែលបានអានវាសោះ។ ប៉ុន្តែអ្នកផ្សេងទៀត បែរជាសរសេរវាឡើង ដូច្នេះវាជាអ្វីពួកគេបានយកមកពីក្នុងការប្រជុំ។ ខ្ញុំបានពិនិត្យមើល ដូច្នេះខ្ញុំចាំមើលអ្វីមួយផ្សេងទៀតដែលជានិច្ចនឹងកើតឡើង។ ដូច្នេះ មិនអីទេខ្ញុំបានអានផ្នែកខ្លះហើយអាននៅទីនេះ និងទីនោះ តាមតែខ្ញុំមានពេល។

35 ហើយឥឡូវនេះគឺក្នុងនាម—ក្នុងនាមជាក្មេងប្រុសតូចមួយ អ្នកដឹងទេថានិមិត្តដែលនិយាយមកកាន់ខ្ញុំនោះ ខ្ញុំមានអាយុ៧ឆ្នាំ ហើយនិយាយថា "កុំផឹកស្រា ឬកុំជក់បារី ឬ ប្រមាថរាងកាយអ្នកដោយរបៀបណាក៏ដោយឡើយ នឹងមានការងារសម្រាប់អ្នកធ្វើពេលដែលមានវ័យអ្នកចាស់ទៅ។" ហើយខ្ញុំក៏បានលឺពីក្នុងសៀវភៅដែរ។ មែន នោះជាការត្រឹមត្រូវ។ វាបន្តកើតឡើង ទាំងអស់នោះមក។

36 ពេលខ្ញុំក្លាយជាព័ន្ធការី បាទ នោះវា—នោះវាពិតជាបានចាប់ផ្តើមកើតឡើងគ្រប់ពេលវេលា។

37 ហើយយប់មួយខ្ញុំឃើញព្រះអម្ចាស់យេស៊ូវ។ ខ្ញុំនិយាយបែបនេះ ដោយការអនុញ្ញាតិ មកពីព្រះវិញ្ញាណបរិសុទ្ធ ខ្ញុំជឿថាអញ្ចឹង។ ទេវតារបស់ព្រះអម្ចាស់ដែលមកនោះមិនមែនជាព្រះយេស៊ូវទេ។ មើលទៅមិនដូចជាទ្រង់ឡើយ ក្នុងនិមិត្តដូចគ្នានោះ។ ព្រោះនិមិត្តដែលខ្ញុំឃើញព្រះអម្ចាស់យេស៊ូវទ្រង់ជាបុរសតូចម្នាក់។ ព្រះអង្គមិន...ខ្ញុំបាននៅខាងក្រៅក្នុងវាលអធិស្ឋានសម្រាប់ឪពុករបស់ខ្ញុំ។ ហើយខ្ញុំត្រលប់មកវិញហើយចូលទៅដេក ហើយនៅយប់នោះខ្ញុំឃើញទ្រង់ ហើយខ្ញុំ—ខ្ញុំនិយាយថា "ឱព្រះជាម្ចាស់ សង្គ្រោះគាត់ផង!។"

38 ម្តាយរបស់ខ្ញុំទទួលការសង្គ្រោះរួចហើយ ហើយខ្ញុំក៏បានជ្រមុជទឹកអោយគាត់ដែរ។ បន្ទាប់មកខ្ញុំគិតថា "ឱ ឪពុកខ្ញុំផឹកស្រាយ៉ាងដូច្នេះ។" ហើយខ្ញុំគិត "ខ្ញុំអាចនាំគាត់ទទួលព្រះអម្ចាស់យេស៊ូវ!" ខ្ញុំចេញទៅក្រាបចុះ លើពូកញាត់ចំបើងបន្ទប់ខាងមុខក្បែរទ្វា។

39 ហើយមានអ្វីនិយាយមកកាន់ខ្ញុំ "ក្រោកឡើង។" ហើយខ្ញុំក្រោក ដើរចេញទៅនិងដើរត្រលប់មកវាលខាងក្រោយវិញ ជាវាលដើមអំបោសស្លួត។

40 ហើយទីនោះ មានបុរសម្នាក់ ឈរចម្ងាយពីខ្ញុំមិនឆ្ងាយជាង១០ហ្វីតទេ លោកមានសម្លៀកបំពាក់ពណ៌ស មានអ្នកហែរហមខ្លះ លោកក្តោបដៃ*យ៉ាងនេះ* មាន

ពុកមាត់ រាងខ្លី សក់ត្រឹមស្មា ហើយលោកសម្លឹងមើលទៅទីឆ្ងាយពីខ្ញុំយ៉ាងដូច*នេះ* នោះជារូបភាពនៃសន្តិភាព។ ប៉ុន្តែខ្ញុំមិនយល់ពីការនោះឡើយ របៀបជើងលោកនៅក្រោយគ្នា។ ហើយខ្យល់បក់ រ៉ូបរបស់លោកកម្រើក បក់តិចៗ។

41 ខ្ញុំគិត "ឥឡូវ ចាំមួយនាទីសិន។" ខ្ញុំវាយខ្លួនឯង។ ខ្ញុំនិយាយថា "ឥឡូវខ្ញុំមិនងងុយដេកទៀតឡើយ។" ហើយខ្ញុំទាញចុះ ទាញបំណែកនេះចេញ អ្នកដឹងទេ ដូចយកឈើចាក់ធ្មេញចេញអញ្ចឹង។ ខ្ញុំយកវាមកដាក់ក្នុងមាត់។ ខ្ញុំមើលមកទៅផ្ទះវិញ។ ខ្ញុំនិយាយថា "ទេ ឥឡូវខ្ញុំនៅទីនេះ ដើម្បីអធិស្ឋានសម្រាប់ឱពុក ហើយមានអ្វីមួយនិយាយចេញពីទីនោះ ហើយទីនេះមានលោកនេះឯង។"

42 ខ្ញុំគិត "នោះដូចជាព្រះអម្ចាស់យេស៊ូវអញ្ចឹង។" ខ្ញុំគិត "ខ្ញុំឆ្ងល់ថា តើវាអញ្ចឹងមែនអត់?" ទ្រង់ទតមើលមកដូច្នេះ គឺទ្រង់ទតទៅកាន់ផ្ទះរបស់យើងឥឡូវនេះ។ ដូច្នេះ ខ្ញុំបង្វិលជុំវិញខ្លួនដោយរបៀបនេះ ដើម្បីមើលថាខ្ញុំអាចឃើញទ្រង់ឬទេ។ ហើយខ្ញុំអាចឃើញចំហៀងព្រះភ័ក្ត្រយ៉ាងនេះ។ ប៉ុន្តែទ្រង់...ខ្ញុំត្រូវវត់ចេញយ៉ាង*នេះ* ដើម្បីមើលទ្រង់។ ហើយខ្ញុំនិយាយថា "អឺម!" មិនអាចផ្លាស់ប្តូរទ្រង់ឡើយ។ ហើយខ្ញុំគិត "ខ្ញុំជឿ ខ្ញុំហៅទ្រង់។" ហើយខ្ញុំនិយាយ "ព្រះយេស៊ូវ។" ហើយពេលនោះ ទ្រង់ងាកយ៉ាងដូចនេះ។ នោះជាការទាំងអស់ដែលខ្ញុំចងចាំ ទ្រង់គ្រាន់តែលូកព្រះហស្ត ប៉ុណ្ណោះ។

43 គ្មានជាងគំនូរណាម្នាក់ ក្នុងលោកអាចគូរូបភាពទ្រង់ឡើយ លក្ខណៈនៃព្រះភក្ត្រទ្រង់ទេ។ ភាពល្អបំផុតដែលខ្ញុំមិនធ្លាប់ឃើញគឺ សៀវភៅដែលរៀបរាប់អំពី *ព្រះសិរសារបស់ព្រះយេស៊ូវវ័យ៣៣* ឆ្នាំនិពន្ធដោយហូហ្វមែន (Hofmann) ខ្ញុំបានប្រើក្នុងអក្សរសិល្ប៍ និងគ្រប់យ៉ាងដែលខ្ញុំប្រើ។ ព្រោះការឃើញនោះដូចអញ្ចឹង ហើយដូច្នេះ...ឬ ក្បែរ នៅជិតតាមតែអាចទៅរួច។

44 ទ្រង់ដូចជា (បុរសម្នាក់) ប្រសិនជាទ្រង់មានបន្ទូល ពិភពលោកនឹងដល់ទីបញ្ចប់ហើយមានក្តីស្រលាញ់យ៉ាងបរិបូរណ៍ និងក្តីសប្បុរសរហូតដល់អ្នក—អ្នក... ខ្ញុំអោយ។ ហើយនៅ ពេលថ្ងៃខ្ញុំឃើញខ្លួនឯងដូចនៅព្រលឹមអញ្ចឹង ភ្លួយ អាវទទឹកដោយទឹកភ្នែកពេល ខ្ញុំមកជាខ្លួនឯងវិញ ខ្ញុំដើរកាត់វាលដើមអំបោសស្លួតមកផ្ទះវិញ។

45 ខ្ញុំប្រាប់រឿងនេះទៅព័ន្ធការីដែលជាមិត្តរបស់ខ្ញុំ។ គាត់និយាយ "ប៊ីលលី (Billy) នោះនាំអោយអ្នកឆ្កួតហើយ។" គាត់និយាយ "នោះជាអារក្សហើយ។" ហើយ

និយាយថា "កុំអោយអ្នកវង្វេងជាមួយការគ្មានប្រយោជន៍នោះឡើយ។" ពេលនោះខ្ញុំជាអ្នកដឹកនាំបាបទីស្ទ។

46 មែនខ្ញុំទៅផ្ទះមិត្តភ័ក្តចាស់ម្នាក់ទៀតរបស់ខ្ញុំ។ ខ្ញុំអង្គុយចុះហើយនិយាយប្រាប់គាត់ពីរឿងនោះ។ ខ្ញុំនិយាយថា "បងប្អូនប្រុស តើអ្នកគិតយ៉ាងណាចំពោះរឿងនោះ?"

47 គាត់និយាយ "បាទ ប៊ីលលី (Billy) ខ្ញុំប្រាប់អ្នក។" គាត់និយាយថា "ខ្ញុំជឿ បើអ្នកព្យាយាមរក្សាជីវិតអ្នក អធិប្បាយអ្វីដែលមានក្នុងព្រះបន្ទូលនេះ ព្រះគុណរបស់ព្រះជាម្ចាស់នឹងបន្តហូរទៀត ខ្ញុំមិនចេញទៅតាមអ្វីជាភាពអស្ចារ្យ ដូចនោះទេ។"

48 ខ្ញុំនិយាយថា "លោក ខ្ញុំមិនមានន័យថា អោយចេញតាមអ្វីអស្ចារ្យទេ។" ខ្ញុំនិយាយ "គឺត្រឹមតែអ្វីដែលខ្ញុំព្យាយាមស្វែងយល់ថានេះជាអ្វីប៉ុណ្ណោះ។"

49 គាត់និយាយ "ប៊ីលលីជាច្រើនឆ្នាំហើយ គេមានការនោះក្នុងបណ្តាព្រះវិហារ។ ប៉ុន្តែ" និយាយ "ពេលពួកសាវ័កឈប់ ការទាំងនោះក៏ឈប់ដែរ។" ហើយនិយាយ "ឥឡូវ អ្វីដែលយើងមានគឺថា...ប្រភេទណាមួយ នៃការមើលឃើញការទាំងនោះ" និយាយ "វាជាវិញ្ញាណអារក្ស។"

ខ្ញុំនិយាយ "អូ បងប្រុស ម៉ាក់ឃីជនី (McKinney) អ្នកមានន័យអញ្ចឹងឬ?"

គាត់និយាយ "បាទ លោក។"

ខ្ញុំនិយាយ "អូព្រះជាម្ចាស់ សូមមេត្តាទូលបង្គំផង!"

50 ខ្ញុំនិយាយ "ខ្ញុំ—ខ្ញុំ...អូ បងប្រុសម៉ាក់ឃីជនី អ្នកនឹង—នឹងចូលរួមជាមួយយើងក្នុងការអធិស្ឋានថា ព្រះនឹងមិនដែលអោយវាកើតឡើង ជាមួយខ្ញុំទៀតទេ? អ្នកដឹងទេ ខ្ញុំស្រលាញ់ទ្រង់ ហើយខ្ញុំមិនចង់ខុសជាមួយការទាំងនេះទៀតឡើយ។" ខ្ញុំនិយាយ "សូមអធិស្ឋានជាមួយខ្ញុំ។"

51 គាត់និយាយ "ខ្ញុំនឹងធ្វើ ប្អូនប្រុសប៊ីលលី (Billy)។" ដូច្នេះយើងក៏អធិស្ឋាននៅទីនោះក្នុង—ក្នុងដំណាក់របស់ព្រះជាម្ចាស់។

52 ខ្ញុំសួរអ្នកដឹកនាំមួយចំនួនទៀត។ ការដដែល បានចេញមក។ ដូច្នេះ ខ្ញុំភ័យខ្លាចក្នុងការសួរគេបន្តទៀត ព្រោះគេគិតថាខ្ញុំជាអារក្ស។ ដូច្នេះ ខ្ញុំ—ខ្ញុំមិនចង់នៅជាយ៉ាងនោះទេ។ ខ្ញុំដឹងថាក្នុងចិត្តរបស់ខ្ញុំ ថានឹងមានអ្វីមួយកើតឡើង។

ឥឡូវ នេះគឺអស់ហើយ មាន—មានអ្វីមួយក្នុងចិត្តខ្ញុំបានកើតឡើង។ ហើយខ្ញុំមិនចង់ក្លាយជាយ៉ាងនោះទេ មិនឡើយ។

53 ដូច្នេះក្រោយមកទៀតក្នុងឆ្នាំនោះ ថ្ងៃមួយខ្ញុំបានលឺពីវិហារបាបទីស្ទទី១ដែលជាកន្លែងខ្ញុំជាសមាជិកនៅពេលនោះ ខ្ញុំលឺមានអ្នកនិយាយថា "និយាយ អ្នកគួរតែទៅ ហើយស្តាប់ពីគេដែលជាអ្នកជឿគិតថាខ្លួនបរិសុទ្ធ (holy rollers) កាលពីយប់មិញ។"

54 ហើយខ្ញុំគិត "អ្នកជឿគិតថាខ្លួនបរិសុទ្ធ (holy rollers)?" ហើយមិត្តខ្ញុំ វ៉លចនសុន (Walt Johnson) អ្នកច្រៀងបាស និងខ្ញុំនិយាយ "នោះជាអ្វី បងវ៉ល (Walt)?"

គាត់និយាយ "ក្រុមពួកអ្នក ពេតេកុស (Pentecostals)"

ខ្ញុំនិយាយ "អ្វីគេ?"

55 គាត់និយាយ "ពេតេកុស (Pentecostals)!" និយាយ "ប៊ីលលី (Billy) អ្នកធ្លាប់ឃើញទេ" និយាយ "ពួកគេជាអ្នក រមៀលលើកម្រាល ដូចយ៉ាងនេះ ហើយលោតឡើងលោតចុះ។" ហើយនិយាយ "ពួកគេនិយាយថា ពួកគេត្រូវនិយាយប៉ប៉ាច់ប៉ប៉ោចក្នុងរបៀបជាភាសាដទៃដែលមិនស្គាល់ឬ ពួកគេ—ពួកគេមិន ទទួលការសង្គ្រោះឡើយ។"

ហើយខ្ញុំនិយាយ "នៅឯណា?"

56 "អូ" និយាយ "តង់ចាស់តូចមួយជួបគ្នានៅទីនោះ នៅម្ខាងទៀតនៃ ឡូវីសវីល (Louisville)។និយាយពិតណាស់ជាពួកស្បែកខ្មៅ។"

ហើយខ្ញុំនិយាយ "អា-ហា។"

ហើយគាត់និយាយ "មានពួកជនជាតិស្បែកសច្រើនណាស់ នៅទី នោះ។"

ខ្ញុំនិយាយ "ពួកគេធ្វើអញ្ចឹង ដែរឬ?"

និយាយ "បាទ បាទ! ពួកគេក៏ធ្វើអញ្ចឹង ដែរ។"

57 ខ្ញុំនិយាយ "គួរអោយកំប្លែងមែន មនុស្សលាយទ្បំគ្នាបែបនេះ។" ខ្ញុំនិយាយ "ល្អ ខ្ញុំស្មានថាយើងត្រូវមានការទាំងនោះដែរ។" ព្រឹកថ្ងៃអាទិត្យឡើង ខ្ញុំមិនភ្លេចវា ទេ។ គាត់កំពុងបរិភោគ បំណែកសំបកក្រូចស្ងួត ដែលគាត់មានឈើឆ្កល់ក្រពះ ហើយ

ខ្ញុំអាចឃើញថា វាមើលទៅដូចថ្ងៃម្សិលមិញដែរ។ ហើយខ្ញុំគិត "និយាយ ប៉ប៉ាច់ ប៉ប៉ោច លោតឡើងលោតចុះនេះ ជាប្រភេទសាសនាអ្វីដែលគេនឹងមាននាពេលខាងមុខទៀត?" ហើយ ដូចច្នេះខ្ញុំ—ខ្ញុំបន្ត។

58 បន្ទាប់ពីនោះ ខ្ញុំជួបបុរសចាស់ម្នាក់ដែលនៅក្នុងព្រះវិហារទីនោះ ឬគាត់នៅទីនេះគ្រប់គ្រងក្រុមជំនុំផងគាត់ឈ្មោះចន រីយ៉ាន (John Ryan)។ ហើយខ្ញុំជួបគាត់នៅកន្លែង...មានបុរសចាស់ម្នាក់មានពុកមាត់ និងសក់វែង ហើយប្រហែលគាត់នៅទីនេះដែរ។ ខ្ញុំគិតថាគាត់មកពី បេនតុន ហាបបរ (Benton Harbor) មកទីនេះ នៅឯផ្ទះនៃដាវីឌ (David)។

59 ហើយពួកគេមានកន្លែងក្នុងឡូវីសវិល (Louisville)។ ខ្ញុំព្យាយាម ស្វែងរកពួក គេហើយពួកគេហៅវាថាសាលាពួកព្យាការី។ ដូច្នេះខ្ញុំគិតថា ខ្ញុំគួរតែទៅហើយមើល នោះជាអ្វី។ មែន ខ្ញុំមិនឃើញមាននរណារមៀលលើកម្រាលទេ ប៉ុន្តែពួកគេមានគោលលទ្ធិចម្លែក។ ហើយនោះជាកន្លែងដែលខ្ញុំជួបបុរសចាស់ គាត់អញ្ជើញខ្ញុំអោយមកកន្លែងគាត់។

60 ខ្ញុំចេញទៅវិស្សមកាល។ ហើយខ្ញុំនៅទីនោះមួយថ្ងៃ ហើយខ្ញុំត្រលប់ទៅផ្ទះរបស់គាត់ ហើយគាត់ចេញទៅ ហើយគាត់ទៅកន្លែងណាមួយនៅ អិនដៀអាយណាផូលិស (Indianapolis)។ ប្រពន្ធ គាត់និយាយ "ព្រះអម្ចាស់ហៅគាត់។"

ខ្ញុំនិយាយ "អ្នកមានន័យថា អោយបុរសនោះរត់ចេញដូច្នេះឬ?"

61 គាត់និយាយ "អូ គាត់ជាអ្នកបម្រើព្រះជាម្ចាស់!" រឿងចាស់ទើបស្លាប់ពីរបីសប្តាហ៍មុនខ្ញុំលឺ។ហើយនាងលះបង់សម្រាប់គាត់។ ខ្ញុំអើយ នោះជាប្រភេទប្រពន្ធដែលត្រូវតែមាន! ត្រូវទេ។ ត្រូវ ឬ ខុស ទោះយ៉ាងណាគាត់ត្រូវហើយ! ខ្ញុំនិយាយ... មែន ខ្ញុំស្គាល់ពួកគេ...

62 ឥឡូវគាត់...បងប្រុសរីយ៉ាន (Ryan) អ្នកនៅទីនេះទេ? គាត់មិននៅទីនេះទេ។ គាត់នៅថ្ងៃផ្សេងទៀត គាត់មិនអញ្ជឹង ក្មេងប្រុស?

63 មែន គេរស់នៅត្រឹមតែអ្វីដែលគេអាចកាន់បាន ហើយគាត់មិនមានអ្វីបរិភោគនៅក្នុងផ្ទះឡើយ។ ពិតមែន។ ហើយខ្ញុំបានចាប់ត្រីខាងក្រៅ នៅឯស្រះ ឬ បឹងនៅមីឈីហ្គេន (Michigan) ហើយត្រលប់មក—ហើយខ្ញុំត្រលប់មកកន្លែងវិញ។

ហើយពួកគេមិនមាន សូម្បីតែដុំខ្លាញ់ជ្រូកនៅផ្ទះផង ឬ ខ្លាញ់ចម្អិនត្រី។ ហើយខ្ញុំនិយាយ "គាត់ចេញពីអ្នកដោយគ្មានបន្សល់អ្វីក្នុងផ្ទះឬ?"

និយាយ "អូ តែគាត់ជាអ្នកបម្រើព្រះជាម្ចាស់ ប្អូនប្រុសប៊ីល!" និយាយ "គាត់..."

64 ហើយខ្ញុំគិត "មែន ប្រទានពរដល់ចិត្តអ្នក។ បងប្រុសខ្ញុំឈរនៅខាងបង។" ពិតណាស់។ "អ្នកគិតច្រើនណាស់ពីប្តីរបស់អ្នក ខ្ញុំត្រៀមរួចជាស្រេចក្នុងការចូលរួម និងឈរជិតអ្នក សម្រាប់ការនោះ។" ត្រូវហើយ។ យើងត្រូវការស្ត្រីបែបនោះកាន់តែច្រើននាបច្ចុប្បន្ន និងបុរសដែលគិតពីប្រពន្ធបែបនោះដែរកាន់តែច្រើនដែរ។ ពិតណាស់។ វានឹងក្លាយជាអាមេរិកកាន់តែប្រសើរ បើប្តី និងប្រពន្ធរួមគ្នាដូចនោះ។ ត្រូវ ឬ ខុសចូរអោយនៅដូចជាពួកគេ។ នឹងមិនមានការលែងលះច្រើននោះទេ។

65 ដូច្នេះយើង—យើងទៅ...បន្ទាប់មកខ្ញុំបន្ត។ ហើយតាមផ្លូវមកផ្ទះខ្ញុំវិញ មានការចម្លែកមួយ ខ្ញុំមកផ្ទះកាត់តាម មីសសាវ៉ាកា (Mishawaka)។ ហើយឃើញឡានតូច—តូចចាស់មួយចតតាមផ្លូវមើល...មានស្លាកសញ្ញាធំមួយលើឡាន "ព្រះ យេស៊ូវតែមួយគត់។" ខ្ញុំគិត "តើ...'ព្រះយេស៊ូវតែមួយ' នោះពិតជាសាសនា។" ហើយ ខ្ញុំទៅទីនោះ ហើយមានកង់មួយមានស្លាកលើនោះថា "ព្រះយេស៊ូវតែមួយគត់។" កាឌីឡាស ម៉ូដែល-ធី ហ្វដ (Cadillacs, Model-T Fords) គ្រប់យ៉ាងសុទ្ធតែមាន "ព្រះយេស៊ូវតែមួយគត់" នៅលើនោះ។ ខ្ញុំគិត "មែនឆ្ងល់ណាស់ នោះ ជាអ្វី?"

66 ដូច្នេះខ្ញុំទៅតាម ហើយក៏រកឃើញ វាជាការជួបជុំបែបសាសនាដ៏ធំមនុស្ស១៥០០ទៅ២០០០នាក់នៅទីនោះ។ ហើយខ្ញុំលឺនៅទីនោះមានការស្រែកលោតឡើងលោតចុះ ហើយអ្វីជាច្រើនទៀត។ ខ្ញុំគិត "និយាយ នេះជាកន្លែងខ្ញុំនឹងឃើញថា អ្នកជឿគិតថាខ្លួនបរិសុទ្ធ (holy rollers) ហើយ។"

67 ដូច្នេះ ខ្ញុំមានឡានហ្វដ (Ford) ចាស់មួយ អ្នកដឹងទេ នោះខ្ញុំបើកប្រហែលល្បឿន៣០ម៉ាលក្នុងមួយម៉ោង ជួន១៥ម៉ាលតាមផ្លូវ*នេះ* និង១៥ម៉ាលឡើងចុះតាមផ្លូវ*នេះ*។ ដូច្នេះខ្ញុំដាក់វាម្ខាង ខ្ញុំ...ពេលខ្ញុំរកកន្លែងចតបាន ហើយក៏ដើរត្រលប់មកក្រោយវិញ។ ដើរចូលទៅក្នុង មើលជុំវិញ គ្រប់គ្នាឈរតាមតែអាចឈរបាន។ ខ្ញុំត្រូវមើលរំលងក្បាលពួកគេ។ ហើយពួកគេកំពុងតែស្រែក និងលោត ហើយខ្លះដួលចុះ និងផ្សេងៗទៀត។ ខ្ញុំគិត "មើល ហូ នេះជាមនុស្សយ៉ាងណា!"

68 ប៉ុន្តែដរាបណា ខ្ញុំឈរនៅទីនោះកាន់តែយូរ ខ្ញុំកាន់តែមានអារម្មណ៍ប្រសើរឡើង។ ខ្ញុំគិត "នោះជាការល្អណាស់។" ខ្ញុំគិតថា "គ្មានអ្វីខុសជាមួយអ្នកទាំងនោះទេ។ ពួកគេមិនមែនឆ្កួតទេ។" ខ្ញុំត្រូវទៅនិយាយជាមួយអ្នកខ្លះក្នុងអ្នកទាំងនោះ ដូច្នេះ ពួកគេ—ពួកគេជាមនុស្សល្អ។ ដូច្នេះខ្ញុំនិយាយ...

69 មែន ឥឡូវ នោះដូចជាការប្រជុំដែលខ្ញុំបានទៅ ហើយនៅពេញមួយយប់ ហើយថ្ងៃបន្ទាប់ខ្ញុំចូលក្នុង។ ហើយអ្នកលឺខ្ញុំប្រាប់រឿងក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំនៅលើឆាកជាមួយអ្នកដឹកនាំ១៥០នាក់ ទៅ ២០០នាក់ហើយប្រហែលច្រើនជាងនេះទៅទៀត ហើយពួកគេចង់អោយគ្រប់គ្នាគ្រាន់តែងើបឡើង ហើយប្រាប់ថាពួកគេមកពីណា។ ហើយខ្ញុំនិយាយ "អ្នកផ្សាយដំណឹងល្អ វិល្លៀមប្រានហាំ (William Branham) មកពី ចេហ្វឺសាន់វិល (Jeffersonville)" អង្គុយចុះ "បាបទីស្ទ" ដូច្នេះក៏បានអង្គុយចុះ។ ម្នាក់ៗប្រាប់ថាពួកគេមកពីណា។

70 ដូច្នេះព្រឹកបន្ទាប់ ពេលខ្ញុំចូលទៅ...ខ្ញុំដេកនៅក្នុងវាលពេញមួយយប់នៅយប់នោះហើយអ៊ុតខោខ្ញុំនៅចន្លោះកៅអីអង្គុយពីរអ្នកដឹង ហើយខ្ញុំ ខ្ញុំ...ខោសៀសាក់ខឺ (seersucker)ចាស់ អាវតូចមួយ អ្នកដឹងទេ។ ដូច្នេះព្រឹក បន្ទាប់ ខ្ញុំទៅការប្រជុំពាក់អាវយឺតតូច។ ហើយខ្ញុំចេញទៅ...

71 ខ្ញុំមិនមានអ្វីក្រៅពីលុយ៣ដុល្លារទេ ហើយខ្ញុំមានសាំងគ្រប់គ្រាន់ត្រលប់មកផ្ទះវិញ។ ហើយដូច្នេះខ្ញុំ—ខ្ញុំដាក់ដុំរ៉ូល (roll) ប្រភេទចាស់អ្នកដឹងទេ ប៉ុន្តែខ្ញុំរីករាយ។ ហើយខ្ញុំមានបំពង់ពន្លត់ភ្លើង (hydrant) ខ្ញុំមានកែវទឹក អ្នកដឹងទេ ហើយពួកវា ទាំងអស់នោះល្អមែន។ ដូច្នេះខ្ញុំត្រូវផ្សើមទឹកបន្តិច ហើយបន្ទាប់មកក៏បរិភោគអាហារពេលព្រឹក។

72 ឥឡូវ ខ្ញុំអាចបរិភោគជាមួយពួកគេ ឥឡូវ ពួកគេបរិភោគ២ដងក្នុងមួយថ្ងៃ។ ប៉ុន្តែខ្ញុំមិនអាចមិនដាក់ដង្វាយទេ ដូច្នេះខ្ញុំមិន—មិនលាងចានទេ។

73 ដូច្នេះខ្ញុំ ខ្ញុំ—ទៅដល់ទីនោះពេលព្រឹក ពួកគេនិយាយ...ខ្ញុំគ្រាន់តែប្រាប់ផ្នែកខ្លះពីវា។ ហើយដូច្នេះទៅដល់ទីនោះពេលព្រឹក ហើយពួកគេនិយាយ "យើងកំពុងរកវិល្លៀមប្រានហាំជាក្មេងផ្សាយដំណឹងល្អបាទីស្ទនៅលើឆាកកាលពីយប់មិញ។" និយាយ "យើងចង់អោយគាត់នាំសារនៅព្រឹកនេះ។" ខ្ញុំឃើញថា វាជាការទាញខ្ញុំយ៉ាងលំបាកពីក្រុមមនុស្សទាំងនោះ ខ្ញុំជាអ្នកខាងបាទីស្ទ។ ដូច្នេះ ខ្ញុំគ្រាន់តែនៅអង្គុយជាប់នឹងកន្លែង។ ខ្ញុំស្លៀកខោ សៀសាក់ខឺ និងអាវយឺត អ្នកដឹង

ទេ ហើយយើងស្លៀកពាក់ជាសង្ឃ ដូច្នេះ...ហើយខ្ញុំត្រលប់នៅកន្លែងអង្គុយយ៉ាងដូចនេះ។ ដូច្នេះ គាត់សួរ២ទៅ៣ដង។ ហើយនៅជាមួយក្មេរនឹងបងប្អូនប្រុសស្បែកពណ៌។

74 ហើយហេតុផលដែលពួកគេមានសន្និបាតនៅភាគខាងជើង ព្រោះការរើសអើងពូជសាសន៍នៅភាគខាងត្បូង។ ដូច្នេះគេមិនអាចធ្វើនៅខាងត្បូងបាន។

75 ដូច្នេះខ្ញុំឆ្ងល់ថាពាក្យ "ព្រះយេស៊ូវតែមួយគត់" ជាអ្វី។ ហើយខ្ញុំគិត "កាលមានព្រះយេស៊ូវ គឺជាការល្អ។ ដូច្នេះ វាមិនមានការខុសគ្នា ថាតើវាជា...វាដូចម្តេច ដរាបណានោះនៅតែជាទ្រង់។"

76 ដូច្នេះ ខ្ញុំអង្គុយទីនោះមួយភ្លែតហើយមើលទៅគាត់ ហើយពួកគេហៅ២ទៅ៣ដងទៀត។ ហើយបងប្អូនប្រុសជនជាតិស្បែកពណ៌ម្នាក់មើលមកខ្ញុំ ហើយគាត់និយាយ "អ្នកស្គាល់គាត់ទេ?" ខ្ញុំ—ខ្ញុំ—ខ្ញុំ...ការបង្ហាញគឺនៅទីនោះ។ ខ្ញុំមិនអាច លាក់នឹងបុរសម្នាក់នោះបានឡើយ ហើយខ្ញុំក៏មិនចង់ដែរ។

ខ្ញុំនិយាយ "មើល បងប្រុស។ បាទ ខ្ញុំស្គាល់គាត់។"

គាត់និយាយ "មែន ទៅយកគាត់មក។"

77 ខ្ញុំនិយាយ "ល្អ ខ្ញុំ—ខ្ញុំនឹងប្រាប់អ្នក បងប្រុស" ខ្ញុំនិយាយ "ខ្ញុំគឺជាម្នាក់នោះហើយ។ ប៉ុន្តែ អ្នកឃើញ" ខ្ញុំនិយាយ "មើល ខ្ញុំ...ខោសៀសាក់ខី។"

"ឡើងទៅណោះទៅ។"

78 ហើយខ្ញុំនិយាយ "ទេខ្ញុំមិនអាចឡើងទៅបានទេ" ខ្ញុំនិយាយ "ស្លៀកខោយ៉ាងនេះ ដូចអញ្ចឹង អាវយឺតតូច។"

និយាយ "ពួកគេជាមនុស្សមិនខ្វល់ថាអ្នកស្លៀកអ្វីទេ។"

79 ហើយខ្ញុំនិយាយ "មែនមើល កុំអោយអ្នកយកចិត្តទុកដាក់វាខ្លាំពេក។ លឺទេ?" ខ្ញុំនិយាយ "ឃើញខ្ញុំស្លៀកខោក្រណាត់សៀសាក់ខី ខ្ញុំមិនចង់ឡើងទៅទីនោះទេ។"

និយាយ "អ្នកណាស្គាល់វិល្លៀមប្រានហាំ (William Branham) នៅឯណាទេ?"

គាត់និយាយ "គាត់នៅទីនេះ! គាត់នៅទីនេះ!"

80 អូ ខ្ញុំអើយ! មុខរបស់ខ្ញុំក្រហម អ្នកដឹងទេ គ្មានក្រវ៉ាត់ក អ្នកដឹងហើយ ហើយ អាវយឺតចាស់តូចមួយ អ្នកដឹងទេ ហើយដៃអាវតូចនេះយ៉ាងនេះ។ ហើយខ្ញុំចេញ ដើរទៅកាត់នោះ ត្រចៀកខ្ញុំឆេះក្តៅល។ ខ្ញុំមិនដែលនៅជិតមីក្រូហ្វូនទេ។

81 ហើយខ្ញុំអធិប្បាយលើនោះ ហើយខ្ញុំយកអត្ថបទមួយ ខ្ញុំមិនដែលភ្លេចវាឡើយ "បុរសអ្នកមាន ងើយភ្នែករបស់ខ្លួននៅស្ថាននរក រួចយំ។" ខ្ញុំ មានពេលជាច្រើន ដង អធិប្បាយរឿងបីតូចៗដូចនោះ "មក មើលបុរសម្នាក់" "អ្នកជឿរឿងនេះទេ?" ឬ "ពេលនោះគាត់ក៏យំ។" ហើយខ្ញុំបន្តនិយាយ"គ្មានផ្កា ហើយគាត់យំ។ គ្មានការ ប្រជុំអធិស្ឋានបន្ទាប់មកគាត់យំ។ គ្មានកូន ដូច្នេះគាត់យំ។ គ្មានចម្រៀង ដូច្នេះ គាត់ក៏យំ" បន្ទាប់មកខ្ញុំក៏យំ។

82 បន្ទាប់ពីវាបានចប់ទៅ ហេតុអ្វី ខ្ញុំ ពួកគេ...ទាំងអស់នៅជុំវិញខ្ញុំ ចង់អោយខ្ញុំ កាន់កាប់ការប្រជុំសម្រាប់ពួកគេ។ ហើយខ្ញុំគិត "និយាយ ប្រហែលខ្ញុំជាអ្នករ៉ូលឡឺ បរិសុទ្ធ!" ឃើញទេ? ដូច្នេះខ្ញុំគិត "ប្រហែល..." មើល ពួកគេជាមនុស្សល្អមែន។

83 ហើយខ្ញុំក្រោកដើរទៅ។ បុរសម្នាក់ស្លៀកខោ ខៅបូយ ស្បែកជើងកវែង មួកខៅ បូយធំ ខ្ញុំនិយាយ "អ្នកជានរណា?"

គាត់និយាយ "ខ្ញុំជាចាស់ទុំ *ដូច្នេះ-និង-ដូច្នេះ* គឺ មកពីតិចសាស (Texas)។"

ខ្ញុំគិត "ល្អ មើលទៅ..."

84 អ្នកមកជាមួយផ្សេងទៀត គេស្លៀកខោប៊ីធីនីកខីប៊ូកខីតូចៗទាំងនេះ អ្នក ដឹងទេពួកគេធ្លាប់លេងហ្គោលជាមួយខោនោះហើយម្នាក់ក្នុងចំណោមនោះពាក់ អាវចាក់ប៊ីធី តូចនោះ។ គាត់និយាយថា "ខ្ញុំជា គ្រូគង្វាល *ដែល-បាន-មក* ពីហ្វ្លរីដា (Florida)។ សូមចាប់ដៃមួយ..."

85 ខ្ញុំមានអារម្មណ៍ថា "ខ្ញុំនៅផ្ទះ ប្អូនប្រុសអើយ ទាំងនេះជាខោសៀសាក់ខីនិង អាវយឺតទាំងនេះ។ នោះជាការល្អណាស់។"

86 ដូច្នេះអ្នកអាចលឺពីជីវិតខ្ញុំ មកពីរឿងទាំងអស់នោះ ដូច្នេះខ្ញុំឈប់នៅទីនេះ ហើយ ខ្ញុំប្រាប់អ្នកពីអ្វីដែលមិនធ្លាប់ប្រាប់ពីមុនមក។ ទីមួយ ខ្ញុំចង់សួរអ្នក...ខ្ញុំនឹង ទៅជុំវិញទីក្រុង។ ខ្ញុំមិនធ្លាប់និយាយវាក្នុងជាសាធារណៈឡើយ ក្នុងជីវិតរបស់ខ្ញុំ។ បើអ្នកសន្យានឹងខ្ញុំថា អ្នកស្រលាញ់ខ្ញុំ ហើយព្យាយាមស្រលាញ់ខ្ញុំ បន្ទាប់ពីខ្ញុំ

និយាយរឿងនេះ ហើយដូចមុនកាលខ្ញុំនិយាយ សូមលើកដៃ។ ពិតមែនហើយ។ នេះជាការសន្យារបស់អ្នក ខ្ញុំនឹងប្រាប់អ្នកនៅក្នុងរឿងនេះ។

87 អង្គុយក្នុងការប្រជុំយប់នោះ ពេលគេចាប់ច្រៀងចម្រៀងរបស់ពួកគេ ពួកគេទះដៃ។ ហើយពួកគេច្រៀង "ខ្ញុំ..." នោះជាចម្រៀងមួយចំនួន "ខ្ញុំដឹងថាវាជាលោហិតខ្ញុំដឹងថាវាជាលោហិត។" ហើយពួកគេរត់ឡើងរត់ចុះពេញច្រកដើរ ហើយគ្រប់យ៉ាងហើយគ្រាន់តែស្រែកសសើរព្រះអម្ចាស់។ ខ្ញុំគិតថា "សម្លេងនោះពិតជាល្អខ្លាំងណាស់ចំពោះខ្ញុំ។" ខ្ញុំចាប់ផ្ដើម...

88 ហើយពួកគេសំដៅពេលទាំងអស់ទៅកាន់គម្ពីរកិច្ចការ កិច្ចការ ២:៤ កិច្ចការ២:៣៨ កិច្ចការ ១០:៤៩ គឺទាំងអស់នោះ។ ខ្ញុំគិតថា "និយាយ នោះជាខគម្ពីរ! ខ្ញុំមិនដែលឃើញដូច្នេះទេ ពីមុនមក។" ប៉ុន្តែចិត្តរបស់ខ្ញុំកំពុងតែឆេះឆួលហើយ "នេះជាការអស្ចារ្យណាស់!" ខ្ញុំគិតថាពួកគេជាក្រុមអ្នកជឿដែលគិតថាខ្លួនបរិសុទ្ធ ពេលដែលជួបពួកគេដំបូង ហើយខ្ញុំគិត "ឱ ខ្ញុំអើយ! ឥឡូវពួកគេជាក្រុមទេវតា។" ឃើញទេ ខ្ញុំដូរគំនិតខ្ញុំលឿនណាស់។

89 ដូច្នេះពេលព្រឹកឡើងពេលដែលព្រះអម្ចាស់ប្រទានឱកាសដ៏អស្ចារ្យនេះ ខ្ញុំគិត "អូ ខ្ញុំអើយ ខ្ញុំនឹងមានទំនាក់ទំនងជាមួយក្រុមអ្នកទាំងនេះ! នោះពិតជាប្រភេទអ្វីដែលគេហៅថា 'ការស្រែកនៃក្រុមរបស់មេតូឌីស។' គ្រាន់តែបន្តទៀត" ខ្ញុំគិត។ "ប្រហែលនេះជាវាហើយ។" ដូច្នេះខ្ញុំគិត "ល្អ ខ្ញុំ...ខ្ញុំគឺប្រាកដដូចនោះខ្លាំងណាស់។ អូ ជាអ្វីអំពីពួកគេដែលខ្ញុំចូលចិត្ត ពួកគេបន្ទាបខ្លួន ហើយផ្អែមល្ហែម។"

90 ដូច្នេះរឿងមួយ ដែលខ្ញុំមិនយល់គឺការនិយាយភាសាដទៃ នេះជាអ្វីខ្ញុំមាន។ ហើយខ្ញុំ...មានបុរសម្នាក់ និយាយ អង្គុយនៅ*ទីនោះ*ហើយម្នាក់នៅ*ទីនោះ* ហើយពួកគេជាអ្នកដឹកនាំក្រុម។ ម្នាក់*នេះ*ងើបឡើង ហើយនិយាយភាសាដទៃ *នេះ*នឹងបកប្រែហើយនឹងប្រាប់ពីការប្រជុំនឹងបន្តទៀត។ ខ្ញុំគិត "ខ្ញុំអើយ ខ្ញុំត្រូវតែអានអំពីសេចក្ដីនោះ!" ដូច្នេះពួកគេនឹងត្រលប់ទៅវិញទៅមក ធ្លាក់មកលើអ្នក*នេះ* រួចទៅលើអ្នក*នោះ* ម្នាក់ៗនឹងនិយាយភាសាដទៃ ឬ បកប្រែ។ អ្នកផ្សេងទៀតក្នុងក្រុម ជំនុំនិយាយ ប៉ុន្តែមិនដូចជាការបកប្រែចេញពីអ្នកទាំងពីរនាក់នោះទេ។ ឥឡូវខ្ញុំបានឃើញពួកគេអង្គុយជិតគ្នា ខ្ញុំគិត "អូ ខ្ញុំអើយ ពួកគេពិតជាទេវតា!" ដូច្នេះកាលបើអង្គុយមកវិញ...

91 តាំងពីនោះមក (អ្នកដឹងទេ) ខ្ញុំមិនអាចចេញក្រៅសោះ វានឹងមកដល់ខ្ញុំ។ ហើយខ្ញុំដឹងពីរបៀបថាតើព្រះអម្ចាស់ចង់អោយខ្ញុំស្គាល់វា អ្នកដឹងទេ។ ហើយខ្ញុំមិនបានធ្វើឡើយ...នោះជាហេតុផលដែលខ្ញុំ និយាយថាខ្ញុំមិនដកដង្ហើមចេញ គឺមិនដែលនៅទីសាធារណៈឡើយ។ បើខ្ញុំចង់រកអ្វីដែលព្រះអម្ចាស់ជាធម្មតាប្រាប់ខ្ញុំអំពីការទាំងនេះ។ នោះហើយជាអំណោយទានសម្រាប់ធ្វើ អ្នកឃើញទេ។ ដូច្នេះអ្នកមិនអាចជះវាចេញនៅមុខមនុស្សបានឡើយ វាដូចជាអ្នកបោះគុជនៅចំពោះជ្រូកដែរ។ វាជាអាថ៌កំបាំង ជាភាពបរិសុទ្ធ ហើយអ្នកមិនចង់ធ្វើដូច្នោះឡើយ។ ដូច្នេះ ព្រះជាម្ចាស់ប្រទានខ្ញុំនូវទំនួលខុសត្រូវ។ ដូចជាការនិយាយទៅកាន់បងប្អូននិង អ្នក ដទៃទៀត ខ្ញុំមិនព្យាយាមស្វែងរករឿងអាក្រក់ពីបងប្អូនឡើយ។

92 ពេលមួយអង្គុយជាមួយបុរសម្នាក់លើតុមួយ ដៃគាត់ដាក់ជុំវិញខ្ញុំ និយាយ "អូប្អូនប្រុស ប្រានហាំ ខ្ញុំស្រលាញ់អ្នក។" ហើយខ្ញុំរក្សាអារម្មណ៍ដែលកំពុងកម្រើក។ ខ្ញុំមើលទៅគាត់។ ខ្ញុំមិនអាចមានការប្រាប់មកដូច្នេះឡើយ ខ្ញុំដឹងថាគាត់មិនបានធ្វើឡើយ ឃើញទេ ព្រោះនោះគឺយ៉ាងនោះ។ គាត់ពិតជាមនុស្សកំពុត បើធ្លាប់មានម្នាក់ ឃើញទេ ហើយដៃនោះដាក់មកខ្ញុំ។

93 ខ្ញុំនិយាយ "ល្អ អូខេ" ដើរចេញ។ ខ្ញុំមិនចង់ដឹងទេ។ ខ្ញុំស្គាល់គាត់ត្រឹមតែរបៀបដែលខ្ញុំស្គាល់គាត់ ដូចជាបងប្អូនប្រុស ហើយអោយនៅតែបន្តដូច្នេះចុះ។ ចូរអោយព្រះជាម្ចាស់សម្រេចការនៅសល់។ ឃើញទេ? ហើយខ្ញុំក៏មិនចង់...មិនដឹង ចង់ស្គាល់ការទាំងនោះ។

94 ហើយមានពេលជាច្រើនពីរឿងទាំងនេះ វាមិននៅក្នុងព្រះវិហារទេ។ ខ្ញុំអង្គុយក្នុងបន្ទប់អង្គុយក្នុងភោជនីយដ្ឋានព្រះវិញ្ញាណបរិសុទ្ធប្រាប់ខ្ញុំពីរឿងនឹងកើតឡើង មនុស្សនៅទីនេះដឹងថាវាជាការពិត។ ខ្ញុំនៅផ្ទះហើយខ្ញុំនិយាយ "ឥឡូវ ចូរប្រយ័ត្ន មានឡានមួយកំពុងចូលមកប្រមាណមួយខណៈទៀត។ *វាពិតជា ពិតជាមនុស្ស*។ នាំពួកគេចូលមក ដ្បិតព្រះអម្ចាស់មានបន្ទូលថា ពួកគេនឹងមកទីនេះ។" "នៅពេលយើងទៅដល់ផ្លូវ *ពិតជា* មានរឿងនោះកើតឡើងមែន។ មើលចំណុចកាត់គ្នានៅទីនោះ ព្រោះអ្នកនឹងស្ទើរតែត្រូវរងការប៉ះទង្គិច។" ហើយមើល តើវាមិនមកអញ្ចឹងឬទេ មើល គ្រប់ពេល គឺត្រូវឥតខ្ចោះ! ដូច្នេះអ្នកមិនចាំបាច់បោះខ្លួនអ្នកពេកនោះទេ ទៅក្នុងរឿងនោះ ព្រោះអ្នក...វា—វាគឺ...អ្នកអាចប្រើវា វាជាអំណោយទានរបស់

ព្រះជាម្ចាស់ តែអ្នកត្រូវតែប្រយ័ត្ននឹងអ្វីដែលអ្នកធ្វើវា។ ព្រះជាម្ចាស់នឹងប្រទាន អ្នកជាមួយទំនួលខុសត្រូវ។

95 សូមមើលទៅម៉ូសេ។ ម៉ូសេជាមនុស្ស-ដែលបញ្ជូនមកដោយព្រះជាម្ចាស់។ អ្នកជឿទេ? ដោយតម្រូវជាមុន ចាក់ប្រេងតាំងជាមុន ហើយធ្វើអោយក្លាយជាព្យាការី! ហើយព្រះជាម្ចាស់បញ្ជូនគាត់ចេញ ដោយមានបន្ទូលថា "ចូរទៅ ហើយនិយាយទៅកាន់ដុំថ្ម" បន្ទាប់មក ក៏បានវាយរួចហើយ។ និយាយ "ទៅនិយាយទៅកាន់ដុំថ្ម ហើយវានឹងបញ្ចេញទឹកមក។"

96 ប៉ុន្តែម៉ូសេ ខឹង រត់ចេញទៅហើយវាយថ្មនោះ។ ទឹកមិនបានចេញមកទេ គាត់វាយម្តងទៀត និយាយ "អ្នកបះបោរអើយ! តើយើងត្រូវតែបញ្ចេញទឹកពីថ្មនេះមកឬ?"

97 អ្នកឃើញអ្វីដែលព្រះជាម្ចាស់បានធ្វើទេ? មានទឹកចេញមក តែទ្រង់មានបន្ទូលថា "ចេញមក ម៉ូសេ។" នេះជាពេលបញ្ចប់ ឃើញទេ។ អ្នកត្រូវតែមើលការនោះ ដូច្នេះអ្នក...អ្វីដែលធ្វើជាមួយអំណោយទាននៃព្រះជាម្ចាស់។

98 ដូចជាអ្នកអធិប្បាយម្នាក់ ជាអ្នកអធិប្បាយជម្រុញចិត្តយ៉ាងល្អ ហើយចេញទៅអធិប្បាយយកតែដង្វាយ និងប្រាក់ ព្រះជាម្ចាស់ប្រទានទំនួលខុសត្រូវដល់គាត់សម្រាប់ធ្វើការនោះ។ ជាការពិត។ អ្នកត្រូវតែប្រយ័ត្នជាមួយអំណោយទានរបស់ព្រះជាម្ចាស់។ ហើយ ឬ ព្យាយាមធ្វើអោយកិត្តិនាម ឬឈ្មោះធំសម្រាប់ព្រះវិហារ ឬ ឈ្មោះធំសម្រាប់ខ្លួនឯង។ ខ្ញុំចង់មានការប្រជុំពីរ ទៅបី យប់ភ្ជាប់នៅទីណាមួយហើយចូរបន្ទាបខ្លួនហើយកាន់អោយខ្ជាប់ខ្ជួន។ ហើយអ្នកដឹងពីអ្វីខ្ញុំនិយាយ។ បាទ លោក ចូរនៅទីណា ដែលព្រះជាម្ចាស់អាចដាក់ព្រះហស្តលើអ្នក បាន។

នេះគឺនៅក្នុងជីវិតឥឡូវ ចូរចងចាំ។

99 ដូច្នេះនៅថ្ងៃនេះ ខ្ញុំគិត "ល្អ ខ្ញុំនឹងដើរឡើងទៅ។" ហើយខ្ញុំនឹងប្រយ័ត្នជាមួយមនុស្សទាំងនោះ ខ្ញុំគិត "ខ្ញុំនឹងស្វែងយល់ពីមនុស្សទាំងនោះ។" ហើយនៅក្រៅច្បារនោះ ខ្ញុំនៅមើលពួកគេរហូតកម្មវិធីបញ្ចប់។ ខ្ញុំមើលជុំវិញ។ ខ្ញុំឃើញពួកគេម្នាក់ ខ្ញុំនិយាយ "សុខសប្បាយទេលោក?"

100 គាត់និយាយ "អ្នកសុខសប្បាយទេ!" និយាយ "អ្នកជាអ្នកអធិប្បាយវ័យក្មេងនៅព្រឹកនេះឬ?"

ខ្ញុំនិយាយ...ពេលនោះខ្ញុំមានអាយុ២៣ឆ្នាំ។ ខ្ញុំនិយាយ "បាទ លោក។"

ហើយគាត់និយាយ "អ្នកឈ្មោះអ្វី?"

ខ្ញុំនិយាយ "ប្រានហាំ។" ហើយខ្ញុំនិយាយ "អ្នកវិញ?"

101 ហើយគាត់ប្រាប់ឈ្មោះគាត់ដល់ខ្ញុំ។ ហើយខ្ញុំគិត "បាទ ឥឡូវ បើខ្ញុំអាចទាក់ទងវិញ្ញាណគាត់ឥឡូវ។" ហើយមិនទាន់ដឹងអ្វីដែលកំពុងធ្វើនោះឡើយ។ ហើយខ្ញុំនិយាយ "ល្អ និយាយ លោក" ខ្ញុំនិយាយ "អ្នកជាមនុស្សមានអ្វីនៅទីនេះដែលខ្ញុំមិនមាន។"

គាត់និយាយ "អ្នកទទួលព្រះវិញ្ញាណបរិសុទ្ធតាំងពីអ្នកជឿមកឬ?"

ខ្ញុំនិយាយ "បាទ ខ្ញុំជាបាបទីស្ទ។"

102 គាត់និយាយ "អ្នកទទួលព្រះវិញ្ញាណបរិសុទ្ធតាំងពីអ្នកជឿមក?"

103 ហើយខ្ញុំនិយាយ "ល្អ បងប្អូនប្រុស តើអ្នកមានន័យយ៉ាងណា?" ខ្ញុំនិយាយ "ខ្ញុំ—ខ្ញុំមិនមានអ្វីដែលអ្នកទាំងអស់គ្នាមានទេ ខ្ញុំដឹងដូច្នេះ!" ខ្ញុំនិយាយ "ព្រោះអ្នកមានអ្វីដែលហាក់បីដូចជាមានអំណាច ហើយពិតជា..."

និយាយ "អ្នកធ្លាប់និយាយភាសាដទៃទេ?"

ហើយខ្ញុំនិយាយ "ទេ លោក។"

និយាយ "ខ្ញុំប្រាប់អ្នកអោយរហ័សទៅថាអ្នកមិនមានព្រះវិញ្ញាណបរិសុទ្ធទេ។"

104 ហើយខ្ញុំនិយាយ "បាទ បើខ្ញុំ...បើនោះជាអ្វីដែលត្រូវទទួលព្រះវិញ្ញាណបរិសុទ្ធខ្ញុំមិនមានទេ។"

105 ដូច្នេះគាត់និយាយ "បាទ បើអ្នកមិននិយាយភាសាដទៃ អ្នកមិនទទួលវាបានឡើយ។"

106 ហើយបន្តការសន្ទនាយ៉ាងនោះទៀត ខ្ញុំនិយាយ "ល្អ ខ្ញុំអាចទទួលបាននៅឯណា?"

107 និយាយ "ទទួលវានៅក្នុងបន្ទប់នោះ ហើយចាប់ផ្ដើមស្វែងរកព្រះវិញ្ញាណបរិសុទ្ធ។"

108 ហើយខ្ញុំតាមមើលគាត់ អ្នកដឹងទេ។ គាត់មិនដឹងថា ខ្ញុំកំពុងធ្វើអ្វីទេ ប៉ុន្តែគាត់...ខ្ញុំដឹងគាត់មានអារម្មណ៍ចម្លែកបន្តិច ប៉ុន្តែគាត់...ភ្នែកគាត់ចាប់ផ្ដើមដូចជាមិនយកចិត្តទុកដាក់ការគាត់សម្លឹងមកខ្ញុំ។ ហើយគាត់...ប៉ុន្តែគាត់ពិតជា គ្រីស្ទបរិស័ទ។ គាត់ពិតណាស់ ជាគ្រីស្ទបរិស័ទ១០០ភាគរយ។ នោះជាការពិត។ មែន ខ្ញុំគិត "សរសើរព្រះអង្គ នៅទីនេះ! ខ្ញុំ—ខ្ញុំបាន—ខ្ញុំបានចូលទៅអាសនានៅកន្លែងមួយ។"

109 ខ្ញុំចេញទៅ មើលជុំវិញ ខ្ញុំគិត "ខ្ញុំនឹងរកអ្នកផ្សេងទៀត។" ហើយពេលខ្ញុំរកបានអ្នកនោះ ខ្ញុំចាប់និយាយជាមួយគាត់ ខ្ញុំនិយាយ "អ្នកសុខសប្បាយទេ លោក?"

110 គាត់និយាយ "និយាយ អ្នកជាសមាជិកក្រុមជុំនំណា?" គាត់និយាយ "ពួកគេប្រាប់ខ្ញុំថា អ្នកជាពួកបាបទីស្ទ។"

ខ្ញុំនិយាយ "បាទ។"

ហើយគាត់និយាយ "អ្នកមិនទាន់ទទួលព្រះវិញ្ញាណបរិសុទ្ធទេ មែនទេ?"

ខ្ញុំនិយាយ "មែន ខ្ញុំមិនដឹងឡើយ។"

និយាយ "អ្នកនិយាយភាសាដទៃទេ?"

ខ្ញុំនិយាយ "ទេ លោក។"

និយាយ "អ្នកមិនទាន់មានទេ។"

111 ហើយខ្ញុំនិយាយ "បាទ ខ្ញុំដឹង ខ្ញុំមិនបានទទួលអ្វីដែលអ្នកទាំងអស់គ្នាទទួលទេ។ ខ្ញុំដឹង។" ហើយខ្ញុំនិយាយ "ប៉ុន្តែ បងប្អូនអើយ ខ្ញុំពិតជាត្រូវការវា។"

គាត់និយាយ "មែន នោះ—នោះជាអាងហែលទឹក រៀបចំហើយ។"

112 ខ្ញុំនិយាយថា "ខ្ញុំបានជ្រមុជទឹក។ ប៉ុន្តែ" ខ្ញុំនិយាយទៀតថា "ខ្ញុំ—ខ្ញុំមិនបានទទួលអ្វីទាំងអស់ដែលអ្នកបានទទួលទេ" ខ្ញុំនិយាយ "អ្នកបានទទួលអ្វីមួយដែលខ្ញុំ—ខ្ញុំពិតជាចង់បានមែនទែន។"

ហើយគាត់និយាយ "មែន នោះជាការល្អ។"

113 ខ្ញុំព្យាយាម ចាប់គាត់ អ្នកឃើញទេ។ ហើយបើខ្ញុំ...ទទួលវិញ្ញាណ នេះនៅទីបំផុតឥឡូវ នោះមានបុរសម្នាក់ទៀត ថាតើខ្ញុំធ្លាប់និយាយទៅកាន់មនុស្សកំពុត នោះ គឺជាម្នាក់ក្នុងចំណោមពួកគេហើយ។ គាត់កំពុងរស់នៅ...ជាមួយ ប្រពន្ធជាមនុស្សក្បាលខ្មៅ គាត់កំពុងរស់នៅជាមួយអ្នកសក់ពណ៌ទង់ដែង និងមានកូនពីរនាក់ជាមួយនាងនោះ។ ផឹក ជេរ នៅតៀមស្រា និងផ្សេងៗទៀត ហើយតែនៅក្នុងនោះនិយាយភាសាដទៃ និងថ្លែងទំនាយ។

114 បន្ទាប់ខ្ញុំនិយាយ "ព្រះអម្ចាស់ សូមអត់ទោសទូលបង្គំផង" ខ្ញុំទៅផ្ទះ។ នោះត្រូវហើយ។ ខ្ញុំនិយាយ "ខ្ញុំទើបទទួល...ខ្ញុំមិនអាចយល់បានទេ។ ហាក់ដូចជាព្រះពរព្រះវិញ្ញាណបរិសុទ្ធធ្លាក់មក លើមនុស្សកំពុត។" ខ្ញុំនិយាយ "មិនអាច! នោះគឺចប់ហើយ។"

115 ខណៈពេលដ៏យូរនេះ ខ្ញុំរៀន និងយំ ព្រមទាំងបានគិតថា បើខ្ញុំអាចចេញទៅជាមួយគេ ប្រហែលខ្ញុំអាចរកឃើញនោះជាអ្វីដែលបាននិយាយអំពី។ មានម្នាក់ជាគ្រីស្តបរិស័ទជាក់ច្បាស់ ហើយអ្នកផ្សេងទៀតក៏ជាជនកំពុតដែរ។ ដូច្នេះខ្ញុំគិត "នោះជាអ្វី? អូ" ខ្ញុំនិយាយ "ព្រះអើយ ប្រហែល—ប្រហែលមានអ្វីខុសជាមួយទូលបង្គំ។" ហើយខ្ញុំនិយាយ ជាអ្នកមូលដ្ឋានគ្រឹះនិយម "នោះនឹង...ត្រូវឃើញក្នុង ព្រះគម្ពីរ។ វាត្រូវតែដូច្នេះ។"

116 ចំពោះខ្ញុំ គ្រប់យ៉ាងដែលធ្វើឡើងត្រូវតែចេញពីព្រះគម្ពីរ បើមិនដូច្នេះទេ វាមិនត្រូវឡើយ។ ត្រូវតែចេញមកពីនេះ។ វាអាចបង្ហាញតាមព្រះគម្ពីរ មិនមែនចេញពីកន្លែងតែមួយនោះទេ ប៉ុន្តែវាត្រូវតែចេញមកពីព្រះគម្ពីរ។ ខ្ញុំជឿវាយ៉ាងដូច្នេះ។ វាត្រូវតែស៊ីគ្នាហើយចងភ្ជាប់ជាមួយរាល់ខគម្ពីរ បើមិនដូច្នេះខ្ញុំមិនជឿទេ។ ហើយព្រោះតែប៉ូលនិយាយ "ទោះទេវតាមកពីស្ថានសួគ៌ ប្រកាសដំណឹងល្អផ្សេងទៀត ចូរអោយត្រូវបណ្តាសារចុះ។" ដូច្នេះខ្ញុំជឿដល់ព្រះគម្ពីរ។

ហើយខ្ញុំនិយាយ "ខ្ញុំមិនអាចឃើញអ្វីដូចនៅក្នុងព្រះគម្ពីរឡើយ។"

117 ពីរឆ្នាំក្រោយមក បន្ទាប់ពីខ្ញុំបាត់បង់ប្រពន្ធខ្ញុំ និងអ្វីៗគ្រប់យ៉ាង ខ្ញុំនៅគ្រីនមីល (Green's Mill) ជាកន្លែងតូចចាស់របស់ខ្ញុំ គឺនៅទីនោះ អធិស្ឋាន។ ត្រលប់ទៅល្អាងរបស់ខ្ញុំវិញនៅទីនោះប្រហែលពីរ ឬ បីថ្ងៃកន្លងទៅ វាគឺពីរថ្ងៃហើយ។ ខ្ញុំដើរចេញទៅដើម្បីរកដង្ហើមបន្តិច ដង្ហើមខ្យល់។ ពេលខ្ញុំដើរចេញទៅទីនោះ ព្រះគម្ពីររបស់ខ្ញុំទុកនៅទីនោះលើឈើដូចអ្នកចូលមកអញ្ជឹង។ ដើមឈើចាស់

មួយដួលចុះមានជំពាមនៅទីនោះ។ ឥឡូវ អ្នក...មាន ជំពាម នៅពីមុខដូច*នេះ* ដើមឈើផ្តេកចុះ។ ហើយខ្ញុំប្រកគាវលើឈើនោះ ហើយដេកទីនោះពេញមួយយប់ មើលមេឃដូច*នេះ* ដៃរបស់ខ្ញុំដាក់បែប*នេះ*ហើយជួនកាលដេកលក់ដេកលើឈើយ៉ាង*នេះ* ហើយជួនកាលដេកលក់ដេកលើឈើយ៉ាង*នោះ* អធិស្ឋាន។ នៅទីនោះពីរបីថ្ងៃ មិនបរិភោគ មិនហូប ឬផឹកផង នៅតែអធិស្ឋាន។ ហើយខ្ញុំដើរចេញទៅក្រៅ ដើម្បីទទួលខ្យល់ស្រស់ នៅក្រៅល្អាង នៅទីនោះត្រជាក់សើម។

118 ដូច្នេះបន្ទាប់មកខ្ញុំចេញក្រៅ ហើយទុកគម្ពីរព្រះគម្ពីរកន្លែងបានដាក់ពីម្សិល ហើយក៏ត្រលប់ទៅហោព្រើរ ជំពូក៦។ ហើយខ្ញុំផ្តើមអានវា "ចូរយើងទុកសិន... លើ...បន្តទៅកន្លែងឥតខ្ចោះ មិនមែនផ្តេកម្តងទៀត លើគ្រឹះការកែប្រែចិត្ត និងកិច្ចការដែលស្លាប់ និងមានជំនឿ ចំពោះព្រះជាម្ចាស់" ហើយបន្ត។ "វាមិនអាចទៅរួចទេ ចំពោះការទាំងនោះដែលធ្លាប់បំភ្លឺម្តងហើយ អ្នកចូលរួមនៃអំណោយទានស្ថានសួគ៌ និងការត្រាស់ហៅ" ហើយបន្ត។ ប៉ុន្តែនិយាយ "ប៉ុន្តែបន្លា និងដើមបន្លាក្បែរនោះចំពោះការបដិសេធ ចុងបញ្ចប់...ទឹក...ភ្លៀងមករឿយៗលើផែនដី ដើម្បីតុបតែងវា និងរៀបចំវាសម្រាប់អ្វីដែលជា—ជាក្បែរនឹងការបដិសេធដែរ ជាមួយបន្លា និងដើមបន្លា ការបញ្ចប់របស់វាគឺត្រូវបញ្ឆេះ។"

ហើយមានអ្វីកើតឡើង "វ៉ូសៗៗៗៗ!"

119 ខ្ញុំគិត "នេះហ្នែ។ ខ្ញុំនឹងលឺពីអ្វីដែលគាត់...គាត់ដាស់ខ្ញុំអោយភ្ញាក់នៅទីនោះ គាត់រៀបចំអោយខ្ញុំនូវនិមិត្តមួយឥឡូវនេះ។" ខ្ញុំចាំទីនោះនៅចុងគល់ឈើ ហើយចាំ។ ខ្ញុំក្រោកហើយដើរទៅវិញទៅមកឡើងចុះ។ ដើរត្រលប់ គ្មានអ្វីកើតឡើង។ ដើរត្រលប់ទៅល្អាងវិញ គ្មានអ្វីកើតឡើងទៀត។ ខ្ញុំឈរទីនោះ ខ្ញុំគិត "បាទ នេះជាអ្វី?"

120 ខ្ញុំដើរទៅកាន់ព្រះគម្ពីរខ្ញុំម្តងទៀត ហើយអូ ខ្ញុំបានឃើញព្រះគម្ពីរម្តងទៀតហើយ។ ខ្ញុំរើសឡើង ហើយគិត "តើមានអ្វីនោះដែលទ្រង់ចង់អោយខ្ញុំអាន?" ខ្ញុំបន្ត នៅអានទៅក្រោមអំពី "ការកែប្រែចិត្តចំពោះព្រះជាម្ចាស់ និងជំនឿ" ហើយបន្ត ហើយអានអាចចុះក្រោមមកកន្លែងដែលនិយាយថា "ភ្លៀងធ្លាក់មកញយៗលើផែន ដី ដើម្បីតុបតែង និងរៀបចំវាសម្រាប់អត្ថន័យនៃការនោះ នៅទីនេះ ប៉ុន្តែបន្លា និងដើមបន្លាដែលនៅក្បែរនឹងការបដិសេធនឹងត្រូវដុតចោល។" ហើយ អូ វាដូចជាអង្រួនខ្ញុំអញ្ចឹង!

121 ហើយខ្ញុំគិត "ព្រះអម្ចាស់ តើទ្រង់នឹងប្រទាននិមិត្តអ្វីមកទូលបង្គំ..." ខ្ញុំទៅទីនោះដើម្បីសួរទ្រង់ពីអ្វីផ្សេងទៀត។

122 ដូច្នេះអ្វីទាំងអស់ នៅពីមុខខ្ញុំ ខ្ញុំឃើញពិភពលោកវិល ហើយវាជាថាសមូលផ្ទា។ ហើយទីនោះមានមនុស្សស្បែកសម្នាក់ ក្បាលងើបឡើង ព្រោះគ្រាប់ពូជដូចនេះ។ ហើយពេលលោកទៅណាមកណា គឺដូចជាលោកទៅលើភ្នំអញ្ចឹង ទីនេះក៏មានបុរសម្នាក់ ទៀតមកពីក្រោយលោក ស្លៀកខ្មៅដោយអោនក្បាលចុះ ព្រោះគ្រាប់ពូជ។ ហើយ ពេលគ្រាប់ពូជល្អដុះឡើង វាជាស្រូវសាឡី ហើយពេលគ្រាប់ពូជអាក្រក់ដុះឡើងវាជាស្រងែ។

123 ហើយក៏មានភាព រាំងស្ងួតនៅលើផែនដី ហើយស្រូវសាឡីមានក្បាលងើយឡើង ស្ទើរតែអន្តរាយ ព្រោះត្រូវការទឹក។ ហើយខ្ញុំបានឃើញមនុស្សទាំងអស់លើកដៃឡើងអធិស្ឋានទៅព្រះជាម្ចាស់អោយទ្រង់បញ្ជូនទឹកភ្លៀងមក។ ហើយខ្ញុំឃើញស្រងែអោនចុះ អោនរកទឹក។ ហើយបន្ទាប់មក ក៏មានពពកធំចូលមកហើយភ្លៀងក៏បង្អុរចុះ។ ពេលនោះ ស្រូវសាឡីតូចៗដែលដួលទាំងអស់ "សម្លេងរីសៗ" ក្រោកត្រង់ឡើង។ ស្រងែតូចៗនៅឯម្ខាងទៀត "សម្លេងរីសៗ" ក៏ឈរឡើងដែរ។

ខ្ញុំគិត "មែន នោះជាអ្វី?"

124 ពេលខ្ញុំត្រលប់មកខ្លួនឯងវិញ។ នោះក៏យ៉ាងនោះមែន។ ភ្លៀងដូចគ្នាដែលធ្វើអោយស្រូវសាឡីដុះ ហើយក៏ធ្វើអោយស្រងែដុះដែរ។ ហើយព្រះវិញ្ញាណបរិសុទ្ធអាចធ្លាក់លើពួកមនុស្ស ហើយអាចប្រទានពរមនុស្សកំពុតដូចប្រទានពរដល់អ្នកដទៃ។ព្រះយេស៊ូវមានបន្ទូល "ដោយផលផ្លែរបស់គេអ្នកនឹងស្គាល់ពួកគេ។" ចំណាំមិនថាគេស្រែក ឬគេរីករាយ ប៉ុន្តែ "ដោយផលផ្លែរបស់គេ អ្នកនឹងស្គាល់គេ។"

125 ខ្ញុំនិយាយ "អ្នកនៅទីនេះ!" "ខ្ញុំយល់ហើយ ព្រះអម្ចាស់អើយ។" ខ្ញុំនិយាយ "ដូច្នេះនោះពិតជាសេចក្តីពិត។" មនុស្សនេះ...ទ្រង់អាចប្រទានអំណោយទាន ទោះគេមិនស្គាល់ព្រះជាម្ចាស់ក៏ដោយ។

126 ដូច្នេះខ្ញុំ—ខ្ញុំរិះគន់ពេកលើការនិយាយភាសាដទៃ អ្នកឃើញទេ។ ប៉ុន្តែថ្ងៃមួយបន្ទាប់មក ព្រះជាម្ចាស់បង្ហាញអោយឃើញថា ខ្ញុំត្រូវមែន!

127 ខ្ញុំធ្វើបុណ្យជ្រមុជទឹកនៅទន្លេ នៅទន្លេអូហាយ៉ូ សម្រាប់អ្នកជឿថ្មី ពេលខ្ញុំជ្រមុជទឹកអោយអ្នកទី១៧ ដូចដែលខ្ញុំបានចាប់ផ្តើមជ្រមុជដំបូង ខ្ញុំនិយាយ "ព្រះវរបិតា ដោយទូលបង្គំជ្រមុជទឹកដល់គេ សូមទ្រង់ជ្រមុជគេដោយព្រះវិញ្ញាណបរិសុទ្ធ។" ខ្ញុំចាប់ផ្តើម—ដាក់គេចូលក្នុងទឹក។

128 ហើយពេលនោះខ្យល់គួចមកពីលើមេឃ ហើយក៏មានពន្លឺភ្លឺចែងចាំងមក។ មានមនុស្សរាប់រយនាក់នៅឯឆ្នេរនាម៉ោង២រសៀល ខែមិថុនា។ ហើយវាក៏រាលដាលដល់កន្លែងដែលខ្ញុំនៅ។ សម្លេងនិយាយចេញពីទីនោះ ហើយនិយាយថា "ដូចជាយ៉ូហានបាបទីស្ទដែលត្រូវបញ្ជូនមកជាដំណើរ មុនការមកដល់លើកទីមួយរបស់ព្រះយេស៊ូវ អ្នកនឹងទទួល...សារដែលនឹងនាំដំណើរមុន នៃការយាងមក ជា លើកទីពីរ។" ហើយវាដូចជាបន្លាចខ្ញុំទៅរកសេចក្តីស្លាប់អញ្ចឹង។

129 ហើយខ្ញុំត្រលប់មកវិញ ហើយមនុស្សទាំងអស់នៅទីនោះ អ្នក—អ្នកអ្នកធ្វើការខាងស្លលោហធាតុ ហើយពួកឱសថការី ហើយពួកគេទាំងអស់នៅឆ្នេរ។ ខ្ញុំបានជ្រមុជទឹកអោយពួកគេពីប្រហែល២០០ ទៅ៣០០នាក់នៅល្ងាចនោះ។ ហើយពេលពួកគេយកខ្ញុំចេញ ទាញខ្ញុំចេញពីទឹកមកពួកចាស់ទុំបានឡើងទៅ ពួកគេសួរខ្ញុំ និយាយថា "តើពន្លឺនោះមានន័យយ៉ាងណា?"

130 ក្រុមមនុស្សយ៉ាងធំមកពីព្រះ—ព្រះវិហារហ្គិល អេជ បាបទីស្ទ (Gilt Edge Baptist) និងព្រះវិហាឡូនស្តារ (Lone Star) នៅទីនោះ ហើយពួកគេជាច្រើននៅទីនោះ ពួកគេចាប់ផ្តើមស្រែក ពេលគេឃើញរឿងនោះកើតឡើង គឺមានមនុស្សដួល។

131 ក្មេងស្រីម្នាក់ ដែលខ្ញុំព្យាយាមយកចេញពីទូក អង្គុយទីនោះពាក់អាវងូតទឹកជាគ្រូថ្ងៃអាទិត្យក្នុងព្រះវិហារ ហើយខ្ញុំនិយាយ "អ្នកមិនចេញមកទេឬអី ម៉ាជី (Margie)?"

នាងនិយាយ "ប៊ីលលី ខ្ញុំមិនបាច់ចេញទេ។"

132 ខ្ញុំនិយាយ "ត្រូវហើយ អ្នកមិនចាំបាច់ទេ ប៉ុន្តែខ្ញុំមានការគោរពគ្រប់គ្រាន់សម្រាប់ដំណឹងល្អ ដើម្បីចេញពីកន្លែងដែលខ្ញុំជ្រមុជទឹក។"

នាងនិយាយ "ខ្ញុំមិនបាច់ចេញនោះទេ។"

133 ហើយពេលនាងនៅទីនោះ នាងសើចកក្អឹក និងសើចចំពោះខ្ញុំដែលជ្រមុជទឹក ព្រោះនាងមិនជឿលើការជ្រមុជទឹកឡើយ ដូច្នេះពេលទេវតារបស់ព្រះម្ចាស់យាងចុះមក នាងត្រូវបានបោះចូលក្នុងទូក។ បច្ចុប្បន្នក្មេងស្រីនេះនៅក្នុងមន្ទីរពេទ្យវិកលចរិក។ ដូច្នេះ អ្នកមិនអាចលេងជាមួយព្រះជាម្ចាស់ឡើយ។ ឃើញទេ? ឥឡូវ បន្តទៀត... ក្មេងស្រីស្អាតម្នាក់ បានចេញទៅផឹក ក៏ត្រូវទទួលការវាយដោយដប ដោយ—ដោយដបស្រាបៀ មុតលើមុខរបស់នាង។ អូ នាងក្លាយជាមនុស្សមើល ទៅគួរអោយញញើត! ហើយនោះជារឿងពិតដែលបានកើតឡើង។

134 ហើយតាមខ្សែដំណើរជីវិតខ្ញុំចុះមក ខ្ញុំឃើញថា ឃើញថាមានចលនា ឃើញថានិមិត្ត របៀបដែលការទាំងនោះកើតឡើង។ ក្រោយបន្តិចមក វាចាប់រំខានខ្ញុំខ្លាំងណាស់ហើយគ្រប់គ្នាប្រាប់ខ្ញុំថា វាជារឿងខុស។ ហើយខ្ញុំចេញទៅទន្រ្ទាំជើងលើដីម្តងទៀត នៅកន្លែងដែលខ្ញុំតែងអធិស្ឋាន។ ហើយខ្ញុំ...មិនថាបញ្ហាប៉ុណ្ណាទេ ខ្ញុំនៅជាប់នឹងការអធិស្ឋាន សុំកុំអោយការនោះចូលដល់ខ្ញុំ តែទោះជាយ៉ាងណាវានៅតែមក។ ហើយដូច្នេះខ្ញុំគ្រាន់តែ...ខ្ញុំគឺ—ខ្ញុំគឺជាមេព្រៃក្នុងរដ្ឋអិនឌៀអាយណា (Indiana)។ ហើយខ្ញុំចូលមក មានមនុស្សម្នាក់អង្គុយទីនោះ ជាមួយប្អូនអ្នកលេងព្យាណូក្នុងរោងឧបោសថ។ ហើយគាត់និយាយ "ប៊ីលលី (Billy) តើអ្នកនឹងឡើងទៅម៉ាឌីសុន (Madison) ជាមួយខ្ញុំនៅថ្ងៃនេះទេ?"

ខ្ញុំនិយាយ "ខ្ញុំមិនអាចទៅបានទេ ខ្ញុំត្រូវទៅក្នុងព្រៃ។"

135 ហើយខ្ញុំ...គ្រាន់តែមកផ្ទះ ដោះខ្សែក្រវ៉ាត់ចេញ ក្រវ៉ាត់កាំភ្លើង និងរបស់របរ ហើយមូរដៃអាវ។ យើងរស់នៅក្នុងផ្ទះតូចមួយមានបន្ទប់ពីរ ហើយខ្ញុំបានសំអាត និងរៀបអាហារទទួលទានរួចហើយ។ ហើយខ្ញុំសំអាត ហើយដើរជុំវិញផ្ទះ ក្រោមដើម—ដើមម៉ាបភល ហើយនោះមានអ្វីមួយចេញមក "វ៉ូសៗៗ!" ហើយស្ទើរតែសន្លប់ទៅហើយ។ ហើយខ្ញុំមើល ហើយខ្ញុំដឹងថា វាម្តងទៀតហើយ។

136 ខ្ញុំចាប់តាំងជំហាន ហើយគាត់លោតចេញពីឡាន និងរត់មករកខ្ញុំ និយាយ "ប៊ីលលី អ្នកសន្លប់ហើយឬ?"

ខ្ញុំនិយាយ "មិនអីទេ លោក។"

គាត់និយាយ "មានរឿងអ្វីឬ ប៊ីលលី?"

137 ហើយខ្ញុំនិយាយ "ខ្ញុំមិនដឹងដែរ។" ខ្ញុំនិយាយ "ទៅចុះបងប្រុស មិនអីទេ អរគុណ។"

138 ប្រពន្ធខ្ញុំចេញមក ហើយយកទឹកមួយផ្តិល នាងនិយាយ "បងសម្លាញ់ មានរឿងអ្វី?"

ខ្ញុំនិយាយ "មិនមានអីទេ អូនសម្លាញ់។"

139 ដូច្នេះនាងនិយាយ "មកឥឡូវ ហូបអាហារពេលល្ងាចហើយឬនៅ" ហើយនាងដាក់ដៃនាងជុំវិញខ្លួនខ្ញុំ ព្យាយាមនាំខ្ញុំចូលទៅក្នុង។

140 ខ្ញុំនិយាយ "អូនសម្លាញ់ បង—បងចង់ប្រាប់អូនរឿងខ្លះ។" ខ្ញុំនិយាយ "អូនហៅពួកគេមក និងប្រាប់គេថា បងមិនទៅទេល្ងាចនេះ។" ខ្ញុំនិយាយ "មេដា (Meda) ជាទីស្រលាញ់។" ខ្ញុំនិយាយ "បងដឹងថាក្នុងចិត្តបងស្រលាញ់ព្រះយេស៊ូវគ្រីស្ទ។ បងដឹងថា បងឆ្លងពីសេចក្តីស្លាប់មកឯជីវិត។ ប៉ុន្តែបងមិនចង់អោយអារក្ស ធ្វើអ្វីក្នុងជីវិតបងទេ។" ហើយខ្ញុំនិយាយ "ខ្ញុំមិនអាចបន្តជីវិត ខ្ញុំដូច្នេះទេ ខ្ញុំដូចជា អ្នកទោស។" ខ្ញុំនិយាយ "នៅពេលការទាំងនេះនៅតែបន្តកើត ឡើង រឿងដូច្នេះ ហើយនិមិត្តនេះចូលមក ហើយបន្តដូច្នេះ។ ឬ វាជាអ្វីក៏ ដោយ" ខ្ញុំនិយាយ "វាកើតឡើងចំពោះខ្ញុំ។" ខ្ញុំមិនដឹងថា វាជានិមិត្តឡើយ។ ខ្ញុំក៏មិនហៅវាថាជានិមិត្តដែរ។ "នោះជាការលង់ស្មារតី" ខ្ញុំនិយាយ "បងមិនស្គាល់វាជាអ្វីទេ។ ហើយ អូនសម្លាញ់ បង—បង—បង—បងមិនចង់វង្វេងជាមួយរឿងនេះឡើយពួកគេ—ពួក គេប្រាប់បងថាវាជាអារក្ស។ ហើយបងស្រលាញ់ព្រះអម្ចាស់យេស៊ូវ។"

141 "អូ" នាងនិយាយ "ប៊ីលលី បងមិនគួរស្តាប់អ្វីដែលមនុស្សនោះប្រាប់បងឡើយ។"

142 ខ្ញុំនិយាយ "ប៉ុន្តែ អូនសម្លាញ់ មើលទៅអ្នកអធិប្បាយដទៃទៀត។" ខ្ញុំនិយាយ "បង—បង មិនត្រូវការវាទេ។" ខ្ញុំនិយាយ "បងទៅកន្លែងបងក្នុងព្រៃវិញ។ បងមានលុយប្រហែល១៥ដុល្លារ អូនថែទាំប៊ីលលី ផង។" ប៊ីលលី ជាក្មេងប្រុសតូចមួយពេលនោះ ក៏ជាមិត្តតូចដែល។ ខ្ញុំនិយាយ "អូន—អូនយក...នោះជាការគ្រប់គ្រាន់ហើយសម្រាប់អូន និងប៊ីលលី រស់នៅមួយរយៈ។ ហៅពួកគេមក ហើយប្រាប់ពួកគេថា បងនឹង—បងនឹងប្រហែលត្រលប់មកថ្ងៃស្អែក ហើយក៏ប្រហែលមិនត្រលប់មកវិញផង។ បើបងមិនមកវិញនៅប្រាំថ្ងៃក្រោយមក រក

មនុស្សផ្សេង ជំនួសបងចុះ។" ហើយខ្ញុំនិយាយ "មេដា (Meda) បងនឹងមិនចេញពីព្រៃរហូតព្រះជាម្ចាស់សន្យានឹងបងថា ទ្រង់នឹងយកការនោះចេញ ពីបងមិនអោយវាកើតឡើងម្តងទៀតឡើយ។" គិតពីការមិនដឹងមិនឮ ថាមនុស្សនេះជាយ៉ាងណាចុះ!

143 ហើយខ្ញុំឡើងទៅយប់នោះ។ ត្រលប់ទៅបន្ទប់តូចចាស់ ជាថ្ងៃបន្ទាប់ពេលនោះរាងយឺតបន្តិច។ ខ្ញុំត្រូវទៅជំរំរបស់ខ្ញុំនៅថ្ងៃបន្ទាប់ ឡើងទៅ...ឆ្ងាយនៅលើភ្នំ ឬ កូនភ្នំ គឺ ទៅព្រៃដែលនៅទីនោះ។ ខ្ញុំមិនជឿថា អេហ្វ.ប៊ី.អាយ (F.B.I) អាចរកខ្ញុំឃើញនៅទីនោះទេ។ ដូច្នេះនៅក្នុងខ្ទមងងឹតតូចនោះ...ខ្ញុំបានអធិស្ឋានពេញមួយរសៀលនោះ ព្រោះថាងងឹតជ្រុលទៅហើយ។ ខ្ញុំអធិស្ឋាន ក៏អានព្រះគម្ពីរដែលត្រង់នោះ និយាយថា "វិញ្ញាណរបស់ព្យាការីនឹងអាស្រ័យលើព្យាការីនោះ។" ខ្ញុំមិនអាចចេញមកក្រៅបាន។ ដូច្នេះវាគឺងងឹតណាស់ក្នុងខ្ទមនោះ។

144 កន្លែងខ្ញុំធ្លាប់ដាក់អន្ទាក់ ពេលខ្ញុំនៅជាក្មេង ក៏នៅមានខ្សែអន្ទាក់នៅទីនោះនៅឡើយ ខ្ញុំឡើងទៅទីនោះ ហើយស្នូចត្រី ទាំងនៅទីនោះមួយយប់។ ខ្ទមចាស់ទ្រុឌទ្រោមមានអាយុកាលជាច្រើនឆ្នាំមកហើយ។ ប្រហែលជាធ្លាប់មានអ្នកជួលនៅទីនោះផងពីមុនមក។

145 ហើយខ្ញុំ—ខ្ញុំចាំនៅទីនោះ។ ខ្ញុំគិត "ល្អ។" បន្តដល់ម៉ោងមួយ ម៉ោងពីរ ម៉ោងបីពេលព្រឹក ខ្ញុំដើរលើចុះឡើងឥដ្ឋ ដើរទៅដើរមក។ ខ្ញុំអង្គុយបន្តិចលើជើងម៉ាចាស់តូចមួយនៅទីនោះតូច...មិនមែនជាជើងម៉ាទេ ជាប្រអប់ម៉្យាងតូចចាស់មួយ។ ហើយខ្ញុំអង្គុយទីនោះហើយខ្ញុំគិត"ឱព្រះជាម្ចាស់ ហេតុអ្វីទ្រង់ធ្វើការនេះចំពោះទូលបង្គំ?" ខ្ញុំនិយាយ "ព្រះបិតាទ្រង់ជ្រាបទេថាទូលបង្គំស្រឡាញ់ទ្រង់។ ទ្រង់ជ្រាបហើយថាទូលបង្គំ ស្រលាញ់ទ្រង់! ហើយទូលបង្គំ—ទូលបង្គំ—ទូលបង្គំមិនចង់អោយអារក្សឃុំទូលបង្គំឡើយ។ ទូលបង្គំមិនចង់អោយរឿងនេះកើតឡើងចំពោះទូលបង្គំឡើយ។ សូមព្រះអង្គ កុំអោយវាកើតឡើងចំពោះទូលបង្គំឡើយ។"

146 ខ្ញុំនិយាយ "ទូលបង្គំ—ទូលបង្គំស្រឡាញ់ទ្រង់។ ទូលបង្គំមិនចង់ទៅស្ថាននរកឡើយ។ អ្វីជាប្រយោជន៍ដល់ទូលបង្គំដែលអធិប្បាយនិងព្យាយាមហើយដាក់ ការប្រឹងប្រែងទូលបង្គំនោះបើទូលបង្គំមានកំហុស? ហើយទូលបង្គំក៏មិននាំតែទូល បង្គំ ទៅស្ថាននរកឡើយ ទូលបង្គំដឹកនាំមនុស្សដទៃរាប់ពាន់នាក់ខុសដែរ។" ឬ រាប់រយនាក់ក្នុងជីវិតរបស់គេ។ ហើយ ខ្ញុំនិយាយ...ខ្ញុំមានព័ន្ធកិច្ចធំ

មួយ។ ហើយខ្ញុំ និយាយ "ពិតមែនហើយ ខ្ញុំ—ខ្ញុំមិនដែលចង់អោយវាកើតឡើងម្តងទៀតទេ។"

147 ហើយខ្ញុំអង្គុយលើជើងម៉ា។ ហើយគ្រាន់តែអង្គុយនោះ អូ អង្គុយរបៀបយ៉ាងនេះ គឺយ៉ាង*នេះ*ឯង។ ហើយក្នុងពេលនោះ ខ្ញុំឃើញពន្លឺភ្លឺបភ្លែតក្នុងបន្ទប់។ ហើយខ្ញុំគិត មាននរណាម្នាក់ មកដោយយកពិលមកជាមួយ។ ហើយខ្ញុំមើលជុំវិញ ហើយខ្ញុំគិត"ល្អ..."ហើយវានៅទីនេះ នៅពីមុខខ្ញុំ។ បន្ទះក្តាឈើចាស់លើឥដ្ឋ។ ហើយវានៅទីនោះ នៅមុខខ្ញុំ។ វាជាចង្ក្រានចាស់នៅកៀនជ្រុង ដាច់ក្បាលចេញហើយ។ ហើយ—ហើយនៅទី*នេះ* មាន—មានពន្លឺលើឥដ្ឋហើយខ្ញុំគិត"ល្អ នោះ ជាអ្វី? ល្អ នោះមិនគួរចេញមកសោះ..."

148 ខ្ញុំមើលជុំវិញ។ ហើយនៅពីលើខ្ញុំ នោះ*មាន*ពន្លឺដូចគ្នា នៅពីលើខ្ញុំ នៅព្យូរដូច*នោះ*។ ព័ទ្ធជុំវិញដូចជាភ្លើង វាមានពណ៌ប្រភេទជាត្បូងមរកត បន្ត "វ៉ូសៗៗ វ៉ូសៗៗ វ៉ូសៗៗ!" យ៉ាងដូចនោះ នៅលើវានោះ ដូចនោះ។ ហើយខ្ញុំមើលទៅនោះ។ ខ្ញុំគិត "នោះជាអ្វី?" ឥឡូវ វាធ្វើអោយខ្ញុំខ្លាចហើយ។

149 ខ្ញុំលឺមានអ្នកចូលមក [បងប្រុសប្រានហាំ ធ្វើត្រាប់ម្នាក់ដែលដើរ—Ed។] គ្រាន់តែដើរប៉ុណ្ណោះ គឺដើរជើងទទេ។ ហើយខ្ញុំបានឃើញជើងរបស់មនុស្សម្នាក់ចូលមក។ នៅក្នុងបន្ទប់នោះងងឹតទាំងអស់ ប៉ុន្តែទីនេះមានពន្លឺភ្លឺចុះមក។ ហើយខ្ញុំឃើញជើងមនុស្សកំពុងចូលមក។ ពេលគាត់ចូលមកដល់បន្ទប់ ដើរឡើងមកគាត់ជាមនុស្សប្រហែល...មើលទៅមានទំងន់ ប្រហែល២០០ផោន។ គាត់អោបដៃយ៉ាង*នេះ*។ ឥឡូវ ខ្ញុំបានឃើញថា វានៅក្នុងខ្យល់គួច ខ្ញុំបានលឺពាក្យនិយាយមកកាន់ខ្ញុំ ហើយឃើញវាជាទម្រង់ពន្លឺ ប៉ុន្តែជាពេលដំបូងខ្ញុំបានឃើញទម្រង់នោះ។ វាបានដើរមករកខ្ញុំកាន់តែជិត។

150 ល្អ មិត្តស្មោះត្រង់អើយ ខ្ញុំ—ខ្ញុំគិតថាបេះដូងរបស់ខ្ញុំធ្វើអោយខ្ញុំបរាជ័យ។ ខ្ញុំ...គ្រាន់តែស្រម៉ៃ! ដាក់ខ្លួនអ្នកនៅទីនោះ ខ្ញុំធ្វើអោយអ្នកមានអារម្មណ៍ដូចគ្នា។ អ្នកប្រហែលធ្វើជាឪពុកយូរជាងខ្ញុំផង ប្រហែលជាក្លាយជាគ្រិស្ទានយូរជាងខ្ញុំផង ប៉ុន្តែវាធ្វើអោយអ្នកមានអារម្មណ៍បែបនោះ។ ព្រោះបន្ទាប់ពីការចូលមករាប់រយដង វាបានធ្វើអោយខ្ញុំក្លាយជាពិការពេលដែលបានមកជិតខ្ញុំ។ វាជួនកាល វាធ្វើអោយខ្ញុំ...ខ្ញុំស្ទើរតែសន្លប់ផង គ្រាន់តែខ្សោយ ពេលខ្ញុំចេញពីវេទិកាជាច្រើនដង។ បើខ្ញុំនៅយូរ ខ្ញុំនឹងស្លាប់ទាំងស្រុង។ ខ្ញុំធ្លាប់ឲ្យគេដឹកខ្ញុំរយៈពេលជាច្រើន

ម៉ោង ខ្ញុំមិនដឹងថាខ្លួនខ្ញុំនៅឯណាផង។ ហើយខ្ញុំមិនអាចពន្យល់វាដែរ។ អាន នៅក្នុងព្រះគម្ពីរ ខ្ញុំនឹងពន្យល់វា ថាវាជាអ្វី។ ខគម្ពីរនិយាយដូច្នេះ!

151 ដូច្នេះខ្ញុំអង្គុយទីនោះ និងមើលទៅគាត់។ ខ្ញុំ—ខ្ញុំលើកដៃដូចយ៉ាងនេះ។ គាត់សម្លឹងមើលខ្ញុំដោយរីករាយ។ ប៉ុន្តែគាត់មានសម្លេងធំគាត់និយាយ "កុំខ្លាច ខ្ញុំជាអ្នកដែលត្រូវបានបញ្ជូនមកពីវត្តមាននៃព្រះដ៏ព្រះចេស្តា។" ហើយនៅពេល ដែល សម្លេងនោះបន្លឺឡើង សម្លេងនោះ ដូចជាសម្លេងនិយាយមកខ្ញុំ កាលខ្ញុំនៅ អាយុ២ឆ្នាំដែរ។ ខ្ញុំដឹងថានោះជាព្រះអង្គ។ ហើយខ្ញុំគិត "ឥឡូវ..."

152 ហើយលឺវា។ ឥឡូវស្តាប់ការសន្ទនា។ ខ្ញុំនឹងស្រង់សំដីមកឲ្យបានល្អបំផុត តាមតែអាចធ្វើទៅបាន ដោយដឹង មួយពាក្យមួយពាក្យ ព្រោះខ្ញុំចាំបានតិច។

153 គាត់...ខ្ញុំនិយាយ...មើលទៅគាត់យ៉ាងនោះ។ គាត់និយាយ "កុំខ្លាច" ស្ងាត់ បន្តិច និយាយ "ខ្ញុំត្រូវបានបញ្ជូនមកពីវត្តមាននៃព្រះដ៏មានចេស្តា ដើម្បីប្រាប់ អ្នកពីកំណើតពិសេសរបស់អ្នក..." ដូចអ្នកដឹងហើយអំពីកំណើតរបស់ខ្ញុំ។ ជា ពន្លឺដដែលនៅលើខ្ញុំ ពេលខ្ញុំកើតដំបូង។ ហើយដូច្នេះគាត់និយាយ "កំណើត ពិសេសរបស់អ្នក ការយល់ច្រឡំក្នុងជីវិត បានចង្អុលបង្ហាញថា អ្នកត្រូវទៅទូទាំង ពិភពលោកទាំងមូល និងអធិស្ឋានដល់អ្នកឈឺ។" ហើយនិយាយ "ដោយមិនគិត ពីអ្វីដែលពួកគេមាន..." ហើយព្រះបានបង្ហាញ។ ព្រះជាម្ចាស់ ជាចៅក្រមនៃខ្ញុំ ដឹង ទេនោះ ទ្រង់បង្ហាញ "ជំងឺមហារីក។" និយាយ "គ្មានអ្វីសោះ...បើអ្នកធ្វើអោយគេ ជឿអ្នក ហើយស្មោះត្រង់ពេលអ្នកអធិស្ឋាន គ្មានអ្វីអាចឈរមុខការអធិស្ឋាន របស់ អ្នកឡើយសូម្បីតែជំងឺមហារីកក៏ដោយ។" ឃើញទេ "បើអ្នកធ្វើអោយគេជឿ។"

154 ហើយខ្ញុំឃើញថា គាត់មិនមែនជាសត្រូវរបស់ខ្ញុំទេ គាត់ជាមិត្តរបស់ខ្ញុំ។ ហើយខ្ញុំមិនស្គាល់ថាតើ—ថាតើខ្ញុំស្លាប់ ឬ មានអ្វីកើតឡើងពេលគាត់មកចំពោះ ដូចនោះ។ ហើយខ្ញុំនិយាយ "ល្អ លោក" ខ្ញុំនិយាយ "ខ្ញុំគឺ..." អ្វីដែលខ្ញុំដឹងអំពីការ ប្រោសអោយជា និង ជាអ្វីដែលខ្ញុំគិតដូច្នោះអំណោយទានទាំងនោះ? ខ្ញុំ និយាយ "ល្អ លោក ខ្ញុំគឺជា...ខ្ញុំ—ខ្ញុំគឺជាអ្នកក្រម្នាក់។" ហើយខ្ញុំនិយាយ "ខ្ញុំនៅក្នុងចំណោម ប្រជាជនខ្ញុំ ខ្ញុំ—ខ្ញុំរស់នៅជាមួយប្រជាជនខ្ញុំដែលក្រីក្រ។ ខ្ញុំមិនបានរៀនសូត្រ ទេ។" ហើយខ្ញុំនិយាយ"ហើយខ្ញុំ—ខ្ញុំ—ខ្ញុំមិនអាច ពួកគេមិន—ពួកគេមិនយល់ពីខ្ញុំ ឡើយ។" ខ្ញុំនិយាយ "ពួកគេ—ពួកគេ—ពួកគេមិនស្តាប់ខ្ញុំឡើយ។"

155 ហើយគាត់និយាយ "ដូចព្យាការីម៉ូសេទទួលបានអំណោយទានចំនួនពីរទីសម្គាល់ច្រើន" លើសពីនោះ "ដើម្បីបង្ហាញភាពត្រឹមត្រូវព័ន្ធកិច្ចលោក នោះអ្នកទទួលបានចំនួនពីរដែរ—ដូច្នេះអ្នកនឹងទទួលអំណោយទានពីរ ដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃព័ន្ធកិច្ចអ្នក។" គាត់និយាយ "ម្នាក់ក្នុងចំណោមពួកគេនឹងគឺអ្នកនឹងមានមនុស្សដែលអ្នកអធិស្ឋាននៅការដាក់ដៃ ដោយដៃឆ្វេង និងខាងស្ដាំ" ហើយនិយាយ "ហើយនៅស្មៀម ហើយនឹងមាន...នឹងមានការប៉ះពាល់ ខាងរូបកាយដែលនឹងកើតឡើង លើរាងកាយអ្នក។" ហើយនិយាយ "បន្ទាប់មកអ្នកអធិស្ឋាន។ បើចេញបាត់ជំងឺក៏ចេញពីមនុស្សដែរ។ បើវាមិនចេញទេគ្រាន់តែសុំព្រះពរ ហើយដើរ ចេញចុះ។"

"ល្អ" ខ្ញុំនិយាយ "លោក ខ្ញុំខ្លាចតែពួកគេនឹងមិនទទួលខ្ញុំ។"

156 គាត់និយាយ "ហើយការបន្ទាប់នឹងមាន បើគេមិនស្ដាប់ពីការនោះទេ ដូច្នេះគេនឹងស្ដាប់លើការនេះវិញ។" និយាយ "នឹងមានពេលមកដល់ អ្នកនឹងដឹងពីចិត្តសម្ងាត់របស់គេ។" និយាយ "ការនេះគេនឹងស្ដាប់។"

157 "ល្អ" ខ្ញុំនិយាយ "លោក នេះជាហេតុផលដែលខ្ញុំនៅទីនេះនាពេលយប់នេះ។ ខ្ញុំត្រូវបានបុព្វជិតប្រាប់ថា ការទាំងនោះដែលកើតឡើងនោះ វាជាការខុសហើយ។"

158 គាត់និយាយ "អ្នកកើតមកលើលោកនេះ សំរាប់គោលបំណងនេះហើយ។" (ឃើញទេ "អំណោយទាននិងការត្រាស់ហៅដោយមិនមានការកែប្រែចិត្ត។") គាត់និយាយ "អ្នកកើតមកលើលោកនេះសំរាប់គោលបំណងនោះហើយ។"

159 ហើយខ្ញុំនិយាយ "ល្អ លោក" ខ្ញុំនិយាយ "នោះ បុព្វជិតប្រាប់ថា វានោះ វាជា វិញ្ញាណ—អារក្ស។" ហើយខ្ញុំនិយាយ "ពួកគេ...ហេតុនេះជាហេតុផលទូលបង្គំអធិស្ឋានពេលនេះ។"

160 ហើយនេះជាអ្វីដែលគាត់ស្រង់សំដីនិយាយចំពោះខ្ញុំ។ គាត់ចូលមកទាក់ទងជាមួយខ្ញុំពីការយាងមក របស់ព្រះអម្ចាស់យេស៊ូវ ក្នុងការយាងមកជាលើកទីមួយរបស់ទ្រង់ ហើយខ្ញុំនិយាយថា...

161 រឿងចម្លែកគឺ មិត្តជាច្រើន...ល្អ ខ្ញុំនឹងឈប់ត្រង់នេះមួយនាទី ត្រលប់ទៅវិញ។ អ្វីដែលធ្វើអោយខ្ញុំកាន់តែខ្លាចទៀត គ្រប់ពេលដែលខ្ញុំជួបគ្រូទាយ ពួកគេនឹងសម្គាល់ពីរឿងដែលកើតឡើង។ ហើយនោះអាចជា...វាស្ទើរតែសម្លាប់ខ្ញុំផង។

162 ឧទាហរណ៍ មានថ្ងៃមួយបងប្អូនជីដូនមួយខ្ញុំ និងខ្ញុំនាំគ្នាទៅ—ទីកន្លែងលេងកំសាន្ត ហើយយើងជាក្មេងតូចនៅឡើយ ដើរទៅ។ ដូច្នេះមានគ្រូទាយចាស់ម្នាក់អង្គុយខាងក្រៅ ក្នុងចំណោមតង់ទីនោះ មានស្រ្តីក្មេង ស្អាត ស្រ្តីក្មេង នាងអង្គុយទីនោះ។ ហើយយើងទាំងអស់គ្នាបន្តដើរក្បែរនោះ។ នាងបាននិយាយ "និយាយ អ្នកមកទីនេះមួយភ្លែត!"ហើយក្មេងប្រុសទាំងបីក្នុងចំណោមពួកយើងបែរទៅនាង។ ហើយនាងនិយាយថា "អ្នកម្នាក់ពាក់អាវរងារពណ៌ឆ្នូត។" នោះគឺជាខ្ញុំ។

163 ហើយខ្ញុំនិយាយ "បាទ ខ្ញុំឬអ្នកស្រី?" ខ្ញុំគិតថា នាងចង់អោយខ្ញុំទៅយកទឹកក្រូចអោយនាង ឬ អ្វីទៀតស្រដៀងនឹងនោះ។ ហើយនាង—ស្រ្តីក្មេង ប្រហែលនៅទើបជាង២០ឆ្នាំ ប្រហែលប៉ុននឹង អង្គុយទីនោះ។ ហើយខ្ញុំក្រោកឡើង ខ្ញុំនិយាយ "បាទអ្នកស្រី តើអ្នកស្រីមានការអ្វីដែរ?"

164 ហើយនាងនិយាយ "និយាយ អ្នកដឹងទេ មាន—មានពន្លឺមួយនៅតាមអ្នក? អ្នកកើតមកនៅក្រោមទីសម្គាល់មួយ។"

ខ្ញុំនិយាយ "អ្នកមានន័យយ៉ាងម៉េច?"

165 នាងនិយាយ "ល្អ អ្នកកើតមកនៅក្រោមទីសម្គាល់មួយ។ មានពន្លឺមួយនៅតាមអ្នក។ អ្នកកើតមកសម្រាប់ការត្រាស់ហៅពីព្រះជាម្ចាស់។"

ខ្ញុំនិយាយ "នៅអោយឆ្ងាយពីទីនេះទៅ បងស្រីអើយ!"

166 ខ្ញុំចាប់បន្ត ព្រោះម្តាយខ្ញុំតែងប្រាប់ខ្ញុំថា ពួកគេជាអារក្ស។ គាត់ថាត្រូវ។ ដូច្នេះខ្ញុំ... នោះបានបន្លាចខ្ញុំ។

167 ហើយថ្ងៃមួយ កាលខ្ញុំជាឆ្នាំហ្គេមខ្ញុំឡើងទៅលើរថយន្តក្រុង។ ហើយខ្ញុំនៅលើរថយន្តក្រុង។ នោះតែងជាទីសំគាល់នៃព្រះវិញ្ញាណ។ ខ្ញុំបានឈរនៅទីនោះមាននារីកម្នាក់នៅពីក្រោយខ្ញុំ។ ខ្ញុំឡើងទៅល្បាត ហើយខ្ញុំទៅ ដែនព្រៃហិនរីវិល (Henryville Forestry) នៅលើរថយន្ត។ ខ្ញុំមានអារម្មណ៍ចម្លែក។ ខ្ញុំក្រលេកមើលជុំវិញនោះហើយមាន—ស្រ្តីមានមាឌធំទំងន់ធ្ងន់ ម្នាក់អង្គុយទីនោះស្លៀកឈុតស្អាតបាត។ គាត់និយាយ "អ្នកសុខសប្បាយទេ?"

និយាយ "អ្នកសុខសប្បាយទេ!"

168 ខ្ញុំគិតថា គ្រាន់ជាស្រ្តីធម្មតាប៉ុណ្ណោះ អ្នកដឹងទេ និយាយ ដូច្នេះខ្ញុំនៅបន្ត... គាត់និយាយ "ខ្ញុំចង់និយាយជាមួយអ្នកមួយភ្លែត។"

ខ្ញុំនិយាយ "បាទ លោកយាយ?" ខ្ញុំបែរមក។

គាត់និយាយ "អ្នកដឹងទេថាអ្នកកើតមកក្រោមទីសម្គាល់មួយ?"

169 ខ្ញុំគិត "ម្នាក់ទៀតក្នុងចំណោមពួកគេជាស្ត្រីកំប្លែងទៀតហើយ។" ដូច្នេះខ្ញុំចេះតែឈរមើលដោយប្រយ័ត្ន។ ខ្ញុំមិននិយាយពាក្យអ្វីទេ គឺគ្រាន់តែនៅស្ងៀម...

170 គាត់និយាយ "ខ្ញុំអាចនិយាយជាមួយអ្នកមួយភ្លែតបានទេ?" ខ្ញុំនៅបន្ត...គាត់និយាយ "កុំធ្វើអញ្ចឹងអី។"

171 ខ្ញុំនៅបន្តចាំមើល។ ខ្ញុំគិត "នេះមិនមែនដូចជារបៀបមនុស្សសុភាពទេ។"

គាត់និយាយ "ខ្ញុំចង់និយាយជាមួយអ្នកតែមួយភ្លែតទេ។"

172 ខ្ញុំនៅមើលបន្ត ហើយខ្ញុំមិនយកចិត្តទុកដាក់លើ ចំពោះគាត់ទាល់តែសោះ។ ភ្លាមនោះ ខ្ញុំគិត "ខ្ញុំជឿថា ខ្ញុំនឹងយល់ បើសិនជាគាត់និយាយដូចអ្នកផ្សេងទៀត។" ខ្ញុំបែរមក ខ្ញុំគិត "អូ ខ្ញុំ! ពាក្យនោះធ្វើអោយខ្ញុំរញ្ជួយ ខ្ញុំដឹង។" ព្រោះខ្ញុំស្អប់ការគិតរបៀបនោះ។ បែរក្រោយ។

173 គាត់និយាយ "ប្រហែល ខ្ញុំពន្យល់ខ្លួនខ្ញុំបានប្រសើរជាង។" គាត់និយាយ "ខ្ញុំជាអ្នកមើលហោរាសាស្ត្រ។"

ខ្ញុំនិយាយ "ខ្ញុំគិតថា អ្នកជាអ្វីស្រដៀងនោះដែរ។"

174 គាត់និយាយ "ខ្ញុំកំពុងនៅតាមផ្លូវរបស់ខ្ញុំទៅឈីកាហ្គូ (Chicago) ទៅមើលកូនប្រុសខ្ញុំជាអ្នកដឹកនាំក្រុមជុំនំបាបទីស្ទ។"

ខ្ញុំនិយាយ "បាទ យាយ។"

175 គាត់និយាយ"មានអ្នកធ្លាប់ប្រាប់អ្នកថាអ្នកកើតមកក្រោមទីសម្គាល់មួយទេ។"

176 ខ្ញុំនិយាយ "ទេ យាយ។" ខ្ញុំកុហកគាត់នៅទីនោះឃើញទេហើយខ្ញុំនិយាយ... គ្រាន់តែចង់មើលអ្វី ដែលគាត់ចង់និយាយ។ ហើយគាត់និយាយ...ខ្ញុំនិយាយ "ទេ លោកយាយ។"

ហើយគាត់និយាយ "មិន...មិនមានគ្រូគង្វាល ណាម្នាក់ប្រាប់អ្នកទេឬ?"

ខ្ញុំនិយាយ "ខ្ញុំមិនមានអ្វីត្រូវនិយាយជាមួយអ្នកដឹកនាំទេ។"

ហើយគាត់និយាយ "អា ហា។"

ហើយខ្ញុំនិយាយ...គាត់—គាត់និយាយមកខ្ញុំ...ខ្ញុំនិយាយ "ល្អ..."

177 គាត់និយាយ "បើខ្ញុំប្រាប់អ្នកភាពពិតប្រាកដពេលអ្នកកើត តើអ្នកនឹងជឿខ្ញុំទេ?"

ខ្ញុំនិយាយ "មិនទេ យាយ។"

ហើយគាត់និយាយ "ខ្ញុំអាចប្រាប់អ្នកពេលអ្នកកើតមក។"

ខ្ញុំនិយាយ "ខ្ញុំមិនជឿទេ។"

178 ហើយគាត់និយាយ "អ្នកកើតនៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩០៩ ម៉ោង៥ព្រឹក។"

179 ខ្ញុំនិយាយ "ត្រូវហើយ។" ខ្ញុំនិយាយ "អ្នកដឹងបានយ៉ាងដូចម្ដេច?" ខ្ញុំនិយាយ "ប្រាប់ អ្នកបើកនាវានេះពីពេលគាត់កើតទៅមើល។"

និយាយ "ខ្ញុំមិនអាចទេ។"

ហើយខ្ញុំនិយាយ "ហេតុអ្វី? តើអ្នកអាចដឹងដោយរបៀបណា?"

180 និយាយ "មើល លោក។" គាត់និយាយ មុនពេលគាត់និយាយពីតារាសាស្ត្រ ហើយគាត់និយាយ "ជាច្រើនឆ្នាំមកហើយ..." និយាយ "អ្នកចាំទេពេលផ្កាយព្រឹកមក ដែលនាំពួកហោរទាំងបីទៅកាន់ព្រះយេស៊ូវ?"

181 ហើយខ្ញុំក៏ជារបៀបនោះដែរ អ្នកដឹងទេ ខ្ញុំនិយាយ "ល្អ ខ្ញុំមិនដឹងអ្វី ទាំងអស់ពីសាសនា។"

182 ហើយគាត់និយាយ "ល្អ អ្នកបានលឺពីពួកហោរាមករកព្រះយេស៊ូវ។"

ខ្ញុំនិយាយ "បាទ។"

ហើយគាត់និយាយ "ល្អ អ្វីទៅជាហោរា?"

"អូ" ខ្ញុំនិយាយ "ពួកគេជាហោរប៉ុណ្ណោះ តាមខ្ញុំដឹង។"

183 គាត់និយាយ "ល្អ ហោរាជាអ្វី?" គាត់និយាយ "គឺដូចគ្នានឹងអ្នកគ្រូតារាសាស្ត្រ 'អ្នកមើលពីតារាសាស្ត្រ' គេហៅពួកគេថាដូច្នេះ។" ហើយគាត់និយាយ "អ្នកដឹងទេ មុនព្រះជាម្ចាស់ធ្វើអ្វីៗក្នុង—ក្នុងផែនដី ទ្រង់តែងប្រកាសនៅស្ថានសួគ៌ ហើយទើបធ្វើនៅលើផែដី។"

ហើយខ្ញុំនិយាយ "ខ្ញុំមិនដឹងទេ។"

184 ហើយគាត់និយាយ "ល្អ..." គាត់ហៅពីរ ឬ បី ពីរ...ផ្កាយបី ដូចជា ផ្កាយព្រះអង្គារ ផ្កាយព្រហស្បតិ៍ ផ្កាយសុក្រ។ វាមិនមែនអញ្ចឹងទេ ប៉ុន្តែគាត់និយាយ "ពួកវាដើរតាមផ្លូវរបស់វាហើយមករួមគ្នា ហើយបង្កើតឡើង..." និយាយ "មានហោរបីនាក់ដែលមកជួបព្រះអម្ចាស់យេស៊ូវ ហើយម្នាក់មកពីពូជហាំ ម្នាក់មកពីពូជសិម ហើយម្នាក់មកពីពូជ យ៉ាផែត។" ហើយនិយាយ "ពេលពួកគេជួបគ្នានៅបេថ្លេហិម ជាផ្កាយទាំងបីដែលបានមក...គ្រប់មនុស្សនៅលើផែនដី។" និយាយ "ពួកគេមានអ្វីទាក់ទងជាមួយផ្កាយ។" និយាយ "សួរពីនារីកម្នាក់នោះពេលព្រះច័ន្ទចេញបាត់ ហើយភពនៅលើមេឃទៅបាត់ ជំនោរមិនទៅជាមួយវាក៏ និងមកដែរ។"

ខ្ញុំនិយាយ "ខ្ញុំមិនចាំបាច់សួរគាត់បែបនោះទេ។"

185 ហើយគាត់និយាយ "ល្អកំណើតរបស់អ្នកមាន ទាក់ទងជាមួយផ្កាយទាំងនោះ។"

ហើយខ្ញុំនិយាយ "ល្អ ខ្ញុំមិនដឹងទេ។"

186 ហើយគាត់និយាយ "ឥឡូវ ហោរទាំងបីនោះមកហើយ។" ហើយនិយាយ "ពេលផ្កាយទាំងបីពួកគេ ពេលពួកគេ...ពួកគេមកពីទិសដៅ ខុសគ្នាហើយជួបនៅបេថ្លេហិម។ ហើយពួកគេនិយាយថាបានរកឃើញ ហើយពិភាក្សាគ្នា ហើយម្នាក់មកពីខ្សែស្រលាយ ហាំ សិម និង យ៉ាផែត ជាកូនប្រុសទាំងបីរបស់ណូអេ។" ហើយគាត់និយាយ "ដូច្នេះពួកគេមក និងថ្វាយបង្គំព្រះអម្ចាស់យេស៊ូវគ្រីស្ទ។" ហើយនិយាយ "ពេលពួកគេចេញទៅ។" និយាយ "ពួកគេនាំយកអំណោយ និងថ្វាយដល់ទ្រង់។"

187 ហើយនិយាយ "ព្រះយេស៊ូវគ្រីស្ទមាន ព្រះបន្ទូលក្នុងព័ន្ធកិច្ចទ្រង់ថា ពេលដំណឹងល្អបានផ្សាយដល់ចុងផែនដី (ប្រជាជនរបស់ ហាំ សិម និងយ៉ាផែត) ដូច្នេះ ទ្រង់នឹងយាងមកម្តងទៀត។" ហើយគាត់និយាយ "ឥឡូវ ពិភពទាំងបីនោះភពនៅលើមេឃតាមដែលវាបានធ្វើដំណើរ..." គាត់និយាយ "ពួកវាបានបែកចេញពីគ្នា ហើយ។ ពួកវាមិនបានមកលើផែនដីទេ តាំងពីពេលនោះមកដឹងទេ។ ប៉ុន្តែ" និយាយ "រាល់រៀងរាប់រយឆ្នាំ ពួកវានឹងកាត់តាមរង្វង់បែប*នេះ។*" បើវាលេចចេញអោយឃើញដល់គ្រូតារាសាស្ត្រទីនេះ អ្នកនឹងដឹងថា គាត់កំពុងនិយាយពីអ្វី។ ខ្ញុំមិនដឹងទេ។ ដូច្នេះ ពេលគាត់និយាយ-...និយាយ "ពួកគេកាត់តាមរបៀបនោះ។" ហើយនិយាយ "ក្នុងការរំលឹកខួបអំណោយទានដ៏អស្ចារ្យដែលបានប្រទានអោយ

មនុស្សលោក ពេលព្រះប្រទានបុត្រាទ្រង់។ ពេលភពទាំងនេះប្រសព្វខ្លួន ពួកវាម្តងទៀត ហេតុអ្វី" និយាយ "ទ្រង់បញ្ជូនអំណោយមួយទៀតដល់ផែនដី។" ហើយនិយាយ "អ្នកជាមនុស្សកើតនៅចំនុចប្រសព្វនៃវេលានោះ។" ហើយនិយាយ "នេះជាហេតុផលដែលខ្ញុំដឹង។"

188 ល្អ ដូច្នេះខ្ញុំនិយាយ "លោកស្រី ដំបូង ខ្ញុំមិនជឿអ្វីទាំងអស់។ ខ្ញុំមិនមែនជាអ្នកសាសនាអ្វីទេ ខ្ញុំក៏មិនចង់លឺអ្វីពីវាទៀតដែរ!" ដើរចេញទៅ។ ហើយដូច្នេះ ខ្ញុំកាត់គាត់ដោយខ្លីបែបនោះ។ ដូច្នេះខ្ញុំចេញទៅ។

189 ហើយពេលណា...ខ្ញុំនៅតែក្បែរម្នាក់ក្នុងចំណោមពួកគេ នោះជារបៀបដែលវាអាចកើតមាន។ ហើយខ្ញុំគិត "ហេតុអ្វីពួកគេជាអារក្ស គេអាចធ្វើដូច្នេះ?"

190 ហើយ អ្នកអធិប្បាយ និយាយ "នោះជាអារក្ស! នោះជាអារក្ស!" ពួកគេធ្វើអោយខ្ញុំជឿវា។

191 ហើយនៅយប់នោះ ពេលខ្ញុំ...ពេលគាត់សំដៅដូច្នោះ ខ្ញុំសួរគាត់ ខ្ញុំនិយាយ "ល្អ ហេតុអ្វីវាទាំងអស់ជាមជ្ឈគតិ និងអ្វីបែបនោះ ហើយពួកគេជាមនុស្សអារក្សសណ្ឋិតដែលតែងតែប្រាប់ខ្ញុំពីរឿងនេះ ហើយពួកបុព្វជិតជាបងប្អូននឹងខ្ញុំ ដែលប្រាប់ ខ្ញុំថានោះជាវិញ្ញាណអារក្ស?"

192 ឥឡូវស្តាប់គាត់និយាយ ម្នាក់នេះជាអ្នកដែលព្យូរនៅក្នុងរូបភាព។ គាត់និយាយ "ដោយព្រោះពីនោះ ដូច្នេះវាឥឡូវអញ្ចឹង។" ហើយគាត់សំដៅមកលើខ្ញុំថា "ពេលព័ន្ធកិច្ចព្រះអម្ចាស់យេស៊ូវគ្រីស្តរបស់យើងចាប់ផ្តើមឡើង អ្នកដឹកនាំនិយាយ 'ទ្រង់ជាអារក្សបៀលសេបា' ប៉ុន្តែអារក្សនិយាយ 'លោកជាបុត្រានៃព្រះ ជាអង្គបរិសុទ្ធនៃអ៊ីស្រាអែល។' អារក្ស...ហើយសម្លឹងទៅប៉ូល និងបាណាបាស ពេលពួកគេឡើងទៅអធិប្បាយ។ ពួកគ្រូគង្វាលនិយាយថា 'មនុស្សទាំងនេះនាំផែនដីអោយក្រឡាប់ហើយ ពួកគេជាអារក្សពួកគេជា—ពួកគេជាអារក្ស។' ហើយគ្រូទាយម្នាក់ដើរតាមផ្លូវរបស់នាង ស្គាល់ថាប៉ូល និងបាណាបាសជាមនុស្សរបស់ព្រះជាម្ចាស់ និយាយ 'ពួកគាត់ជាមនុស្សរបស់ព្រះជាម្ចាស់ជាអ្នកប្រាប់យើងពីផ្លូវ នៃជីវិត។'" ត្រូវទេ? "អ្នកខាងវិញ្ញាណ និងគ្រូទាយ ជាមនុស្សអារក្សចូល។"

193 ប៉ុន្តែពួកយើងជូរជ្រិញ ណាស់ជាមួយទេវសាស្ត្រ រហូតដល់យើងមិនដឹងអ្វីទាំងអស់ពីព្រះវិញ្ញាណ។ ខ្ញុំសង្ឃឹមថាអ្នកស្រលាញ់ខ្ញុំបន្ទាប់ពីនេះ។ ប៉ុន្តែ នោះ

គឺដូច្នេះឯង។ ខ្ញុំមានន័យថា ប៉េនតាខស (Pentecost) ក៏ដូច្នេះដែរ! នោះពិតណាស់។ គ្រាន់តែស្រែក និងរាំមិនមែនមានន័យថាអ្នកស្គាល់ព្រះវិញ្ញាណនោះឡើយ។

194 វាជាការទាក់ទងបែបផ្ទាល់ខ្លួន មុខទល់មុខ នោះជាអ្វីដែលអ្នកត្រូវការ។ នោះជាប្រភេទក្រុមជំនុំដែលព្រះជាម្ចាស់កំពុងកែតម្រង់អោយងើបឡើង នោះជាការពិតពេលពួកគេមករួមគ្នា និង មានអំណាចខាងឯវិញ្ញាណ។

195 ហើយលោកសំដៅបែបនោះ។ ហើយលោកប្រាប់ខ្ញុំពីរបៀបដែលព័ន្ធកិច្ចយល់ច្រឡំពីការនេះ ហើយបញ្ជាក់ខ្ញុំថាព័ន្ធកិច្ចមានការយល់ច្រឡំពីវាហើយ។ ហើយពេលលោកប្រាប់ខ្ញុំពីរឿងទាំងអស់ និងរបៀបដែលព្រះយេស៊ូវ...

196 ខ្ញុំនិយាយ "ល្អ ចុះនេះវិញ រឿងទាំងនេះដែលកើតឡើងចំពោះខ្ញុំ?"

197 ហើយ អ្នកឃើញទេ លោកនិយាយ "នោះនឹងកើនចំនួនច្រើនឡើង និងធំឡើងៗ។" ហើយលោកសំដៅចំពោះខ្ញុំ ប្រាប់ខ្ញុំពីរបៀបដែលព្រះយេស៊ូវធ្វើកិច្ចការនេះ របៀបដែលទ្រង់យាងមក និងទ្រង់មានព្រះចេស្តាដែលអាចដឹងមុនអ្វីៗ និងប្រាប់ស្ត្រីដែលនៅមាត់អណ្តូង ទ្រង់មិនបានប្រកាសថា ជាអ្នកប្រោសអោយជាឡើយ តែប្រកាសថា ធ្វើការទាំងនោះដោយព្រះបិតាបង្ហាញទ្រង់។

ខ្ញុំនិយាយ "ល្អ តើនោះជាព្រះវិញ្ញាណប្រភេទណា?"

លោកនិយាយ "គឺដោយព្រះវិញ្ញាណបរិសុទ្ធ។"

198 បន្ទាប់មកមានអ្វីមួយកើតឡើងក្នុងខ្លួនខ្ញុំ នោះខ្ញុំដឹងថា ជារឿងដែលខ្ញុំបានបែរខ្នង នោះជាអ្វីដែលព្រះជាម្ចាស់នាំខ្ញុំមកទីនេះសម្រាប់ការនោះ។ ហើយខ្ញុំដឹងថា វាដូចជាពួកផារ៉ាស៊ីក្នុងថ្ងៃដែលកន្លងទៅនោះដែរ ពួកគេបកស្រាយខុសពីខគម្ពីរមកដល់ខ្ញុំ។ បន្ទាប់ពីពេលនោះមក ខ្ញុំក៏ធ្វើការបកស្រាយដោយខ្លួនឯង នូវអ្វីដែលព្រះវិញ្ញាណបរិសុទ្ធមានបន្ទូល។

ខ្ញុំប្រាប់លោក "ខ្ញុំនឹងទៅ។"

លោកនិយាយ "ខ្ញុំនឹងនៅជាមួយអ្នក។"

199 ហើយទេវតាក៏ឈាន ចូលទៅក្នុងពន្លឺម្តងទៀត ដែលចាប់ផ្តើមមកជាជុំៗ ហើយជាជុំៗ ហើយនៅជុំជើងរបស់លោកដូចនោះ ឡើងជាពន្លឺហើយចេញពីអាគារ។

ខ្ញុំមកផ្ទះវិញជាមនុស្សថ្មី។

200 ដើរពេញព្រះវិហារ ហើយប្រាប់មនុស្សអំពីការនោះ។ នៅ...យប់ថ្ងៃ អាទិត្យ។

201 ហើយនៅយប់ថ្ងៃពុធ ពួកគេនាំស្ត្រីម្នាក់មកទីនោះ ម្នាក់ដែលទទួល គិលានុបដ្ឋាយិការបស់មាយ៉ូ (Mayo) កំពុងស្លាប់ដោយជំងឺមហារីកគ្មានអ្វីក្រៅពី ស្រមោល នោះឡើយ។ ពេលខ្ញុំដើរទៅកាន់នាងឡើង មាននិមិត្តលេចមកមុខ ខ្ញុំ បង្ហាញ អោយនាងត្រលប់ទៅវិញ ថៃរក្សាម្តងទៀត។ ហើយនាងនៅក្នុងបញ្ជី ឈ្មោះក្នុង ឡូវីសវីល (Louisville)"បានស្លាប់ជាច្រើនឆ្នាំហើយ។"នោះនាងនៅ ចេហ្វើសាន់វីល (Jeffersonville) ឥឡូវនេះ គឺថៃរក្សា ត្រូវបានថៃរក្សារាប់ឆ្នាំ។ ព្រោះខ្ញុំមើលទៅ ហើយខ្ញុំឃើញនិមិត្ត។ ខ្ញុំបែរមក ពិបាកនឹងដឹងថាខ្ញុំកំពុងធ្វើអ្វី ឈរទីនោះ ខ្ញុំញ័រ ពេលពួកគេនាំករណីនោះមក ហើយដាក់នៅទីនោះ។ ហើយ គិលានុបដ្ឋាយិកា និងអ្វីៗឈរនៅជុំវិញនោះ ហើយនាងដេកនៅទីនោះ ហើយមុខ ទាំងអស់របស់នាងផត ហើយភ្នែកលានចេញមកក្រៅ។

202 ម៉ាជីម៉ហ្គេន (Margie Morgan)។ បើអ្នកចង់សរសេរសំបុត្រអោយនាង នោះ គឺ ៤១១ ណបប្លុច អេវិនញូ ចេហ្វឺសាន់វីល អិនឌៀអាយណា (Knobloch Avenue, Jeffersonville, Indiana)។ ឬ សរសេរទៅកាន់ពេទ្យ ខ្លាកខោន ធី នៅចេហ្វឺសាន់វីល អិនឌៀអាយណា (County Hospital, Jeffersonville, Indiana)។ ចូរអោយគាត់ធ្វើ—ធ្វើទីបន្ទាល់អោយអ្នក។

203 ខ្ញុំមើលទៅទីនោះ។ ហើយនោះជាករណីដំបូងនៅទីនោះ ដើម្បីមើលនិមិត្ត ដែលចូលមក។ ខ្ញុំបានឃើញស្ត្រីម្នាក់ទទួលការថែទាំជំងឺម្តងទៀតដើរជុំវិញបានជា និងមានសុខភាពមាំល្អ។ ខ្ញុំនិយាយ "**ព្រះអម្ចាស់មានបន្ទូលបែបនេះ** 'អ្នកនឹងរស់ ហើយមិនស្លាប់ឡើយ!'"

204 ប្តីរបស់នាង បុរសខ្ពស់ម្នាក់ក្នុងពិភពលោកនេះ មើលមកខ្ញុំបែបនេះ។ ខ្ញុំ និយាយ "លោក អ្នកមិនខ្លាចទេឬ! ប្រពន្ធអ្នកនឹងរស់នៅ។"

205 គាត់ហៅខ្ញុំទៅក្រៅ និយាយ...ហៅវេជ្ជបណ្ឌិតពីរ ឬ បីនាក់ហើយ និយាយ "អ្នកស្គាល់ពួកគេទេ?"

ខ្ញុំនិយាយ "បាទ។"

206 "ហេតុអ្វី" និយាយ "ខ្ញុំលេងវាយហ្គោលជាមួយពួកគេ គាត់និយាយ 'មហារីកបានរុំជុំវិញពោះវៀន របស់នាងហើយអ្នកមិនអាច សូម្បីតែសំអាតនាងជាមួយការសុង លាងពោះវៀនផង។'"

207 ខ្ញុំនិយាយ "កុំខ្វល់ថានាងមានអ្វី! មានអ្វីមួយចូលក្នុងទីនេះ ខ្ញុំបានឃើញនិមិត្តមួយ! ហើយអ្នកនោះជាអ្នកប្រាប់ខ្ញុំ និយាយអ្វីក៏ដោយដែលខ្ញុំឃើញ ត្រូវនិយាយ វាហើយវានឹងបានជាដូច្នេះ។ ហើយលោកប្រាប់ខ្ញុំ ហើយខ្ញុំជឿវា។"

208 សរសើរព្រះជាម្ចាស់! បួនប្រាំថ្ងៃពីនោះ នាងក៏ទទួលការលាងសំអាត នៅបន្តលាងទៀត។ នាងមានទម្ងន់ប្រមាណ១៦៥ផោន ហើយឥឡូវ សុខភាពនាងល្អឥតខ្ចោះ។

209 ដូច្នេះនៅពេលខ្ញុំទទួល វាបន្តទៅទៀត។ បន្ទាប់មករ៉ូប៊ឺត ដតធឺធី (Robert Daugherty) ហៅខ្ញុំ។ ហើយនេះត្រូវចេញទៅ ផ្តើមចេញពីតិចសាស (Texas) ទៅទូទាំងពិភពលោក។

210 ហើយនៅយប់មួយ ប្រហែលម៉ោង៤ ឬ ៥...ខ្ញុំមិនអាចយល់ការនិយាយភាសាដទៃនិងអ្វីផ្សេងៗទៀត។ ខ្ញុំជឿក្នុងការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ ជឿមនុស្សដែលនិយាយភាសាដទៃ។ ហើយយប់មួយ ពេលខ្ញុំដើរទៅ...រោងឧបោសថនៅ សានអាន់តូនីយ៉ូ (San Antonio) រដ្ឋតិចសាស (Texas) ដើរទៅទីនោះ មានអ្នកមកជាមួយឈរទីនោះចាប់និយាយភាសាដទៃដូចបាញ់កាំភ្លើង ឬ កាំភ្លើងយន្តភ្លាមៗ។ ផ្លូវទៅវិញ ផ្លូវទៅទីនោះវិញ អ្នកមកជាមួយងើបឡើងហើយនិយាយ "**ព្រះអម្ចាស់មានបន្ទូលដូច្នេះថា!** បុរសដែលដើរទៅកាន់វេទិការនេះនឹងបន្តជាមួយព័ន្ធកិច្ច ដែលចាក់ប្រេងអភិសេកដោយព្រះជាម្ចាស់ដ៏មានចេស្តា។ ហើយដូចយ៉ូហានបាបទីស្ទ ដែលត្រូវបានបញ្ជូនមកជាអ្នកមកមុននៃការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ដូច្នេះគាត់ក៏ខ្ជប់ សារដែលបង្ករអោយមានការយាងមកជាលើកទីពីររបស់អម្ចាស់យេស៊ូវគ្រីស្ទ។"

211 ខ្ញុំចូលចិត្តលាក់ក្នុងស្បែកជើងខ្ញុំ។ ខ្ញុំរកមើល ខ្ញុំនិយាយ "អ្នកស្គាល់ បុរសនោះទេ?"

គាត់និយាយ "ទេ លោក។"

ខ្ញុំនិយាយ "អ្នកស្គាល់គាត់ទេ?"

គាត់និយាយ "ទេ លោក។"

ខ្ញុំនិយាយ "អ្នកស្គាល់ខ្ញុំទេ?"

គាត់និយាយ "ទេ លោក។"

ខ្ញុំនិយាយ "អ្នកកំពុងធ្វើអ្វីនៅទីនេះ?"

212 គាត់និយាយ "ខ្ញុំអានវានៅក្នុងកាសែត។" ហើយជាធម្មតា...នោះជាយប់ដំបូង នៃការប្រជុំ។

ខ្ញុំមើលទៅទីនោះហើយនិយាយ "តើអ្នកមកទីនេះដោយរបៀបណា?"

213 និយាយ "មានគ្នាខ្ញុំមួយចំនួនប្រាប់ខ្ញុំថា អ្នកនឹងមកទីនេះ 'ជាអ្នកប្រោសអោយជាពីព្រះជាម្ចាស់' ហើយខ្ញុំមក។"

ខ្ញុំនិយាយ "តើអ្នកទាំងអស់គ្នាមិនបានស្គាល់គ្នាទៅវិញទៅមកទេឬ?"

គាត់និយាយ "ទេ។"

214 អូ ខ្ញុំ! ទីនោះ ខ្ញុំបានឃើញព្រះចេស្តាដ៏អស្ចារ្យរបស់ព្រះវិញ្ញាណបរិសុទ្ធ...កន្លែងដែលត្រលប់ទៅកាលពីមុននោះខ្ញុំបានគិតថាវា ជាការខុសហើយខ្ញុំដឹងថាខ្ញុំ...ទេវតាព្រះជាម្ចាស់ ដដែលនេះគឺរួបរួមជាមួយអស់អ្នក ដែលមានសេចក្ដីទាំងនោះ។ ថ្វីបើពួកគេក្លែងក្លាយហើយមានការលាយបញ្ចូល ហើយមានការប៉ប៉ាច់ប៉ប៉ោចច្រើននៅក្នុងនោះ ប៉ុន្តែក្នុងនោះមានប្រការពិតប្រាកដ។ [ចន្លោះខ្សែអាត់—Ed។]...គ្រីស្ត។ ហើយខ្ញុំឃើញថាវា—វាជាការពិត។

215 អូ ជាច្រើនឆ្នាំកន្លងទៅ ក្នុងការប្រជុំមនុស្សនឹងបានឃើញ និមិត្តជាច្រើន និងអ្វីផ្សេងៗទៀត។

216 មានពេលមួយ អ្នកថតរូបចាប់វាបានក្នុងរូបភាព ពេលដែលខ្ញុំកំពុងឈរនៅកន្លែងណាមួយនៅ អាកកាន់សាស (Arkansas) ខ្ញុំជឿថាវាដូច្នោះ ក្នុងការប្រជុំស្រដៀងនេះ សាលប្រជុំស្រដៀងនេះ។ ហើយខ្ញុំកំពុងឈរ ព្យាយាមពន្យល់ពីសេចក្ដីនោះ។ មនុស្សបានដឹង ពួកគេអង្គុយ និងស្ដាប់ មេតូឌីស (Methodists) បាបទីស្ទ (Baptists) ព្រីសប៊ីធីរៀន (Presbyterians) និងផ្សេងៗទៀត។ ហើយខ្ញុំកើតការចង់ឃើញ ចូលមកក្នុងទ្វា នេះវាបានមក "វ៉ូសវ៉ូស!"

217 ខ្ញុំនិយាយ "ខ្ញុំមិនត្រូវនិយាយបន្តទៀតទេ ព្រោះទីនេះវាបានមក។" ហើយខ្ញុំបន្ត ហើយមនុស្សចាប់ផ្តើមស្រែក។ មកត្រង់ទីដែលខ្ញុំនៅ និងផ្សះផ្សារនៅម្តុំនោះដែរ។

218 ដូចដែលវាបានចូលមក អ្នកដឹកនាំប្រញាប់ហើយនិយាយ "និយាយ ខ្ញុំបានឃើញ!" ហើយវាក៏បានវាយគាត់អោយងងឹតដូចជា—ជាគាត់ត្រូវជាបែបនោះ ភ្ញាក់ផ្អើល។ អ្នកអាចមើលរូបភាពរបស់គាត់នៅទីនោះក្នុងសៀវភៅ ហើយឃើញថា គាត់ត្រេតត្រូតដោយក្បាលអោនចុះដូចនេះ។ អ្នកអាចឃើញក្នុងរូបភាព។

219 វាក៏ស្ងប់ចុះ។ ដូចដែលអ្នកថតរូបកាសែតថតបានវានៅពេលនោះ។ ប៉ុន្តែព្រះអម្ចាស់មិនទាន់បម្រុងជាស្រេចនៅឡើយទេ។

220 ហើយយប់មួយនៅហូសស្តុន (Houston) ក្នុងរដ្ឋ តិចសាស (Texas) ពេលដែលអូគីថាមនុស្សរាប់ពាន់ក្នុងរាប់ពាន់ដង...មានមនុស្ស៨00...គឺប្រាំបីពាន់ នាក់ នៅអ្វីដែលអ្នកហៅនោះ ពេញសាលតន្ត្រី ត្រលប់ទៅ សេម ហុសស្តុន កូលីសៀម (Sam Houston Coliseum) ដ៏ធំ។

221 ហើយមាន ការពិភាក្សានាយប់នោះ ពេលអ្នកអធិប្បាយ បាបទីស្ទនិយាយថា ខ្ញុំ "មិនមែនជាអ្វីឡើយ គ្រាន់តែជាមនុស្សកំពុតថ្នាក់ទាប និងជាក្លែងខ្លួន អ្នកក្លែងខាងសាសនា គួរតែត្រូវរត់ចេញពីក្នុងក្រុង។" ហើយគាត់ជាមនុស្សដែលគួរតែត្រូវធ្វើវា។

222 បងប្រុស បូសវើស (Bosworth) និយាយ "បងប្រុសប្រានហាំ តើអ្នកអោយរឿងបែបនោះកើតឡើងទេ? ហៅដៃរបស់គាត់មក!"

223 ខ្ញុំនិយាយ "ទេ លោក ខ្ញុំមិនជឿលើការអាញ៉េវអាញ៉ាវ ទេ។ ដំណឹងល្អមិនមែនបង្កើតសម្រាប់ត្រូវ ម៉ូម៉ៅទេ គឺបង្កើតសម្រាប់អោយមានជីវិត។" ហើយខ្ញុំនិយាយ "មិនថាអ្នកបញ្ចុះបញ្ចូលលោកប៉ុណ្ណាទេ លោកនឹងមានដំណើររបៀបដដែល។" ខ្ញុំនិយាយ "លោក...មិនធ្វើខ្លួនលោកជាភាពផ្សេងឡើយ។ បើព្រះមិនអាចមានបន្ទូលទៅកាន់ចិត្តគាត់ តើខ្ញុំអាចធ្វើបានដូចម្តេច?"

224 ថ្ងៃបន្ទាប់ វាចេញមក និយាយ "វាបង្ហាញពីអ្វីដែលពួកគេត្រូវបានបង្កើតចេញមក" ហុសស្តុន ក្រូនីកខល (Houston Chronicle)។ និយាយ "បង្ហាញអ្វី

ដែលពួកគេត្រូវបានបង្កើតចេញមក ពួកគេភ័យខ្លាច លើកឡើង អ្វីដែលគេបាន អធិប្បាយ។"

225 បងប្រុសចាស់បូសវ៉ស (Bosworth) មកជួបខ្ញុំ តាមរបៀបគាត់មានវ័យ70ឆ្នាំ គាត់ជាបង ម្នាក់គួរអោយស្រលាញ់ គាត់ដាក់ដៃជុំវិញខ្ញុំ និយាយ "ប្អូនប្រុស ប្រានហាំ (Branham)" គាត់និយាយ "អ្នកមានន័យថា អ្នកមិនធ្វើរឿងនោះទេឬ?"

226 ខ្ញុំនិយាយ "ទេ បងប្រុស បូសវ៉ស។ទេ លោក។ ខ្ញុំនឹងមិនធ្វើឡើយ។" ខ្ញុំនិយាយ "វាមិនធ្វើអ្វីជាការមិនល្អឡើយ។" ខ្ញុំនិយាយ "ត្រឹមតែបង្ករអោយមានភាព ម៉ូម៉ៅពេលយើងចេញពីវេទិការ។" ខ្ញុំនិយាយ "ខ្ញុំព្យួរការប្រជុំឥឡូវសិន ខ្ញុំមិនចង់អោយអ្វីៗបែកចេញដូចនោះឡើយ។" ខ្ញុំនិយាយ "អោយគាត់ទៅមុខ។" ខ្ញុំនិយាយ "នោះហើយ គាត់គ្រាន់តែនិយាយញាប់ប៉ុណ្ណោះ។" ខ្ញុំនិយាយ "យើងធ្លាប់មានពួកគេពីមុនមក ហើយវាមិនធ្វើអ្វីល្អអោយ និយាយជាមួយពួកគេឡើយ។" ខ្ញុំនិយាយ "ពួកគេបន្តទៅ ក្តោបខ្លួនពួកគេ។" ខ្ញុំនិយាយ "បើពួកគេធ្លាប់ចង់ទទួលបានចំណេះដឹងពីសេចក្តីពិត ហើយក្រោយមក ពួកគេមិនចង់ ក្នុងព្រះគម្ពីរបាននិយាយថា ពួកគេបានឆ្លងកាត់បន្ទាត់ដែលខណ្ឌចែកហើយ ហើយពួកគេមិនភ្លេចពីលោកិយនេះ ហើយលោកិយដែលនឹងត្រូវមក។ ពួកគេហៅវាថា 'អារក្ស' ហើយពួកគេមិនអាចជួយបានទេ។ ពួកគេត្រូវបានជាន់ ដោយវិញ្ញាណសាសនាដែលជាអារក្ស។"

227 តើមានប៉ុន្មាននាក់ដែលដឹងថានោះជាការពិត ថាវិញ្ញាណអារក្ស គឺជាភាពជាសាសនា? បាទ លោក គឺគ្រាន់តែជាគ្រឹះដូចដែលពួកគេអាច នោះ។ ហើយដូច្នេះបន្ទាប់ នេះមិនមានការប្រព្រឹត្តដោយល្អទេ ពេលខ្ញុំនិយាយថា"គ្រឹះ" ប៉ុន្តែនោះជាការពិត។ "មានទម្រង់ជាភាពព្រះជាម្ចាស់ និងបដិសេធអំណាចវិញ។" នោះជាការពិត។ ទីសម្គាល់ និងការអស្ចារ្យ គឺជាសេចក្តីដែលបញ្ជាក់ភាពត្រឹមត្រូវរបស់ព្រះជាម្ចាស់ ជានិច្ចកាល។ ហើយលោកនិយាយថា វានឹងដូចគ្នានៅថ្ងៃចុងក្រោយ។ ហើយចូរចំណាំ!

228 បងប្រុស បូសវ៉ស (Bosworth) ខ្ញុំ...គាត់នឹងមកជាមួយខ្ញុំ ហើយគាត់នឿយហត់។ ទើបតែមកពីជប៉ុន។ គាត់នឹងទៅទីនោះ។ គាត់បន្តនៅ ឡាប់ប៊ុក (Lubbock) ជាមួយខ្ញុំ។ ហើយដូច្នេះគាត់ក៏...គាត់មានរឿងតូចមួយ ផ្តាសាយខ្លាំង ដូច្នេះគាត់មិនអាចមកពេលនេះ គាត់ និងប្រពន្ធគាត់។ ហើយដូច្នេះគាត់...

229 អស់ទាំងគំនិតគាត់ដូចជាកាលែបដែរ។ គាត់ឈរទីនោះ គាត់និយាយ "ល្អ ប្អូនប្រុស ប្រានហាំ" មើលទៅជាទីថ្លៃថ្នូរណាស់ អ្នកដឹងទេ គាត់និយាយ "អោយខ្ញុំធ្វើវា" ហើយនិយាយ "បើអ្នកមិនចង់។"

230 ខ្ញុំនិយាយ "អូ បងប្រុស បូសវ៉ើស (Bosworth) ខ្ញុំ—ខ្ញុំមិនចង់អោយអ្នកធ្វើវាឡើយ។ អ្នកអាចនឹងម៉ូម៉ៅ។"

គាត់និយាយ "នឹងមិនមានពាក្យថាម៉ូម៉ៅឡើយ។"

231 ឥឡូវមុននឹងខ្ញុំបញ្ចប់ សូមស្តាប់ការនេះ។ គាត់ចេញទៅទីនោះ។ ខ្ញុំនិយាយ "បើអ្នកមិន ម៉ូម៉ៅទេ នោះមិនអីទេ។"

និយាយ "ខ្ញុំសន្យានឹងមិនម៉ូម៉ៅឡើយ។"

232 ចំណោមមនុស្ស៣ម៉ឺននាក់ ប្រជុំគ្នានៅសាលប្រជុំនាយប់នោះ។ បងវ៉ូដ (Wood) អង្គុយទីនោះ មានវត្តមាននៅពេលនោះ ហើយកំពុងអង្គុយក្នុងសាលប្រជុំនោះ។ ហើយខ្ញុំ...

233 កូនប្រុសរបស់ខ្ញុំនិយាយ ឬ...ប្រពន្ធខ្ញុំនិយាយ "អ្នកនឹងមិនទៅចូលរួមការប្រជុំនោះទេឬ?"

234 ខ្ញុំនិយាយ "ទេ។ ខ្ញុំនឹងមិនទៅទីនោះ និងស្តាប់ពួកគេនិយាយ អាញ៉េវអាញ៉ាវឡើយ។ ទេ លោក។ ខ្ញុំនឹងមិនទៅទីនោះ និងស្តាប់វាឡើយ។"

ពេលយប់មកដល់ មានអ្វីមួយនិយាយ "ទៅទីនោះចុះ។"

235 ខ្ញុំហៅតាក់ស៊ី បងប្អូនប្រុសរបស់ខ្ញុំ និងប្រពន្ធខ្ញុំរួមទាំងកូនៗខ្ញុំ យើងចេញទៅ។ ហើយយើងចេញទៅក្នុងរានហាល៣០ ផ្លូវខ្ពស់ដូចនេះ ហើយចុះ។

236 បងប្រុសចំណាស់ បូសវ៉ើស (Bosworth) ដើរចេញទៅក្រៅ ដូចជា ការទូតចំណាស់ម្នាក់ អ្នកដឹងទេ។ គាត់បានចម្លងចេញខ្លះនូវ...គាត់មានការសន្យា ខុសៗគ្នានៃការចម្លងចេញពីព្រះគម្ពីរចំនួន៦០០។ គាត់និយាយ"ឥឡូវ វេជ្ជបណ្ឌិត ប៊េស (Doctor Best) បើអ្នកមកទីនេះហើយយកការសន្យាមួយក្នុងចំណោមសន្យាទាំងអស់ហើយបង្ហាញវាថាខុសដោយព្រះគម្ពីរ។ រាល់សេចក្តីសន្យាទាំងអស់នេះ គឺនៅក្នុងព្រះគម្ពីរ ទាក់ទងនឹងព្រះយេស៊ូវគ្រីស្តប្រោសអោយជាអ្នក ជំងឺក្នុងព្រះគម្ពីរសព្វថ្ងៃនេះ។ បើអ្នកអាចយក ការសន្យាទាំងនោះហើយប្រឆាំងទៅ និងព្រះគម្ពីរ ខ្ញុំនឹងនៅស្ងៀម ចាប់ដៃអ្នក និយាយ 'អ្នកពិតជាត្រូវមែន។'"

237 គាត់និយាយ "ខ្ញុំនឹងទទួលខុសត្រូវការនោះពេលដែលខ្ញុំឡើងទៅនោះ!" គាត់ចង់បានជាលើកចុងក្រោយ ដូច្នេះគាត់អាចដកបងប្រុស បូសវើស ឃើញទេ។

238 ដូច្នេះបងប្រុសបូសវើស (Bosworth) និយាយ "ល្អ បងប្រុសប៊េស (Best) ខ្ញុំនឹងសួរអ្នកមួយ ហើយបើអ្នកនឹងឆ្លើយថា 'មែន' ឬ 'ទេ'" និយាយ "យើងផ្សះផ្សារការពិភាក្សានេះឥឡូវ។"

ហើយគាត់និយាយ—គាត់និយាយ "ខ្ញុំនឹងទទួលខុសត្រូវរឿងនោះ!"

គាត់សួរអ្នកសម្របសម្រួល ថាតើគាត់អាចសួរគាត់បានទេ។ និយាយ "បាទ"

239 គាត់និយាយ "បងប្រុសប៊េស (Best) តើព្រះនាមព្រះសង្គ្រោះ ព្រះយេហូវ៉ាសំដៅលើព្រះយេស៊ូវឬទេ? 'មែន' ឬ 'ទេ'?"

240 នោះត្រូវហើយ។ នោះគឺអញ្ចឹងមែន។ ខ្ញុំប្រាប់អ្នក ខ្ញុំមានអារម្មណ៍ថា មានអ្វីកំពុងកើតមានក្នុងខ្លួនខ្ញុំ។ ខ្ញុំមិនគិតថា ខ្លួនខ្ញុំ ឃើញ។ ហើយខ្ញុំគិត "អូខ្ញុំ អើយ គាត់មិនអាចឆ្លើយបានទេ! នោះគឺចងវាហើយ។"

គាត់និយាយ "ល្អ វេជ្ជបណ្ឌិតប៊េស (Doctor Best) ខ្ញុំគឺ—ខ្ញុំគឺទទួលការដាស់តឿនហើយ។"

គាត់និយាយ "ខ្ញុំនឹងទទួលខុសត្រូវការនោះ!"

241 និយាយ "ខ្ញុំទទួលការដាស់តឿនថា អ្នកមិនអាចឆ្លើយសំនួរដ៏ខ្សោយរបស់ខ្ញុំឡើយ។" គាត់គ្រាន់តែត្រជាក់ដូចត្រសក់ប៉ុណ្ណោះ ហើយគាត់ដឹងថាគាត់កំពុងឈរនៅទីណា។ ដូច្នេះគាត់ក៏ចាប់ផ្ដើមដោយខគម្ពីរនោះ។

និយាយ "ចំនាយពេលអ្នក៣០នាទីចុះ ខ្ញុំនឹងឆ្លើយបន្ទាប់ពីនោះ!"

242 ហើយបងប្រុសចំណាស់ បូសវើស ចាប់ផ្ដើមពីនោះ ហើយយកខគម្ពីរនោះ ហើយចងបុរសនោះ ក្នុងកន្លែងនេះរហូតដល់មុខរបស់គាត់ក្រហមខ្លាំង ដែលអ្នកអាចគូសឈើគូសបាន ប្រហែលហ្នឹង។

243 គាត់ងើបចេញពីទីនោះ ខឹង ហើយបោះក្រដាសលើកម្រាល ឡើងទៅហើយអធិប្បាយពីខេមបលទ្បៃ បានយ៉ាងល្អ។ ខ្ញុំពេលនោះជាបាបទីស្ទ ខ្ញុំស្គាល់ពីអ្វីដែលគេជឿ។ គាត់មិនដែល...គាត់មិនដែលអធិប្បាយពីការរស់ឡើងវិញឡើយ។ "'ពេលភាពអមតៈបំពាក់ដោយភាពមិនអមតៈ' ដូច្នេះយើងមានការប្រោសអោយជាមកពីព្រះជាម្ចាស់។" អូ ខ្ញុំ! អ្វីទៅដែលយើងត្រូវការការប្រោសពីព្រះជាម្ចាស់

បន្ទាប់ពីយើងក្លាយជា ភាពមិនអមតៈ ("ពេលភាពអមតៈបំពាក់ដោយភាពមិនអមតៈ" ការរស់ឡើងវិញពីសេចក្តីស្លាប់)? គាត់ក៏សង្ស័យ សូម្បីតែការអស្ចារ្យដែលព្រះយេស៊ូវធ្វើចំពោះ ឡាសា និយាយ "គាត់ស្លាប់ម្តងទៀត ហើយនោះគ្រាន់ តែជាការបណ្តោះអាសន្ន។" ឃើញទេ?

244 ហើយពេលដែលគាត់ទៅបែបនោះ គាត់និយាយ "បញ្ជូនអ្នកប្រោសអោយជាមកពីព្រះជាម្ចាស់នោះមកហើយ អោយខ្ញុំបានឃើញពីគាត់សម្តែងឡើង!"

245 វាបែកភក់បន្តិច។ បងប្រុសបូសវ័ស និយាយ "ខ្ញុំភ្ញាក់ផ្អើលនឹងអ្នកណាស់ បងប្រុសប៊ែស មិនឆ្លើយសំនួរដែលខ្ញុំសួរអ្នក។"

246 ហើយដូច្នេះគាត់ពិតជាលីលាមែន គាត់និយាយ "សូមបញ្ជូនអ្នកប្រោសអោយជាពីព្រះជាម្ចាស់មក ហើយចូរអោយខ្ញុំបានឃើញគាត់សម្តែងឡើង!"

និយាយ "បងប្រុសប៊ែស តើអ្នកជឿមនុស្ស កំពុងតែត្រូវបានសង្គ្រោះទេ?"

គាត់និយាយ "ប្រាកដណាស់!"

និយាយ "តើអ្នកចង់អោយគេហៅថាជា អ្នកសង្គ្រោះមកពីព្រះជាម្ចាស់ទេ?"

និយាយ "ពិតជា មិនឡើយ!"

247 "ហើយក៏មិនដែរ...ដែលធ្វើអោយអ្នកក្លាយជាអ្នកសង្គ្រោះពីព្រះជាម្ចាស់ ដោយព្រោះអ្នកអធិប្បាយសេចក្តីសង្គ្រោះព្រលឹង។"

គាត់និយាយ "ល្អ ពិតជាមិន!"

248 និយាយ "ទាំងមិនធ្វើអោយបងប្រុសប្រានហាំ (Branham) ក្លាយជាអ្នកប្រោសអោយជាមកពីព្រះជាម្ចាស់ ដោយការអធិប្បាយការប្រោសអោយជាមកពីព្រះជាម្ចាស់ដល់រាងកាយដែរ។ គាត់មិនមែនមិនជាអ្នកប្រោសអោយជាមកពីព្រះជាម្ចាស់ឡើយ គាត់ចង្អុលប្រាប់មនុស្សទៅកាន់ព្រះយេស៊ូវគ្រីស្ទ។"

249 ហើយគាត់និយាយ "បញ្ជូនគាត់មក អោយខ្ញុំបានឃើញគាត់សម្តែងឡើង! អោយខ្ញុំបានឃើញមនុស្ស មួយឆ្នាំចាប់ពីពេលនេះ ហើយខ្ញុំនឹងប្រាប់អ្នកថា តើខ្ញុំជឿឬអត់។"

250 បងប្រុសបូសវ័ស (Bosworth) និយាយ "បងប្រុសប៊ែស (Best) សម្លេងនោះហាក់ដូចជាមានករណីផ្សេងទៀតនៅកាល់វ៉ារី 'ចុះពីលើឈើឆ្កាងមក ហើយយើងនឹងជឿអ្នក'" ឃើញទេ?

251 ហើយដូច្នេះ អូ ដូច្នេះគាត់ពិតជាផ្ទុះបែកឡើង។ គាត់និយាយ "ចូរអោយខ្ញុំឃើញគាត់សម្តែងឡើង! ចូរអោយខ្ញុំឃើញគាត់សម្តែងឡើង!" អ្នកសម្រប សម្រួលនាំគាត់អោយនៅស្ងៀម។ គាត់ដើរទៅទីនោះ ហើយនោះ ជាអ្នកអធិប្បាយ ពេនទីកុស្ត ឈរនៅទីនោះ គាត់ទះ គាត់តាំងពីតាមផ្លូវទៅវេទិកា។ ដូច្នេះគេបញ្ឈប់គាត់។ (ដូច្នេះ បងប្រុសបូសវ៉ែសនិយាយ "នៅទីនេះ នៅទីនេះ! ទេ ទេ។") ដូច្នេះអ្នកសម្របសម្រួលក៏ទប់គាត់អោយចុះ។

252 រ៉ាយមិន រីចឈី (Raymond Richey) ងើបឡើងនិយាយ "នេះឬជាឥរិយាបថរបស់ក្រុមជំនុំបាបទីស្ទខាងត្បូង?"និយាយ"អ្នកជាអ្នកដឹកនាំបាបទីស្ទ តើក្រុមជំនុំបាបទីស្ទខាងត្បូងបញ្ជូនបុរសនេះមក ឬគាត់មកដោយខ្លួនឯង?" ពួកគេមិនឆ្លើយឡើយ។ គាត់និយាយ "ខ្ញុំសួរអ្នក!" គាត់ស្គាល់ពួកគេ គ្រប់គ្នា។

253 ពួកគេនិយាយ "គាត់មកដោយខ្លួនឯង។" ព្រោះខ្ញុំដឹងថា បាបទីស្ទក៏ជឿការប្រោសអោយជាមកពីព្រះជាម្ចាស់ដែរ។ ដូច្នេះគាត់និយាយ "គាត់មកដោយខ្លួនឯង។"

254 ដូច្នេះនេះហើយជារឿងកើតឡើង។ បន្ទាប់មកបងប្រុសបូសវ៉ែសនិយាយ "ខ្ញុំដឹងថាប្អូនប្រានហាំនៅក្នុងអង្គប្រជុំ បើគាត់ចង់មកហើយ ដេញអ្នកមកចូលរួម ល្អណាស់។"

ដូច្នេះហូវ៉ដ (Howard) និយាយ "អ្នកអង្គុយអោយស្ងៀម!"

ខ្ញុំនិយាយ "ខ្ញុំកំពុងអង្គុយនៅស្ងៀម។"

255 ហើយបន្ទាប់នោះភ្លាម មានអ្វីមួយចូលមក ចាប់ផ្តើមមានខ្យល់គួចជុំវិញហើយខ្ញុំដឹងថានោះជាទេវតារបស់ព្រះអម្ចាស់ និយាយ "ក្រោកឡើង!"

256 មនុស្សប្រហែល៥00នាក់ដាក់ដៃដូចនេះបង្កើតជាច្រកដើរចុះទៅកាន់វេទិកា។

257 ខ្ញុំនិយាយ "សម្លាញ់ទាំងអស់ ខ្ញុំមិនមែនជាអ្នកប្រោសអោយជាមកពីព្រះជាម្ចាស់ទេ។ ខ្ញុំជាបងប្អូនរបស់អ្នក។" ខ្ញុំនិយាយ "បងប្រុស ប៊ែស (Best) ជាមួយនឹងមិន..." ឬ "បងប្រុសប៊ែស" ខ្ញុំនិយាយ "មិនមែន បំបាក់មុខអ្នកដែរបងប្អូន អើយ គឺមិនសោះឡើយ។ អ្នកមានសិទ្ធិចំពោះការកាត់ទោសរបស់អ្នក ខ្ញុំក៏ ដូចគ្នា ដែរ។" ខ្ញុំនិយាយ "ព្រោះ អ្នកឃើញថាអ្នកមិនអាចបង្ហាញការនោះរបស់

អ្នក ដោយបងប្រុសបូសវ៉ែស។ អ្នកក៏មិនអាចដោយនរណាម្នាក់ដែលអាន ព្រះគម្ពីរបានច្រើន ដែលស្គាល់ការនោះ។" ខ្ញុំនិយាយ "ដូចជាការប្រោសមនុស្សអោយជា ខ្ញុំមិនអាចព្យាបាលគេបានឡើយបងប្រុសប៊ែស។ ប៉ុន្តែខ្ញុំនៅទីនេះរាល់ យប់ បើអ្នកចង់ឃើញព្រះអម្ចាស់សម្តែងការអស្ចារ្យ មកបន្តចុះ។ ទ្រង់ធ្វើវាជារៀងរាល់យប់។"

258 ហើយគាត់និយាយ "ខ្ញុំចង់ឃើញអ្នកព្យាបាលនរណាម្នាក់ និងចូរអោយខ្ញុំបានឃើញពួកគេ! អ្នកអាចសណ្តំគេ ដោយភាពសណ្តំរបស់អ្នក ប៉ុន្តែ" និយាយ "ខ្ញុំចង់ឃើញវាក្នុងមួយឆ្នាំចាប់ពីនោះ!"

ខ្ញុំនិយាយ "ល្អ អ្នកមានសិទ្ធពិនិត្យមើលពួកគេ បងប្រុសប៊ែស។"

259 គាត់និយាយ "គ្មានអ្វីក្រៅពីអ្នកជាក្រុមដ៏លេលា អ្នកជឿគិតថាខ្លួនបរិសុទ្ធ (Holy Rollers) ជឿអ្វីបែបនោះទេ។ អ្នកបាបទីស្ទមិនជឿក្នុងរឿងគ្មានហេតុផលនេះឡើយ។"

260 បងប្រុស បូសវ៉ែស និយាយ "ត្រឹមតែមួយភ្លែត។" និយាយ "មានមនុស្សប៉ុន្មាននាក់នៅទីនោះ ក្នុងការប្រជុំពីរសប្តាហ៍នេះ នោះគឺឈរក្នុងជំហរយ៉ាងល្អជាមួយព្រះវិហារបាបទីស្ទយ៉ាងស្អាតនៅហូស្តុន (Houston) នេះ ដែលអាចបង្ហាញថាអ្នកត្រូវបានប្រោសអោយជាដោយព្រះដ៏មានចេស្តា កាលដែលបងប្រុសប្រានហាំ (Branham) នៅទីនេះ?"ហើយមនុស្សជាង៣០០នាក់ក្រោកឡើង។ និយាយ"នោះជាអ្វី?"

261 គាត់និយាយ "ពួកគេមិនមែនជាបាបទីស្ទទេ!" និយាយ "អ្នកណាក៏អាចធ្វើទីបន្ទាល់អ្វីបានទាំងអស់ នោះមិនទាន់ធ្វើអោយវាបានត្រឹមត្រូវនៅឡើយ!"

262 និយាយ "ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានបន្ទូលថា វាជាការត្រឹមត្រូវ ហើយអ្នកមិនអាចទ្រាំជាមួយការនោះបានឡើយ។ ហើយមនុស្សនិយាយថា វាត្រឹមត្រូវហើយអ្នកក៏មិនអាចត្រលប់ក្រោយវិញបានដែរដូច្នេះ អ្នកនឹងធ្វើអ្វីអំពីវា?" ឃើញទេដូច្នោះឯង។

263 ខ្ញុំនិយាយ"បងប្រុសប៊ែសខ្ញុំត្រឹមតែអាចប្រាប់អ្វីជាការពិតប៉ុណ្ណោះទេ។ ហើយបើខ្ញុំគួរអោយទុកចិត្តបាន ព្រះជាម្ចាស់ក៏ត្រូវស្តារសេចក្តីពិតដែរ។" ខ្ញុំនិយាយ "បើទ្រង់មិន...បើទ្រង់មិនស្តារ សេចក្តីពិតវិញទេទ្រង់ មិនមែនជាព្រះជាម្ចាស់ឡើយ។"

ហើយខ្ញុំនិយាយ "ខ្ញុំមិនមែនព្យាបាលមនុស្សនោះទេ។ ខ្ញុំត្រូវបានកើតមក—មកជាមួយអំណោយទានអោយឃើញអ្វីៗ ឃើញវាកើតឡើង។" ខ្ញុំនិយាយ "ខ្ញុំដឹងថា ខ្ញុំយល់ខុសប៉ុន្តែខ្ញុំមិន អាចធ្វើអ្វីចៀសជាងការបំពេញ ការជឿជាក់ក្នុងចិត្តខ្ញុំឡើយ។" ខ្ញុំនិយាយ "ខ្ញុំជឿថាព្រះយេស៊ូវគ្រីស្ទរស់ពីស្លាប់។ ហើយបើព្រះវិញ្ញាណដែលមកបានបង្ហាញនិមិត្ត និងអ្វីផ្សេងៗទៀត បើនោះជាសំនួរ ទម្លាក់ចុះ ហើយស្វែងរក។" ខ្ញុំនិយាយ "នោះគឺដូច្នេះ។" ប៉ុន្តែខ្ញុំនិយាយ "ប៉ុន្តែសម្រាប់ខ្ញុំ ខ្ញុំមិនអាច ធ្វើអ្វីដោយខ្លួនខ្ញុំឡើយ។" ហើយខ្ញុំនិយាយ "បើខ្ញុំប្រាប់ពីការពិត ព្រះជាម្ចាស់អោយកាតព្វកិច្ចមកខ្ញុំ ដើម្បីជាសាក្សីថា វាជាសេចក្តីពិត។"

264 ហើយកំឡុងពេលនោះ មានអ្វីមួយកើតឡើង "វ៉ូសៗៗៗ!" នេះជាទ្រង់យាងចុះមក។ ហើយសមាគមន៍អ្នកថតរូបអាមេរិក ដូក្លាស ស្ទីឌីយ៉ូ (Douglas Studios) ក្នុងហូស្តុន (Houston) តិចសាស (Texas) មានកាមេរ៉ាយ៉ាងធំរៀបចំទីនោះ (ពួកគេត្រូវបានហាមឃាត់មិនអោយថតរូប) បានថតរូប។

265 ពេលគេនៅទីនោះ ថតរូបលោកប៉េស (Best) ហើយគាត់—គាត់និយាយ មុនខ្ញុំចុះទៅ គាត់និយាយ "រងចាំមួយភ្លែត! ខ្ញុំមានក្រដាសទស្សនាវដ្តី៦នៅទីនេះ!" គាត់និយាយ "ឥឡូវថតរូបខ្ញុំចុះ!" ហើយគាត់ដាក់ម្រាមដៃក្នុងច្រមុះបុរសចាស់បរិសុទ្ធនោះ ដូចនោះ និយាយ "ឥឡូវថតរូបខ្ញុំចុះ!" ហើយពួកគេក៏ធ្វើ។ បន្ទាប់មកគាត់ក៏ទាញកណ្តាប់ដៃមកហើយលើកឡើង និយាយ "ឥឡូវថតរូបខ្ញុំចុះ!" ហើយពួកគេថតវាបែបនោះ។ ហើយគាត់ធ្វើវាបែបនោះ ដើម្បីចោទសួរពីរូបភាពគាត់។ គាត់និយាយ "អ្នកនឹងឃើញបែបនេះក្នុងទស្សនាវដ្តីរបស់ខ្ញុំ!" ដូចនោះ។

266 បងប្រុសបូសវ៉ើស (Bosworth) ឈរនៅទីនោះ ហើយមិននិយាយអ្វីទាំងអស់។ បន្ទាប់មកពួកគេត្រឹមតែមើលរូបភាពនេះ។

267 នៅយប់នោះនៅតាមផ្លូវត្រលប់ទៅផ្ទះវិញ (ក្មេងប្រុសកាតូឡិកជិះ) គាត់និយាយ ទៅកាន់ក្មេងប្រុសមួយទៀតទីនោះ គាត់និយាយ "តើអ្នកគិតដូចម្តេចពីរឿងនោះ?"

268 គាត់និយាយ "ខ្ញុំដឹងថាខ្ញុំរិះគន់គាត់។ ដុំពកនោះស្រាប់តែបាត់ពីបំពង់កស្ត្រីនោះ ខ្ញុំនិយាយថា គាត់សណ្តំស្ត្រីនោះហើយ។" និយាយ "ខ្ញុំគួរតែខុសហើយចំពោះការនោះ។"

និយាយ "អ្នកគិតដូចម្តេចពីរូបភាព?"

"ខ្ញុំមិនដឹងទេ។"

269 ពួកគេដាក់វាក្នុងអាស៊ីដ។ នេះជារូបភាពគាត់ អ្នកអាចសួរ គាត់បានបើអ្នកចង់។ ពួកគេត្រលប់ទៅផ្ទះ ពួកគេអង្គុយទីនោះហើយជក់បារី។ ទាញបងប្រុសបួសរ៍សទៅវិញសួរទៅមក វាជារឿងអរិជ្ជមាន។ ទាញចេញពីរ បី បួន ប្រាំ ប្រាំមួយ ហើយគ្រប់គ្នាក្នុងចំណោមពួកគេនោះ គឺទទេ។ ព្រះជាម្ចាស់នឹងមិនអនុញ្ញាតិអោយមនុស្ស បរិសុទ្ធរបស់ទ្រង់ឈរទីនោះជាមួយពួកកំពុតឡើយ ជាមួយច្រមុះ ឬ ដៃកណ្តាប់ដៃអង្រួនក្រោម ច្រមុះគាត់ដូចនេះឡើយ។ ទ្រង់មិនអនុញ្ញាតិសោះឡើយ។

270 ពួកគេទាញគាត់ចេញបន្ទាប់ទៀត ហើយនេះគឺបែបនេះឯង។ បុរសនោះមានជំងឺគាំងបេះដូង ពួកគេនិយាយ នៅយប់នោះ។

271 ហើយពួកគេបញ្ជូនភាពអវិជ្ជមាននោះទៅ វ៉ាស៊ីងតុន ឌី.ស៊ី (Washington, D.C)។ វាជាសិទ្ធិចម្លង បញ្ជូនត្រលប់វិញ។

272 ហើយ ចច ជេ.ឡេស៊ី (George J. Lacy) ប្រធានអេហ្វ.ប៊ី.អាយ (F.B.I) ក្នុងផ្នែកស្នាមម្រាមដៃ និងឯកសារ និងអ្វីផ្សេងទៀត មួយក្នុងចំណោមភាពអស្ចារ្យនោះនៅក្នុងពិភពលោក ត្រូវបានយកទៅទីនោះពីរថ្ងៃ ដើម្បីពិនិត្យកាមេរ៉ា ពន្លឺ និងអ្វីផ្សេងទៀត។ ហើយពេលយើងមករសៀលនោះ គាត់និយាយ "លោកគ្រូព្រឹទ្ធាចារ្យ ប្រានហាំ ខ្ញុំបានរិះគន់ចំពោះអ្នកដែរ។" គាត់និយាយ "ហើយខ្ញុំនិយាយថា វាជាផ្នែកចិត្តសាស្រ្ត មានអ្នកបាននិយាយថា ពួកគេបានឃើញពន្លឺនិងអ្វីបែបនោះ។" ហើយនិយាយ "អ្នកដឹងទេ មនុស្សកំពុតចាស់ធ្លាប់និយាយបែបនោះ" (គាត់មានន័យថាអ្នកមិនជឿ) "'មានរូបភាពជុំវិញពួកគេ ដែលបាំងជុំវិញព្រះគ្រីស្ទជុំវិញមនុស្សបរិសុទ្ធ' គាត់និយាយ 'នោះគ្រាន់តែជាចិត្តសាស្រ្តធម្មតា។'" ប៉ុន្តែនិយាយ "លោកបុព្វជិត ប្រានហាំ ភ្នែកនៃកាមេរ៉ានេះមិនចាប់យកចិត្តសាស្រ្តទេ! ពន្លឺវាយចូលកែវម៉ាស៊ីនថត ឬ វាយចូលបែបអវិជ្ជមាន ហើយនេះជារូបភាព។" ហើយនិយាយ...

273 ខ្ញុំយល់ស្របតាមកាមេរ៉ាទាំងនោះ។ គាត់និយាយ "អូ លោក តើអ្នកដឹងទេថាវាមានតម្លៃប៉ុណ្ណា?"

ហើយខ្ញុំនិយាយ "មិនមែនសម្រាប់ខ្ញុំទេ មិនមែនសម្រាប់ខ្ញុំទេ។" ហើយដូច្នេះគាត់និយាយ...

274 "ព្រោះ វាមិនមានឥទ្ធិពល ក្នុងពេលអ្នកកំពុងរស់នៅទេ ប៉ុន្តែនៅថ្ងៃណាមួយ បើមានការទំនើបកម្មផ្លាស់ប្តូរទៅហើយ តែគ្រិស្ទាននៅតែនៅដដែល នឹងមានរឿងកើតឡើងចំពោះការនេះ។"

275 ដូច្នេះ មិត្តទាំងអស់ យប់នេះ បើនេះជាយប់ចុងក្រោយនៃការជួបជុំរបស់យើងក្នុងផែនដីនេះ អ្នក និងខ្ញុំត្រូវតាំងខ្លួននៅក្នុងវត្តមានព្រះជាម្ចាស់ដ៏មានចេស្តា។ ទីបន្ទាល់របស់ខ្ញុំជាការពិត។ ជាច្រើន មានការជាច្រើន វាត្រូវចំណាយទំហំក្នុងសៀវភៅ ដើម្បីសរសេរវា ប៉ុន្តែខ្ញុំចង់អោយអ្នកដឹង។

276 តើមានមនុស្សប៉ុន្មានអ្នកទីនេះដែលប្រាកដ មិនមានរូបភាព បានឃើញពន្លឺនៅវិលជុំវិញកន្លែងដែលខ្ញុំអធិប្បាយ? សូមលើកដៃអ្នកឡើង ក្នុងសាលអាគារនេះ មានអ្នកណាខ្លះបានឃើញវា។ ឃើញទេ ប្រហែលមានដៃប្រាំបី ទៅ ដប់នាក់ដែលអង្គុយនៅទីនេះ។

277 អ្នកនិយាយ "ពួកគេអាច អាចឃើញ ហើយខ្ញុំមិនអាចឃើញវាឬ?" បាទលោក។

278 នោះ—នោះជាផ្កាយដែលពួកហោទាំងបីបានដើរតាម ឆ្លងកាត់រាល់កន្លែងអង្កេត។ គ្មាននរណាឃើញក្រៅពីពួកគេឡើយ។ មានតែពួកគេទេ ដែលឃើញវា។

279 អេលីយ៉ា គឺកំពុងឈរទីនោះមើលរទេះក្នុងភ្លើង និងអ្វីផ្សេងទៀត។ ហើយកាហាស៊ីមើលជុំវិញ តែមិនអាចមើលឃើញថាមាននៅកន្លែងណាឡើយ។ ព្រះជាម្ចាស់មានបន្ទូល "បើកភ្នែកគេចុះ ដើម្បីអោយគេអាចមើលឃើញ។" ហើយគាត់ក៏មើលឃើញ ឃើញទេ។ ប៉ុន្តែគាត់ជាក្មេងប្រុសល្អម្នាក់ ឈរទីនោះសម្លឹងរកមើលជុំវិញ ប៉ុន្តែគាត់មិនអាចមើលឃើញឡើយ។ ប្រាកដមែន។ មនុស្សខ្លះអាចមើលឃើញ រីឯអ្នកខ្លះទៀតមិនអាចឡើយ។ ហើយនោះជាការពិត។

280 ប៉ុន្តែឥឡូវអ្នកមិនដែលឃើញវា មិនដែលបានឃើញវា ហើយអ្នកដែលបានឃើញវា ជាមួយភ្នែកធម្មជាតិឡើយ ហើយមិនដែលឃើញរូបភាពនោះទេ តែអ្នកដែលឃើញរូបភាព មានភស្តុតាងកាន់តែអស្ចារ្យ ជាងអ្នកដែលឃើញដោយភ្នែកធម្មជាតិរបស់អ្នកទៅទៀត។ ព្រោះអ្នក ដោយភ្នែកធម្មជាតិអាចមានកំហុស វាអាចជាភាន់ភ្នែក។ នោះត្រូវទេ? ប៉ុន្តែនោះមិនមែនជាការភាន់ភ្នែកឡើយ វាជាការពិត ត្រង់អ្នកស្រាវជ្រាវវិទ្យាសាស្ត្របង្ហាញថាវាជាការពិត។ ដូច្នេះព្រះអម្ចាស់យេស៊ូវបានធ្វើការនេះ។

"តើអ្នកគិតថាវាជាអ្វី" អ្នកនិយាយ "បងប្រុសប្រានហាំ (Branham)?"

281 ខ្ញុំជឿថា វាជាសសរភ្លើងដដែល ដែលនាំកូនចៅអ៊ីស្រាអែលចេញពីអេស៊ីប ទៅកាន់ភីលីស្ទីន។ ខ្ញុំជឿវាជាទេវតាដដែលនៃពន្លឺដែលមកក្នុង—ក្នុងគុក ហើយ ចូលមករកអ្នកបរិសុទ្ធពេត្រុស ហើយពាល់លោក ហើយចេញ និងបើកទ្វារ ហើយដាក់គាត់នៅក្នុងពន្លឺ។ ហើយខ្ញុំជឿថា ព្រះយេស៊ូវគ្រីស្ទនៅដដែលកាលពី ថ្ងៃម្សិលមិញ ថ្ងៃនេះ និងរៀងរហូត។ អាម៉ែន! ទ្រង់នៅជាព្រះយេស៊ូវដដែលនៅ ថ្ងៃនេះ ដូចជាទ្រង់កាលថ្ងៃម្សិលមិញ។ ទ្រង់ក៏នឹងនៅរៀងរហូត ព្រះយេស៊ូវទ្រង់នៅ ដដែល។

282 ហើយកាលខ្ញុំកំពុង និយាយពីរឿងនេះ នោះពន្លឺដូចគ្នាក្នុងរូបភាពនោះមក ទៀត...ឈរចំងាយមិនឆ្ងាយជាងពីរហ្វីតពីកន្លែងដែលខ្ញុំឈរឥឡូវ។ ពិតណាស់។ ខ្ញុំមិនអាចឃើញវាដោយភ្នែក—ភ្នែករបស់ខ្ញុំ ប៉ុន្តែខ្ញុំដឹងថា វាឈរនៅទីនោះ។ ខ្ញុំដឹង ថា វាកំពុងចូលក្នុងខ្លួនខ្ញុំឥឡូវនេះ។ អូ! បើអ្នកដឹងពីភាពខុសគ្នាពេលដែលចេស្តា នៃព្រះដែលមានចេស្តាចាប់មាន ហើយពីរបៀបដែលអ្វីៗមើលទៅខុសប្លែក!

283 នោះជាការលើកទឹកចិត្ត ដល់មនុស្សគ្រប់គ្នា។ ខ្ញុំនឹងមិនអធិស្ឋានដល់អ្នក មិនឈឺទេ ខ្ញុំនឹងធ្វើការសន្យា។ ប៉ុន្តែនិមិត្តកំពុងព្យួរលើមនុស្ស។ ហាស—ហា។ ព្រះជាម្ចាស់ទ្រង់ជ្រាប។ ខ្ញុំនឹងមិនថា គ្នាខ្សែអធិស្ឋានទេ ខ្ញុំទុកអោយអ្នកអង្គុយ នៅទីនោះ។ តើមានមនុស្សប៉ុន្មានអ្នកក្នុងចំណោមបងប្អូនមិនមានកាតអធិស្ឋាន? សូមឲ្យខ្ញុំបានឃើញដៃរបស់អ្នក អ្នកដែលមិនមានកាតអធិស្ឋាន មិនមានកាត អធិស្ឋាន។

284 ស្ត្រីសម្បុរស្បែកពណ៌អង្គុយទីនេះ ខ្ញុំឃើញដៃអ្នកលើកឡើង។ ត្រូវទេ? សូមក្រោកឡើង ដូច្នេះខ្ញុំអាចរើសអ្នកម្នាក់ឯងចេញមកមួយភ្លែត។ ខ្ញុំមិនដឹង ថា ព្រះវិញ្ញាណបរិសុទ្ធនឹងមានបន្ទូលយ៉ាងណាទេ ប៉ុន្តែអ្នកសម្លឹងមើលខ្ញុំដោយ ស្មោះត្រង់ណាស់។ អ្នកមិនមានកាតអធិស្ឋានទេ? បើសិនព្រះដ៏មានចេស្តានឹង បង្ហាញដល់ខ្ញុំពីបញ្ហារបស់អ្នក...ខ្ញុំគ្រាន់តែធ្វើការនេះជាការចាប់ផ្តើម គឺជាការ ចាប់ផ្តើម។ តើអ្នកជឿថាខ្ញុំ...អ្នកដឹងថាមិនមានអ្វីទេ...នោះមិនមានអ្វីល្អពីខ្ញុំទេ។ បើអ្នកជាស្ត្រីរៀបការហើយ ខ្ញុំមិនមែនជាអ្វីលើសជាងប្តីរបស់នាងឡើយ។ ខ្ញុំ គ្រាន់តែជាបុរសម្នាក់ប៉ុណ្ណោះ។ ប៉ុន្តែព្រះយេស៊ូវគ្រីស្ទជាបុត្រារបស់ព្រះជាម្ចាស់ ហើយទ្រង់បញ្ជូនវិញ្ញាណរបស់ទ្រង់បង្ហាញថាត្រឹមត្រូវចំពោះរឿងទាំងនេះ។

285 បើព្រះជាម្ចាស់នឹងប្រាប់ខ្ញុំ នូវអ្វីដែលមិនល្អជាមួយអ្នក (អ្នកដឹងហើយថាគ្មានផ្លូវណាសម្រាប់ខ្ញុំដែលទាក់ទងជាមួយអ្នកឡើយ) តើអ្នកជឿអស់ពីចិត្តអ្នកទេ? [បងស្រីបញ្ជាក់—Ed។] សូមព្រះប្រទានពរដល់អ្នក។ ដូច្នេះ ជំងឺលើសឈាមរបស់អ្នកចេញពីអ្នកហើយ។ នោះជាអ្វីដែលអ្នកមាន។ នោះត្រូវឬទេ? ដូច្នេះ សូមអង្គុយចុះ។

286 អ្នកគ្រាន់តែជឿម្តង! ខ្ញុំលើកទឹកចិត្តដល់អ្នកណាក៏ដោយ ជឿវាចុះ។

287 មើលមកនេះអោយខ្ញុំប្រាប់អ្នករឿងខ្លះ។ ម៉ាថា ចូលមក ព្រះអម្ចាស់យេស៊ូវ។ អំណោយទាននោះមិនដែលធ្វើការឡើយ...រហូតបន្ទាប់ពីព្រះបិតាបានបង្ហាញទ្រង់រួចហើយពីអ្វីដែលទ្រង់នឹងធ្វើ។ វាមិនធ្លាប់បានធ្វើពីមុនមកឡើយ។ ប៉ុន្តែនាងនិយាយ "ព្រះអម្ចាស់ ទូលបង្គំ...បើទ្រង់មានវត្តមាននៅទីនេះ ប្អូនប្រុសរបស់ខ្ញុំក៏មិនស្លាប់ឡើយ។" និយាយ "ប៉ុន្តែទូលបង្គំដឹងថា ទោះបីឥឡូវ អ្វីដែលលោកសុំពីព្រះជាម្ចាស់ ទ្រង់នឹងប្រទានវាដល់លោក។"

288 ទ្រង់មានបន្ទូល "ខ្ញុំជាសេចក្តីរស់ឡើងវិញ និងជាជីវិត អ្នកដែលជឿដល់ខ្ញុំទោះគេស្លាប់ក៏ដោយ តែនឹងរស់វិញ។ ហើយអ្នកណាដែលរស់ ហើយជឿដល់ខ្ញុំនឹងមិនស្លាប់ឡើយ។ ចូរអ្នកជឿទេ?"

289 ស្តាប់ដល់អ្វីដែលនាងនិយាយ។ នាងនិយាយ "ចាស ព្រះអម្ចាស់។ ទូលបង្គំជឿថាអ្វីដែលលោកនិយាយ គឺជាសេចក្តីពិត។ ខ្ញុំជឿលោកថាលោកជាបុត្រារបស់ ព្រះជាម្ចាស់ដែលត្រូវមកផែនដីនេះ។" នោះជាអ្វីដែលនាងចូលមក ដោយបន្ទាបខ្លួន។

អ្នកមានអារម្មណ៍ខុសប្លែក មិនអញ្ចឹង បងប្អូនស្ត្រី? ចាស។ នោះជាការពិត។

290 ស្ត្រីតូចម្នាក់កំពុងអង្គុយទីនោះ មានម្នាក់នៅជិតអ្នក ដែលទទួលរងជំងឺរលាកសន្លាក់ និងបញ្ហាស្ត្រី។ មិនអញ្ចឹងឬ ស្ត្រី? សូមក្រោកឈរមួយភ្លែត ស្ត្រីតូចពាក់ឈុតក្រហម។ អ្នកពិតជានៅជិតណាស់ និមិត្តមួយចូលមកដល់អ្នក។ ជំងឺរលាកសន្លាក់ និងបញ្ហាស្ត្រី។ មិនអញ្ចឹងឬ? ហើយនេះជាអ្វីនៅក្នុងជីវិតរបស់អ្នក (អ្នកមាន—មានភាពស្មោះត្រង់ណាស់ មើលទៅអ្នក): អ្នកមានការបារម្ភច្រើនណាស់ ក្នុងជីវិតអ្នក បញ្ហាជាច្រើន។ ហើយបញ្ហានោះគឺអំពីអ្នកជាទីស្រលាញ់របស់អ្នក ជាប្តីរបស់អ្នក។ គាត់ជាមនុស្សប្រមឹក។ គាត់មិនទៅ

ព្រះវិហារ។ បើនោះជាការពិតមែនសូមលើកដៃ។ ព្រះប្រទានពរដល់អ្នក ស្ត្រី។ ទៅផ្ទះឥឡូវហើយទទួលព្រះពរអ្នកចុះ។ អ្នកបានជាហើយ បំភ្លឺពន្លឺនៅជុំវិញអ្នកចុះ។

291 បុរសដែលកំពុងអង្គុយជិតគាត់ទីនោះ។ អ្នកហើយ លោក លោកជឿទេ? [បងប្រុសនិយាយ "បាទ។ ខ្ញុំជឿ។"—Ed។] អស់ពីចិត្តអ្នកទេ? ["បាទ លោក។"] អ្នកបាត់វិញ្ញាណមួយរបស់អ្នក។ នោះជាញ្ញាណក្លិន។ នោះជាការពិត ឬ មិនទេ? បើសិននោះជាការពិត គ្រវីដៃអ្នកចុះ។ ["ជាការពិត។"] ដាក់ដៃអ្នកក្នុងមាត់របស់អ្នកដូច*នេះ* និយាយ "ព្រះអម្ចាស់យេស៊ូវ ទូលបង្គំជឿទ្រង់អស់ពីចិត្តទូលបង្គំ។" ["ព្រះអម្ចាស់យេស៊ូវ ទូលបង្គំជឿទ្រង់អស់ពីចិត្តទូលបង្គំ។"] សូមព្រះប្រទានពរដល់អ្នក។ ទៅឥឡូវចុះ។ អ្នកទទួលការប្រោសអោយជារបស់អ្នកហើយ។

292 ចូរមានជំនឿដល់ព្រះជាម្ចាស់! តើអ្នកទាំងអស់គិតថានេះជាអ្វី ត្រលប់ទៅវិញ? តើអ្នកជឿទេ? ចូរកោតខ្លាចចុះ!

293 មានស្ត្រីម្នាក់អង្គុយខាងស្តាំនៅជ្រុងនោះ។ ខ្ញុំឃើញពន្លឺនៅពីលើគាត់។ មានផ្លូវតែមួយប៉ុណ្ណោះដែលខ្ញុំអាចប្រាប់ពីការនោះបាន ពន្លឺនៅកំពុងលើនោះ។ ពន្លឺ*នេះ*នៅពីលើស្ត្រីនោះ។ សូមនៅមួយភ្លែត បើខ្ញុំអាចឃើញវាជាអ្វី។ វាធ្វើរួចហើយ... ស្ត្រីកំពុងមានជំងឺជាមួយ—ជាបញ្ហាបេះដូង។ គាត់កំពុងសំលឹងចំមកខ្ញុំ។

294 ហើយប្តីរបស់នាងកំពុងអង្គុយក្បែរនាង។ ហើយប្តីរបស់នាងក៏មានជំងឺគាត់ទើបតែឈឺ ពិបាកចិត្ត ជំងឺ។ មិនអញ្ចឹងឬ លោក? លើកដៃអ្នកឡើង បើនោះជាការពិត។ នោះជាការពិត គឺអ្នក ស្ត្រីមានកន្សែងតូចនៅទីនោះ។ លោក តើត្រូវទេ? អ្នកមិនសប្បាយចិត្តទេថ្ងៃនេះ? អ្នកមិនសប្បាយចិត្តនឹងរឿងក្រពះបុរស។ ត្រូវទេ។

295 អ្នកជឿអស់ពីចិត្តអ្នកទេ ទាំងពីរអ្នក? អ្នកទទួលទេ? លោក ខ្ញុំប្រាប់លោកអ្នកក៏អញ្ចឹងដែរ ខ្ញុំឃើញដៃលោកលើកឡើង ទម្លាប់ការជក់បារីឬ? ឈប់ធ្វើទៀតទៅ។ អ្នកជក់បារីស៊ីហ្កា អ្នកមិនគួធ្វើដូច្នេះឡើយ នឹងធ្វើអោយអ្នកឈឺ។ មិនអញ្ចឹងឬ? បើពិតមែនសូមគ្រវីដៃដូចនេះ។នោះជាអ្វីធ្វើអោយអ្នកមិនសប្បាយចិត្ត។ វាមានការអាក្រក់លើប្រសាទរបស់អ្នក។ បោះរបស់អាក្រក់ចោលទៅ ហើយកុំធ្វើវាទៀត ហើយអ្នកនឹងយកឈ្នះវាបាន ហើយជាឡើងវិញ បញ្ហាបេះដូងរបស់ប្រពន្ធ

អ្នកនឹងចេញពីនាងដែរ។ អ្នកជឿទេ? មិនអញ្ចឹងឬ? ខ្ញុំមិនអាចមើលឃើញអ្នកពីទីនេះទេ ហើយអ្នកក៏ដឹងដែរ ប៉ុន្តែអ្នកមានបារីស៊ីហ្គានៅ...ក្នុង—ក្នុងហោប៉ៅខាងមុខរបស់អ្នក។ នោះជាការពិត។ ដាក់របស់ទាំងនោះចេញក្រៅហើយដាក់ដៃលើប្រពន្ធរបស់អ្នក ទូលដល់ព្រះជាម្ចាស់ថាអ្នកបានឈ្នះរបស់ទាំងនោះ អ្នកទៅផ្ទះវិញបានជាហើយ អ្នក និងប្រពន្ធអ្នកនឹងបានជា។ សូមអោយព្រះនាមព្រះអម្ចាស់យេស៊ូវប្រកបដោយព្រះពរ!

អ្នកជឿអស់ពីចិត្តអ្នកទេ?

296 ស្ត្រីតូចម្នាក់កំពុងអង្គុយនៅទីនេះសម្លឹងមកខ្ញុំ។ អ្នកនៅ...នៅកៅអីខាងមុខអង្គុយនៅទីនេះ។ ស្ត្រីតូចម្នាក់ដោយ...សម្លឹងមកខ្ញុំ កំពុងអង្គុយទីនោះ។ គឺស្ត្រីរាងតូចម្នាក់ជាមួយនឹង...មើលមកខ្ញុំ អង្គុយនៅទីនោះ។ អ្នកមិនមាន...អ្នកមិនមានកាតអធិស្ឋានទេ ស្ត្រី នៅទីនេះ? អ្នកមិនមានកាតអធិស្ឋានទេឬ? តើអ្នកជឿអស់ពីចិត្តទេ? អ្នកជឿថាព្រះយេស៊ូវគ្រីស្ទអាចព្យាបាលអ្នកទេ?

297 អ្នកគិតយ៉ាងណាពីរឿងនេះ អ្នកអង្គុយក្បែរគាត់? តើអ្នកមានកាតអធិស្ឋានទេស្ត្រី? អ្នកមិនមានទេឬ? អ្នកចង់ជាដែរឬទេ? តើអ្នកមិនចង់ទៅបរិភោគម្តងទៀតដូចដែលអ្នកធ្លាប់ មានបញ្ហាក្រពះឬអី? អ្នកជឿថាព្រះយេស៊ូវប្រោសអ្នកអោយជាឥឡូវទេ? ក្រោកឡើងបើអ្នកជឿថាព្រះយេស៊ូវព្យាបាលអ្នកឥឡូវ។ អ្នកមានដំបៅក្រពះ មិនអញ្ចឹង? វាកើតឡើង ដោយសារស្ថានភាពសសៃប្រសាទ។ អ្នកមានការឈឺចាប់យូរមកហើយ។ ជាពិសេសអាស៊ីដនិងអ្វីទៀត ឬ ខ្ញុំមានន័យថាបង្កើតអាស៊ីដ ហើយឈឺធ្មេញពេលអ្នកខ្ពុរអាហារចូលក្នុងមាត់។ នោះជាការពិត។ បាទលោក។ វាជាដំបៅផ្នែករំលាយអាហារ វាកើតនៅបាតក្រពះរបស់អ្នក។ ថាចុកនៅពេលខ្លះ បន្ទាប់ពីបរិភោគជាពិសេសនំប៉័ងជាមួយប័រ។ ពិតទេ? ខ្ញុំមិនកំពុងអានចិត្តរបស់អ្នកប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធមិនដែលបរាជ័យឡើយ។ ឥឡូវនេះអ្នកជាហើយ។ ទៅផ្ទះ ហើយអោយបានជាចុះ។

298 តើអ្នកត្រលប់វិញក្នុងទិសដៅនេះដូចម្តេច? មានអ្នកមួយចំនួននៅទីនោះមិនមានកាតអធិស្ឋានទេ សូមលើកដៃ។ អ្នកដែលមិនមានកាតអធិស្ឋាន។ ល្អ ចូរជឿជាក់ចុះជឿដោយអស់ពីចិត្តរបស់អ្នក។ ចុះអ្នកនៅរានខាងមុខនោះវិញ? មានជំនឿដល់ព្រះជាម្ចាស់ចុះ។

299 ខ្ញុំមិនអាចធ្វើការនេះដោយខ្លួនខ្ញុំឡើយ គឺដោយព្រះគុណដ៏ជារាជ្យរបស់ទ្រង់ប៉ុណ្ណោះ។ តើអ្នកជឿទេ? ខ្ញុំអាចនិយាយត្រឹមតែអ្វីដែលទ្រង់បង្ហាញខ្ញុំប៉ុណ្ណោះ។ ដោយសេចក្តីជំនឿរបស់អ្នក...ខ្ញុំនិយាយថា អង្រួនជំនឿរបស់អ្នក ហើយមើលថាផ្លូវមួយណាដែលទ្រង់ដឹក នាំខ្ញុំ។ តើអ្នកដឹងរឿងនេះ—នេះមិនមែនជាបងប្អូនរបស់អ្នកទេឬ? អ្នកកំពុងឈរក្នុងវត្តមាន របស់ទ្រង់។ មិនមែនខ្ញុំទេដែលធ្វើការនេះ គឺជាជំនឿរបស់អ្នកដែលបានសម្តែងឡើង។ ខ្ញុំមិនអាចធ្វើវាបានទេ។ ចាំមួយភ្លែត។

300 ក្នុងជ្រុងនេះ ខ្ញុំឃើញបុរសស្បែកពណ៌ម្នាក់អង្គុយទីនោះ ជាមនុស្សចាស់ ពាក់វ៉ែនតា។ អ្នកមានកាតអធិស្ឋានទេ លោក? ក្រោកឈរឡើងមួយភ្លែត។ អ្នកជឿថា ខ្ញុំជាអ្នកបម្រើព្រះជាម្ចាស់ទេ អស់ពីចិត្តរបស់អ្នកទេ? អ្នកកំពុងគិតពីអ្នកណាម្នាក់ទៀត ឬមិនមែន? បើពិតមែនគ្រវីដៃរបស់អ្នក។ មិនមែនដោយព្រោះខ្ញុំទេ ជាបងប្អូនអ្នក។ ឥឡូវ អ្នកមិនមានកាតអធិស្ឋាន។ នឹងគ្មានផ្លូវណាអ្នកចូលក្នុងជួរបានឡើយ ព្រោះមិនមានកាតអធិស្ឋាន។ ឥឡូវ បើអ្នកណានៃអ្នកទាំងអស់គ្នាមានកាតអធិស្ឋាន កុំ—កុំ—កុំលើកដៃ ឃើញ ព្រោះអ្នកមានឱកាសចូលក្នុងជួរ។

301 ប៉ុន្តែខ្ញុំឃើញពន្លឺនៅលើគាត់។មិនទាន់បំបែកជានិមិត្តនៅឡើយ។ ខ្ញុំមិនអាចព្យាបាលអ្នកឡើយ បងប្អូនប្រុស ខ្ញុំមិនអាចឡើយ។ មានតែព្រះប៉ុណ្ណោះដែលអាចធ្វើការនោះ។ ប៉ុន្តែ អ្នក...អ្នក...អ្នកមានជំនឿ។ អ្នកកំពុងជឿ។ ហើយមានអ្វីមួយ—អ្វីមួយ វាគឺ—វាបង្ក វាឡើង ដោយរបៀបណាមួយ។

302 បើព្រះដ៏មានចេស្តានឹងប្រាប់ពីបុរសនេះពីបញ្ហារបស់គាត់ តើអ្នកផ្សេងទៀតដែលនៅសល់ ជឿលើការប្រោសអោយជារបស់អ្នកឬទេ? មានបុរសម្នាក់ឈរចម្ងាយដប់ទៅ១៥យ៉ាតពីខ្ញុំ ខ្ញុំមិនដែលជួបគាត់នៅក្នុងជីវិតខ្ញុំឡើយ។ គាត់ជាបុរសម្នាក់ឈរនៅទីនោះ។ បើសិនជាព្រះដ៏មានចេស្តា នឹងបើកសម្តែងពីការមិនល្អនៃបុរសនោះ គ្រប់គ្នាក្នុងចំណោមបងប្អូនគួរតែដើរចេញទៅពីទីនេះ ដោយបានជាស្រួលវិញ។ តើអ្វីទៀតដែលព្រះជាម្ចាស់អាចធ្វើ? ត្រូវ ឬ ទេ?

303 លោក គ្មានអ្វីជាបញ្ហាចំពោះលោកឡើយ។ អ្នកខ្សោយ ភ្ញាក់ឡើងបន្តិចនៅពេលយប់ ឈឺក្រពេញឈ្មោលបុរស និងអ្វីទៀត ប៉ុន្តែនោះមិនមែនជាបញ្ហារបស់អ្នកឡើយ។ បញ្ហារបស់អ្នក គឺបារម្ភចំពោះកូនប្រុសរបស់អ្នក។ ហើយកូនប្រុសរបស់អ្នកនៅក្នុងវិទ្យាស្ថានរដ្ឋណាមួយ ហើយគាត់មានលក្ខខណ:ពីរ។ មែនទេ? គ្រវីដៃអ្នក បើសិនជាពិតមែន។ ជាការពិតណាស់។

304 ប៉ុន្មានអ្នកដែលឥឡូវជឿថា ព្រះយេស៊ូវគ្រីស្ទ ជាបុត្រារបស់ព្រះជាម្ចាស់កំពុងឈរនៅទីនេះ? ចូរក្រោកឡើង ហើយថ្វាយការសរសើរ និងទទួលការប្រោសអោយជារបស់យើង។

305 ព្រះដ៏មានចេស្តា ជាអ្នកផ្តល់កំណើតជីវិត ប្រទានរាល់អំណោយល្អ ទ្រង់គង់នៅទីនេះជាព្រះអម្ចាស់យេស៊ូវគ្រីស្ទនៅដូចថ្ងៃម្សិលមិញ ថ្ងៃនេះ និងរៀងរហូតទៅ។

306 ហើយសាតាំង អ្នកបានបញ្ឆោតមនុស្សទាំងនេះយូរមកហើយ ចេញពីពួកគេភ្លាម! យើងបង្គាប់ឯងដោយព្រះជាម្ចាស់ដ៏មានព្រះជន្ម ដែលមានវត្តមាននៅទីនេះក្នុងទម្រង់ជាសសរភ្លើង ទុកមនុស្សទាំងនេះ! ហើយចេញពីពួកគេ ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ!

307 អ្នកគ្រប់គ្នាលើកដៃអ្នក ឡើងហើយសរសើរព្រះជាម្ចាស់ ហើយទទួលការប្រោសអោយជារបស់អ្នក គ្រប់គ្នា។ [ក្រុមជំនុំសរសើរព្រះជាម្ចាស់—Ed។]

## របៀបដែលទេវតាមកចំពោះខ្ញុំនិងបេសកកម្ម KHM55-0117

(How The Angel Came To Me, And His Commission)

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅថ្ងៃច័ន្ទ ទី 17 មករា 1955 នៅវិទ្យាល័យ Lane Tech, Chicago, Illinois, U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែអាត់ថត ចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសាអង់គ្លេស។ ការបក ប្រែជាភាសាខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក។

KHMER

©2018 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវេបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG